ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ មិនមានចំនួនជីវិកាណាមួយមកដោះដូរជាមួយនឹងការស្លាប់

◆ នីកូឡាស គុំចាន់ បញ្ជាក់ពីជំហរស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦៨ ខែធ្នូ ឆ្នាំ២០១៣

# ស្វែងរកការពិត

លេខ១៦៨ ខែធ្នូ ឆ្នាំ២០១៣

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

### មាតិកា

◆ មិនមានចំនួនថវិកាមកដោះដូរជាមួយ ........................................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព គុយ ជា បុគ្គលិកទូត........................................២

◆ ព្រឹត្តិការណ៍សំខាន់ប្រចាំឆ្នាំ២០១៣ ........................................៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ប្រាសាទព្រះវិហារ ក្នុងពេលខ្មែរក្រហមគ្រប់គ្រង ..........................១០

◆ ថ្ងៃបញ្ចប់កិច្ចពិភាក្សាដេញដោលនៅអង្គជំនុំជម្រះ ..........................១២

◆ សម្រាប់មនុស្សភាគច្រើន រណសិរ្សជាអ្នកផ្តល់..........................២៥

**ផ្នែកច្បាប់**

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ..........................២៧

◆ ការរៀបចំសំណង ការប្រឈមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ...............៣៣

**វេទិកាពិភាក្សាសាធារណៈ**

◆ នីកូឡាស គុំចាន់ បញ្ជាក់ពីជំហរស្វែងរកយុត្តិធម៌ ..........................៣៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទណ្ឌិតផ្លែល្ពៅ ........................................................៤៣

◆ ចាត់ទុកជាសំណាង ..................................................៥៩



សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គុំចាន់ ដែលទើបតែងតាំងថ្មី



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ** : ខាត់ថារី ឌើណូខូអើ, វ៉េនឌល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ, លន់ ដាលីន, គ្រីស្ទីន ប័រត័រលី, ឆាយ ស៊ូឆាត្រ, អ៊ឹម ច័ន្ទបូរ៉ាជាតិ **អ្នកនិពន្ធនិងស្រាវជ្រាវ** : ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ** : នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ** : ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក** : សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** : សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** : ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# មិនមានចំនួនថវិកាណាមួយមកដោះដូរជាមួយនឹងការស្លាប់ ការប៉ះទង្គិចផ្លូវចិត្ត និងការឈឺចាប់ដែលបានកើតឡើងនៅកម្ពុជាបានឡើយ

សព្វថ្ងៃ យើងមិនអាចនិយាយអំពីប្រជាធិបតេយ្យ យុត្តិធម៌ ឬសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ដោយគ្មានគិតពីប្រវត្តិសាស្ត្រនោះទេ ពីព្រោះដើម្បីនិយាយអំពីប្រធានបទអ្វីមួយក្នុងចំណោមប្រធានបទទាំងនេះ គឺតម្រូវឲ្យមានការបកស្រាយពីបញ្ហាមួយផ្សេងទៀតដោយជៀសមិនផុត ។ ទោះបីជាបែបនេះក៏ដោយ ការរកថវិកាមកផ្គត់ផ្គង់កិច្ចការចងក្រងឯកសារ ការអប់រំ និងការស្រាវជ្រាវឯកសារ គឺជាបញ្ហាដ៏លំបាកមួយ ។ បញ្ហាលំបាកនេះគឺមួយផ្នែកដោយសារតែភាពលម្អៀងរបស់អន្តរជាតិទៅលើសកម្មភាពជាក់លាក់ណាមួយ ។ ម្ចាស់ជំនួយ ឬម្ចាស់ផ្តល់មូលនិធិភាគច្រើនដែលធ្វើការនៅអាស៊ីអាគ្នេយ៍មានវ័យក្មេង និងមិនសូវជាស្គាល់ភាពទំនាក់ទំនងគ្នាទៅវិញទៅមករវាងប្រវត្តិសាស្ត្រ និងសិទ្ធិមនុស្ស ។ ម្ចាស់ជំនួយបរទេសមានទំនោរទៅរកការយកចិត្តទុកដាក់យ៉ាងជិតស្និទ្ធទៅនិងកាលៈទេសៈកម្ពុជានាពេលបច្ចុប្បន្ន ដោយមិនបានគិតឲ្យបានស៊ីជម្រៅទៅលើឥទ្ធិពលពីអតីតកាលដែលមានលក្ខណៈស្មុគស្មាញជាងនេះ ។ ជាការពិត យើងឃើញមានការយកចិត្តទុកដាក់ខ្ពស់ទៅនិងកិច្ចការមួយចំនួនដែលផ្តល់លទ្ធផលភ្លាមៗ និងអាចវាស់ស្ទង់បានភ្លាមៗដែលធ្វើឲ្យមានការផ្លាស់ប្តូរជីវិតដល់អ្នកដែលទទួលផលប្រយោជន៍ដែលជាគោលដៅ ប៉ុន្តែទាក់ទងទៅនឹងបញ្ហាអភិវឌ្ឍន៍រយៈពេលវែងបញ្ហាទាំងនេះមិនដែលទទួលបានការចាប់អារម្មណ៍ដែលបញ្ហាទាំងនោះទាមទារឲ្យមានការដោះស្រាយ ។

កិច្ចការស្រាវជ្រាវមិនមែនជាការងារឆើតឆាយនិងសប្បាយដែលបង្កើតលទ្ធផលស្រួលៗនិងក្នុងរយៈពេលខ្លីនោះទេ ។ កិច្ចការចងក្រងឯកសារនិងការស្រាវជ្រាវតម្រូវឲ្យមានការតាំងចិត្តវែងឆ្ងាយ ដែលកិច្ចការទាំងអស់នេះមិនត្រូវទៅនិងគោលដៅរបស់ម្ចាស់ជំនួយដែលយកថវិការបស់ខ្លួនទៅចំណាយដល់គម្រោងណាមួយដែលផ្តល់លទ្ធផលភ្លាមៗ ។ លើសពីនេះទៅទៀត កិច្ចការចងក្រងឯកសារ និងការស្រាវជ្រាវ ជាញឹកញាប់ លទ្ធផលដែលទទួលបានគឺមានលក្ខណៈមិនអាចបង្ហាញបាន និងមិនអាចវាស់ស្ទង់បាន បើសិនជាគ្មានការស្រាវជ្រាវឲ្យបានស៊ីជម្រៅ ។ ខ្ញុំតែងតែមានការលំបាកយ៉ាងខ្លាំងដើម្បីស្វែងរក «ទីផ្សារ» សម្រាប់កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ យើងអាចប្រើពាក្យដែលពិបាកយល់មួយចំនួនដូចជា «ការចងចាំ» «ការពិត» និង «យុត្តិធម៌» ដើម្បីសម្រួល និងធ្វើឲ្យងាយយល់អំពីកិច្ចការរបស់យើងតែទីបំផុត មិនថាយើងបកស្រាយយ៉ាងណាចំពោះអ្វីដែលយើងធ្វើនោះទេ យើងធ្វើការជាមួយការចងចាំ (និងភាពសោកនាដកម្មដែលចេះតែកើតមានឡើងនៃព្រលឹងរបស់មនុស្ស ហើយមិនមានចំនួនថវិការណាមួយមកដោះដូរជាមួយនិងការស្លាប់ ការប៉ះទង្គិចផ្លូវចិត្ត និងភាពឈឺចាប់ដែលបានកើតឡើងនៅកម្ពុជាបានឡើយ ។ **ឆាំង យុ**



រូបថតអ្នកទោសនៅគុកទួលស្លែង

# ចម្លើយសារភាព គុយ ជា បុគ្គលិកទូតរណសិរ្សនៅសូវៀត

*ដកស្រង់ចេញពីឯកសារចម្លើយសារភាពD៥៨៩៧១*

គុយ ជា ជានិស្សិតសារព័ត៌មាននៅសហភាពសូវៀត ។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦ ។ នៅលើក្របមុខចម្លើយសារភាពរបស់ គុយ ជា ត្រូវបានសរសេរដោយដៃថា “គុយ ជា ភ្នាក់ងារសម្ងាត់ K.G.B សូវៀត” ។

គុយ ជា បានសរសេរចម្លើយសារភាពផ្ទាល់ដៃកម្រាស់ ៨៥ទំព័រ ដែលមានចុះកាលបរិច្ឆេទពីថ្ងៃទី២៦ ខែកញ្ញា ដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៦ ដោយមានរៀបរាប់ពីសកម្មភាពចូល K.G.B និងសកម្មភាពពេលត្រឡប់មកប្រទេសកម្ពុជាវិញ ។ ខាងក្រោមនេះជាការសង្ខេបចេញពីការរៀបរាប់របស់ គុយ ជា ៈ

កាលពីចុងឆ្នាំ១៩៦៩ ដោយការលំបាកក្នុងការសិក្សាមុខវិជ្ជាសេដ្ឋកិច្ចនយោបាយនិងប្រវត្តិសារព័ត៌មានអន្តរជាតិ ខ្ញុំបាននិយាយទៅអ្នកកាសែតម្នាក់ជាអ្នកទទួលខុសត្រូវខាងផ្សាយភាសាខ្មែរឈ្មោះ វ៉ាឡេរី ជាសមាជិកនៃអង្គការសម្ងាត់ K.G.B ឲ្យជួយអន្តរាគមន៍ឲ្យមានការបន្ធូរបន្ថយខ្លះចំពោះមុខវិជ្ជានេះក្នុងពេលប្រឡង ។ កាលនោះខ្ញុំធ្វើការនៅក្នុងវិទ្យុមូស្គូ ។ វ៉ាឡេរី បាននាំខ្ញុំទៅជួប អ៊ីកូនីកូវ៉ា អ្នកកាសែត និងជាគណៈកម្មាធិការកណ្តាលនៃសមាគមមិត្តភាពសូវៀត-កម្ពុជា ។ ទាំងពីរនាក់នេះជាសមាជិកគណៈកម្មាធិការសាលារបស់ K.G.B ប្រចាំនៅវិទ្យុមូស្គូ បានសន្យាថានឹងជួយខ្ញុំដើម្បីជាប្រយោជន៍ទៅវិញទៅមក ។ ក្រោយមក អ៊ីកូនីកូវ៉ា បាននាំខ្ញុំទៅជួប នីកូឡៃ កួរាគីន ធ្វើការនៅអង្គការកូសូមម៉ុល ដែលទទួលខុសត្រូវយុវជន និងនិស្សិតមកពីកម្ពុជា និងឡាវ ដើម្បីជួយអន្តរាគមន៍នៅមហាវិទ្យាល័យបន្ត ។ ដល់ពេលទៅប្រលងខ្ញុំបានជាប់មែន ។ ខ្ញុំសប្បាយចិត្តណាស់ ដោយមានគោលដៅបញ្ចប់ការសិក្សា ។ ក្រោយមកខ្ញុំបានជួបអ្នកទាំងនេះជាញឹកញាប់ ដើម្បីផ្លាស់ប្តូរយោបល់ពីបញ្ហានយោបាយ ពិសេសសង្គ្រាមនៅប្រទេសកម្ពុជា ។

នៅដើមខែមេសា ឆ្នាំ១៩៧០ ក្រោយរដ្ឋប្រហារ ខ្ញុំបានវាយទូរលេខទៅសម្តេច សីហនុ នៅក្រុងប៉េកាំង ដើម្បីសុំចូលជាសមាជិករណសិរ្ស ។ ក្រោយមក ខ្ញុំក៏បានទៅជួប ជា សាន មេទូតរណសិរ្សនៅមូស្គូទៀត ប៉ុន្តែគាត់ថាកុំអាលច្រួលច្របល់ ចាំឲ្យសូវៀតជួយយើងសិន ។

មានថ្ងៃមួយ នៅឆ្នាំ១៩៧១ នីកូឡាយ កួរាគីន បានទូរស័ព្ទមកខ្ញុំ សុំជួបនៅភោជនីយដ្ឋានមួយនៅកណ្តាលក្រុងមូស្គូ ដោយបាននាំគ្នាគាត់ម្នាក់ទៀតឈ្មោះ អាណា តូលី ភ្នាក់ងារ K.G.B មកជួបដែរ ។ អ្នកទាំងពីរបានសួរនាំខ្ញុំពីការរស់នៅ ការងារ និងការរៀនសូត្រ បន្ទាប់មក អាណា តូលី បានសួរខ្ញុំថាតើត្រូវធ្វើយ៉ាងម៉េចដើម្បីទាក់ទងជាមួយរណសិរ្សបាន? ខ្ញុំបានឆ្លើយថា រឿងនេះវាហួសពីសមត្ថភាពរបស់ខ្ញុំទៅហើយ ។ ប៉ុន្តែអ្នកទាំងពីរបានស្នើឲ្យខ្ញុំជួយស៊ើបរកដំណឹងក្នុងចំណោមអ្នកដឹកនាំរណសិរ្សនៅក្រៅស្រុក ពិសេសអ្នកស្រឡាញ់សម្តេច សីហនុ ដោយសារឃើញខ្ញុំមានការទាក់ទងល្អជាមួយ ជា សាន ឯកអគ្គរាជទូតកម្ពុជានៅមូស្គូ ។


ជា សាន

នៅពេលនោះដែរ ភ្នាក់ងារសម្ងាត់ K.G.B របស់សូវៀតបានផ្តល់ភារកិច្ចឲ្យខ្ញុំផ្តល់ឲ្យវាពីជីវប្រវត្តិ និងស្ថានភាពសង្គមនៃសមាជិករដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ជាសរុប ខ្ញុំសុខចិត្តទទួលធ្វើភ្នាក់ងាររបស់K.G.B ចាប់ពីពេលនោះមក ។


ចៅ សេង

នៅឆ្នាំ១៩៧១ ដដែល ខ្ញុំដឹងតាម ចៅ សេង ពេលគាត់ធ្វើដំណើរកាត់តាមមូស្គូទៅប៉េកាំងថា សារិន ឆាក បានទុកតំណាងទូតម្នាក់ឲ្យប្រចាំការទាក់ទងជាមួយក្រសួង

ការបរទេសបារាំង ។ ជាបន្តបន្ទាប់ ខ្ញុំបានទទួលព័ត៌មានពីការទាក់ទងរបស់រណសិរ្សជាមួយតំណាងអាមេរិក និង លន់ នល់ ដូចជា វេជ្ជបណ្ឌិតរីស្ស និង ខែក វ៉ាន់ឌី ដែលការជួបប្រព្រឹត្តទៅនៅទីក្រុងប៉េកាំង ព្យុងយ៉ាង និងអាល់ហ្សេរី និងការដែលរណសិរ្សមិនសប្បាយចិត្តជាមួយ អៀង សារី ដែលធ្វើសេចក្តីថ្លែងការណ៍នៅអាល់ហ្សេរី និងទំនាស់រវាងរណសិរ្សខាងក្នុង និងខាងក្រៅ ។ ខ្ញុំបានផ្តល់ព័ត៌មានទាំងនេះឲ្យអង្គការសម្ងាត់ *K.G.B* ដែលដំណឹងខ្លះដឹងតាមរយៈ ជា សាន ពេលត្រឡប់មកពីប្រជុំនៅទីក្រុងប៉េកាំងក្នុងនាមជាសមាជិកការិយាល័យនយោបាយ ។

នៅចុងឆ្នាំ១៩៧១ ខ្ញុំបានទៅចូលរួមសមាជយុវជនប្រជាធិបតេយ្យកម្ពុជានៅអឺរ៉ុបរយៈពេលពីរសប្តាហ៍ដែលចាប់ផ្តើមនៅទីក្រុងប៊ុលការែស ប្រទេសរ៉ូម៉ានី និងបញ្ចប់នៅទីក្រុងបែលក្រាដ ប្រទេសយូហ្គោស្លាវី ក្នុងនាមជាសមាជិកប្រតិភូយុវជនរណសិរ្សរួបរួមកម្ពុជានៅសហភាពសូវៀត ។ ក្នុងដំណើរទៅមក អង្គការកូសូមម៉ុលចេញប្រាក់កាក់ឲ្យខ្ញុំទាំងអស់ ។ នៅមុនពេលចេញដំណើរមួយថ្ងៃ អាណា តូលី បានណែនាំខ្ញុំឲ្យនិយាយការពារផលប្រយោជន៍សូវៀត ដោយលើកពីសូវៀតជួយការតស៊ូរំដោះប្រជាជនកម្ពុជានៅពេលធ្វើសេចក្តីថ្លែងការណ៍បញ្ចប់សមាជ ។ ខ្ញុំបានជិះរថភ្លើងពីមូស្គូទៅរ៉ូម៉ានី ជាមួយ ឡាំ វ៉ារី និង អ៊ុក សុក ។ នៅតាមផ្លូវ យើងបានពិភាក្សាចុះសម្រុងគ្នាលើការទទួលជំនួយសូវៀតក្នុងពេលចម្បាំង បើមិនដូច្នេះទៅថ្ងៃអនាគតនឹងធ្លាក់ចូលកណ្តាប់ដៃចិនមិនខាន ។ ពេលទៅដល់ក្រុងប៊ុយការែស ខ្ញុំបានជួប ទន់ ជោត សារិន តំណាងសមាគមពលករកម្ពុជា នៅប្រទេសបារាំងដើម្បីស្នើដាក់បញ្ចូលសូវៀតនៅក្នុងសេចក្តីថ្លែងការណ៍ ហើយនៅមុននោះខ្ញុំក៏បានស្នើជាមួយ ចៅ សេង ដែរ ។ ប៉ុន្តែនៅពេលបញ្ចប់សមាជ គណៈកម្មាធិការពិសេសសម្រាប់និពន្ធសេចក្តីថ្លែងការណ៍ បាននិពន្ធយោងទៅតាមការណែនាំរបស់សម្តេច ប៉ែន នុត ដែលផ្ញើតាមទូរលេខមកពីទីក្រុងប៉េកាំង ។ ដូច្នេះ ផែនការដែលសូវៀតប្រគល់ឲ្យខ្ញុំឥតបានជាលទ្ធផលអ្វីទាំងអស់ ។

នៅឆ្នាំ១៩៧២ ជា សាន ប្រធានទូតរណសិរ្សនៅសូវៀត ដែលជាសមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃរដ្ឋាភិបាលរណសិរ្ស បានសម្រេចដកខ្ញុំពីវិទ្យុមកធ្វើការនៅស្ថានទូតរណសិរ្សវិញ ដោយសារតែជាងពីរឆ្នាំហើយ សូវៀតមិនព្រមទទួលស្គាល់រដ្ឋាភិបាលរណសិរ្សរួបរួមជាតិ ។ នៅស្ថានទូតខ្ញុំមានភារកិច្ចរៀបចំព្រឹត្តប័ត្រព័ត៌មានសំខាន់ ដែលចុះផ្សាយពីការបង្កើតរណសិរ្ស និងអត្ថបទដែល ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម សរសេរគាំទ្រកំណើតរណសិរ្សសម្រាប់ផ្សាយទៅឲ្យបេសកកម្មការទូត និងអ្នកសារព័ត៌មាននៅសូវៀតបានដឹង ។ ខ្ញុំបានយកព័ត៌មានពីរណសិរ្សតាមរយៈស្ថានទូតនៅមូស្គូ និងព័ត៌មានដែល ជា សាន ជួបជាមួយតំណាងទូតបារាំងនៅមូស្គូ និងបានតាមដានគណៈប្រតិភូរដ្ឋសភា និងគណៈប្រតិភូយោធាដែលដឹកនាំដោយ ញឹក ជូឡុង ដែលមកធ្វើទស្សនកិច្ចនៅសូវៀត រួចហើយផ្តល់ទៅឲ្យភ្នាក់ងារ *K.G.B* ។

ខ្ញុំបញ្ចប់ការសិក្សានៅខែមិថុនា ឆ្នាំ១៩៧៥ ក្រោមការឧបត្ថម្ភជ្រោមជ្រែងរបស់មហាវិទ្យាល័យ និងតាមរយៈអន្តរាគមន៍របស់អង្គការសម្ងាត់ *K.G.B* ។ ក្រោយជ័យជម្នះ ១៧ មេសា នីកូឡៃ គួរាគីន ហៅខ្ញុំទៅជួបនៅភោជនីយដ្ឋាន «យុវជន» នៅក្រុងមូស្គូ ដោយនិយាយថា សូវៀតរីករាយណាស់ដោយសារជ័យជម្នះនេះ ។ គាត់បានប្រាប់ខ្ញុំឲ្យខំសរសេរនិក្ខេបបទ ហើយប្រាប់ថា ភារកិច្ចខ្ញុំជាអ្នកកាសែតត្រូវបម្រើឲ្យផលប្រយោជន៍ប្រទេសទាំងពីរ ។ គាត់ក៏បាននិយាយពីការដែលសូវៀត មិនសប្បាយចិត្តដោយសារខ្មែរក្រហមចាប់អ្នកការទូតសូវៀត ហើយបណ្តេញចេញពីកម្ពុជា ។

នៅខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំបានសុំរដ្ឋាភិបាលចូលស្រុក តែរដ្ឋាភិបាលថាឲ្យចាំមួយរយៈសិន ។ នៅក្នុងពេលរង់ចាំនេះ អង្គការសម្ងាត់ *K.G.B* បានឲ្យអាហារូបករណ៍ខ្ញុំជាកម្មសិក្សាការី ។

លុះដល់ខែមិថុនា ឆ្នាំ១៩៧៦ ទើបអង្គការអនុញ្ញាតឲ្យខ្ញុំចូលស្រុក ។ នៅមុនពេលចូលស្រុកពីរបីថ្ងៃ ខ្ញុំបានជួបជាមួយភ្នាក់ងារសម្ងាត់ *K.G.B* ដូចជា វ៉ាឡេរី, អាណា តូលី, គួរាគីន និងមនុស្សជាច្រើនទៀត នៅភោជនីយដ្ឋានប៉េកាំង ។ ខ្ញុំទទួលបញ្ជាឲ្យធ្វើយ៉ាងណាឲ្យបានចូលធ្វើការក្នុងកាសែត ឬអង្គការផ្សាយដំណឹងណាមួយ ។ អ្នកទាំងនេះបានណែនាំខ្ញុំឲ្យជួប ជួន មុំ និងអ្នកមួយចំនួនទៀត ដូចជា ជា ខន, ហាក់ សៀងឡាយនី, ម៉ិល សុវណ្ណ, គ្រិន លាន, ហេង ពេជ្រ, អ៊ុក សុក, ព្រហ្ម ភឿន អតីតនិស្សិតនៅសូវៀត និង បាន យ៉ាន អតីតនិស្សិតនៅបារាំង ។ ក្រៅពីនេះ


ហាក់ សៀងឡាយនី


ម៉ិល សុវណ្ណ


ជា ខន


ព្រហ្ម កឿន

បានផ្ដាំខ្ញុំឲ្យប្រាប់ ជា ខន (ចូលមកស្រុកនៅចុងឆ្នាំ១៩៧៥) ថា នៅស្ថានទូតឡាវប្រចាំភ្នំពេញមានអតីតនិស្សិតឡាវម្នាក់ដែលធ្លាប់សិក្សានៅសូវៀត ។ ចំណែកការសួរសុខទុក្ខមិត្តយើងអ្នកទាំងនោះថា ចាំផ្ដាំតាម ឡាំ វ៉ារី និង អ៊ុយ ឡួន ដែលទៅតាមក្រោយ ។

ពេលមកដល់ប្រទេស ខ្ញុំមករស់នៅក្នុងសមូហភាពនៅមន្ទីរក១៧ចាស់រយៈពេលពីរខែ ។ អ្នកដែលខ្ញុំធ្លាប់ស្គាល់មានឈ្មោះ ជីង ជុនលាង បុគ្គលិកទូតកម្ពុជានៅកូរ៉េ និងអ្នកដែលរួមដំណើរជាមួយខ្ញុំ ហៃ គឹមស៊ាង ធ្វើការនៅទូតគុយបា ជាមួយប្រពន្ធ (ត្រូវជាកូនរបស់ ហួត សម្បត្តិ) និងកូនស្រីម្នាក់ ។ ក្រៅពីនោះ ខ្ញុំស្គាល់ប្រពន្ធរបស់មិត្តខ្ញុំម្នាក់ អ៊ីវ សេនារក្ស (ធ្វើការនៅស្ថានទូតខ្មែរនៅមូស្គូ) និងកូនបីនាក់ ។ នៅទីនោះ ខ្ញុំមិនហ៊ានឡើងនិយាយអ្វីទេពេលប្រជុំម្ដងៗ ព្រោះក្ដាប់សភាពការណ៍មិនទាន់បាន ។

លុះទៅនៅមន្ទីរថ្មី ក្នុងផែនការបំផុសចលនាប្រឆាំងអង្គការចាត់តាំងខ្ញុំបានបង្កើនការទាក់ទងរឹតតែល្អថែមទៀតជាមួយ ជា គង់ មកពីស្រុកបារាំងដែលធ្លាប់នៅមន្ទីរចាស់ជាមួយគ្នា ។ នៅក្នុងមន្ទីរថ្មី អង្គការចាត់តាំងខ្ញុំ និង ជា គង់ ឲ្យនៅក្រុមខាងកសិកម្ម និងនៅបន្ទប់ជាមួយគ្នា ។ នៅកន្លែងធ្វើការ ខ្ញុំបានវាយប្រហារខ្លាំងទៅលើមេពួក និងមេក្រុម ដោយឈរលើជំហរបុគ្គល ។ ជា គង់ បានសរសើរខ្ញុំ "ថាពូកែនិយាយ ថាក្លាហានប្រឆាំងការជិះជាន់ ថាធ្វើយ៉ាងនេះត្រូវហើយ គេគាំទ្រ" ។ លុះដល់ពេលប្រជុំរួម ក្រោមអធិបតីភាពអង្គការ ហើយបន្ទាប់ពីពិគ្រោះជាមួយ ជា គង់ ខ្ញុំបានឡើងបញ្ចេញមតិវាយប្រហារខ្លាំងទៅលើគណៈទទួលខុសត្រូវដែលខ្ញុំចាត់ទុកថា គ្មានសមត្ថភាពក្នុងការដឹកនាំសមូហភាព ជាពិសេស ក្នុងការហូបចុកដែលមានការខ្វះខាត ។ ខ្ញុំបានវាយប្រហារទៅលើមេពួក មេក្រុមខ្លះ ដែលគ្មានសមត្ថភាពទាំងក្នុងការចាត់តាំងការងារ ទាំងក្នុងការបំពេញការងារពលកម្ម ។ ស្អែកឡើង ជា គង់ ដែលទទួលបន្ទុកស្រង់មតិនៅក្នុងសមូហភាពប្រាប់ខ្ញុំថា ភាគច្រើនគាំទ្រការវាយប្រហាររបស់ខ្ញុំ ។

ក្រោយពីខ្ញុំនិយាយនៅក្នុងអង្គប្រជុំបានពីរថ្ងៃ អង្គការបានផ្លាស់ខ្ញុំចេញពីក្រុមកសិកម្មឲ្យទៅនៅក្រុមសេដ្ឋកិច្ចវិញ ។ មេក្រុមសេដ្ឋកិច្ចសុភាពរាបសា និងទន់ភ្លន់ជាងមេក្រុមចាស់របស់ខ្ញុំ ។ មេក្រុមដែលសុភាពរាបសានេះហើយដែលធ្វើឲ្យខ្ញុំអស់លេសដើម្បីវាយប្រហារនៅពេលប្រជុំរួម ។ លុះដល់មួយសប្ដាហ៍កន្លងមកទៀត ពេលប្រជុំរួម ខ្ញុំក៏ឡើងចាប់អារម្មណ៍ ។ ម្ដងនេះ ខ្ញុំវាយប្រហារពីរឿងបបររាវ បបរដួម ហើយខ្ញុំទម្លាក់កំហុសនេះទៅលើគណៈទទួលខុសត្រូវដែលមើលងាយសមូហភាព ។ រាវខាប់ ស្រេចតែក្បាលចិត្ត ធ្វើដូចរបបចាស់ដែលម្នាក់ៗធ្វើតាមតែក្បាលចិត្ត ។ រយៈពេលប៉ុន្មានថ្ងៃក្រោយមក នៅក្នុងសមូហភាពចាប់មានការស្មុគស្មាញ ជ្រួលច្របល់កាន់តែខ្លាំង ។ ជាលទ្ធផល អង្គការបានឃាត់ខ្លួនខ្ញុំ ហើយចាប់យកមកទីនេះ ។

សេចក្ដីដូចជម្រាបខាងលើជាសក្ខីភាពនៃការវង្វេងជាតិរបស់ខ្ញុំ និងជាការសារភាពទាំងស្រុងនូវកំហុសក្បត់ចំពោះបដិវត្តន៍កម្ពុជាដែលខ្ញុំបានប្រព្រឹត្ត ទោះជាសតិអារម្មណ៍ក្ដី ទោះជាការបញ្ចេញជាក់ស្ដែងក្ដី ។

ខ្ញុំសង្ឃឹមថា អង្គការបដិវត្តន៍នឹងលើកលែងប្រណីទោសនេះដល់រូបខ្ញុំ ហើយកសាងខ្ញុំឲ្យមានមាគ៌ាជាតិត្រឹមត្រូវ មានមាគ៌ាអង្គការបដិវត្តន៍យើង ដែលខ្ញុំប្ដេជ្ញាដើរតាមដោយគ្មានលក្ខខណ្ឌ ។

ខ្ញុំភ្ញាក់រឭកហើយ ខ្ញុំរាងចាលហើយ ។

ជយោ! អង្គការបដិវត្តន៍កម្ពុជាដ៏មហាភ្លឺស្វាង មហាអស្ចារ្យ ។

**សោម ប៊ុនថន**

# ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ២០១៣

### ខែមករា

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១៣ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកចាយសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩) ចំនួនពីរពាន់ក្បាលដល់និស្សិត និងយុវជនស្ម័គ្រចិត្តដែលចូលរួមក្នុងពិធីប្រារព្ធរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះដោយរបបខ្មែរក្រហមនៅសារមន្ទីរប្រល័យពូជសាសន៍ជើងឯក ។ កម្មវិធីនេះរៀបចំដោយក្រុមយុវជនស្ម័គ្រចិត្ត ដឹកនាំដោយឯកឧត្តម ហ៊ុន ម៉ានី ក្នុងគោលបំណងរំឭកទៅដល់ថ្ងៃជ័យជម្នះ ៧ មករា ជាថ្ងៃដែលរបបខ្មែរក្រហមដួលរលំ ។



### ខែកុម្ភៈ

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋបានយាងចូលទិវង្គតនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១២ ដោយជំងឺគាំងបេះដូងនៅមន្ទីរពេទ្យទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិនក្នុងជន្មាយុ៩០ព្រះវស្សា ។ ព្រះបរមសពត្រូវបានដឹកតាមយន្តហោះពិសេសរបស់ចិនបានមកដល់ប្រទេសកម្ពុជានៅថ្ងៃទី១៧ ខែតុលា ដោយមានអ្នកចាំទទួលរាប់លាននាក់ ។ ប្រជាពលរដ្ឋកម្ពុជាភាគច្រើនយល់ឃើញថា ការសោយទិវង្គតរបស់



ព្រះមហាវីរក្សត្រ សម្តេចព្រះ នរោត្តម សីហនុ ជាទីស្រលាញ់របស់ខ្លួនគឺជាការបាត់បង់ដ៏ធំធេងរបស់ជាតិ ។ ព្រះអង្គត្រូវបានប្រជាជនកម្ពុជាទូទៅចាត់ទុកថាជាមេដឹកនាំមួយរូបដែលបានទាមទារឯករាជ្យពីបារាំងជូនជាតិមាតុភូមិ និងបានធ្វើការបង្រួបបង្រួមប្រជាជនក្នុងប្រទេសឲ្យក្លាយជាជាតិខ្មែរតែមួយ ។ ព្រះរាជពិធីបុណ្យព្រះបរមសពត្រូវបានប្រារព្ធឡើងចាប់ពីថ្ងៃទី១ដល់៤ ខែកុម្ភៈ ឆ្នាំ២០១៣ ។

### ខែមីនា

អៀង សារី មានឈ្មោះដើម គីម ត្រាង និងមានឈ្មោះបដិវត្តន៍ វ៉ាន់ ទទួលមរណភាពនៅវេលាម៉ោង៨និង៤៥នាទីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ដោយជំងឺបេះដូងនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត ទីក្រុងភ្នំពេញក្រោយពីបានបញ្ជូនទៅទីនោះកាលពីថ្ងៃទី៤ ខែមីនា ។ សពរបស់ អៀង សារី ត្រូវបានដឹកទៅកាន់ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យនៅថ្ងៃដដែលដើម្បីធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា ។ អៀង សារី កើតនៅខេត្តត្រាវិញ វៀតណាមខាងត្បូង ។ គាត់គឺជាអតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ និងមានប្រពន្ធឈ្មោះ អៀង ធីរិទ្ធ ដែលជាអតីតរដ្ឋមន្ត្រីសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ អៀង សារី និង អៀង



ធីរិទ្ធ ត្រូវបានចាប់ខ្លួននៅផ្ទះរបស់ខ្លួននាទីក្រុងភ្នំពេញ និងបញ្ជូនទៅឃុំឃាំងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អៀង សារី ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅចន្លោះពេលដែលខ្លួនកាន់អំណាចពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ឧក្រិដ្ឋកម្មទាំងនោះមានៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើមនុស្សឃាត ។

### ខែមេសា



អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានខ្វែងគំនិតគ្នារវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិជាថ្មីទៀតលើសំណុំរឿង០០៣ ដែលមានភាពចម្រូងចម្រាសគ្នាដោយបដិសេធនូវបណ្តឹងឧទ្ធរណ៍របស់អ្នកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានការទាត់ចោលម្តងរួចមកហើយកាលពីលើកមុន ក្រោយពីបណ្តឹងនេះដាច់តាំងនោះ ។ សេចក្តីសម្រេចនេះស្តែងឲ្យឃើញបន្ថែមទៀតនូវភាពមិនប្រក្រតីលើនីតិវិធីក្នុងការគ្រប់គ្រងសំណុំរឿង និងធ្វើឲ្យមានកង្វល់ឡើងវិញអំពីសមត្ថភាពរបស់តុលាការក្នុងការចាត់ការស៊ើបអង្កេតដែលនៅសេសសល់ និងមិនលម្អៀង ។

### ខែឧសភា



គ្រូច គឹមសាន អាយុ៦១ឆ្នាំ មកពីសង្កាត់ផ្សារដើមថ្កូវ ក្រុងភ្នំពេញ បានរកឃើញដំណឹងបងប្រុសរបស់គាត់ឈ្មោះ ហៃ សំអុល តាមរយៈកាសែតរស្មីកម្ពុជាចុះថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០១៣ ។ គឹមសាន បានបាត់ដំណឹងបងប្រុសគាត់ ហៃ សំអុល ជាយូរមកហើយដោយមិនដឹងទៅទីណា ។ តាមរយៈអត្ថបទដែលសរសេរដោយ ឆាយ ដារីន នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ទើបគឹមសាន ដឹងថា ហៃ សំអុល ត្រូវបានខ្មែរក្រហមបញ្ជូនទៅមន្ទីរសន្តិសុខស្រុកកងមាស តំបន់៤១ ភូមិភាគឧត្តរ និងបានស្លាប់នៅទីនោះ ។ គឹមសាន បានមកមជ្ឈមណ្ឌលឯកសារកម្ពុជានៅថ្ងៃបន្ទាប់ដើម្បីស្រាវជ្រាវព័ត៌មានបន្ថែមទាក់ទងនឹងបងប្រុសរបស់គាត់ ។

### ខែមិថុនា

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ម៉ាស៊ីនថតរូប រួមទាំងរូបថត និងឯកសារមួយចំនួនទៀតត្រូវបានលោក អ៊ឹង វ៉េងអៀង ដែលជាកូនប្រុសបង្កើតរបស់អតីតអ្នកទោស និងអ្នករួចរស់ជីវិតម្នាក់ពីមន្ទីរស-២១ ឈ្មោះ អ៊ឹង ប៉ិច ផ្តល់ជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ៊ឹង ប៉ិច គឺជាអ្នករៀបចំ និងចាត់ចែងប្រែក្លាយមន្ទីរស-២១




ទៅជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងក្នុងឆ្នាំ១៩៧៩ ។ អំឡុងទសវត្សរ៍៨០ អ៊ឹង ប៊ិច បានប្រើម៉ាស៊ីនថតរូបមួយនេះ ដើម្បីថតទិដ្ឋភាពឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតឡើងអំឡុងរបបខ្មែរក្រហម និងបានថតរូបរណ្តៅសាកសពជាច្រើនទូទាំងប្រទេស ។ អ៊ឹង វើងអៀង បានប្រគល់ម៉ាស៊ីនថតរូប រូបថត វីដេអូ និងឯកសារ មកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសារតែលោកមិនសប្បាយចិត្ត ព្រោះមានការបកស្រាយខុសទាក់ទងទៅនឹងប្រវត្តិសាស្ត្រពិតនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

**ខែកក្កដា**




នៅក្នុងខែកក្កដា ឆ្នាំ២០១៣នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលកំណត់ហេតុជីវប្រវត្តិរបស់ ប៉ូច យូនលី ដែលជាអំណោយពីសាច់ញាតិរបស់គាត់ម្នាក់ឈ្មោះ ប៉ូច សោភ័ណ ។ ប៉ូច យូនលី ជាអតីតអធិការបឋមសិក្សា និងបានបម្រើការងារជាច្រើនទៀតទាក់ទងទៅនឹងការអប់រំនៅសាលារៀនក្នុងខេត្តកំពង់ធំ និងខេត្តកំពង់ចាម និងនៅក្រសួងអប់រំ ។ ប៉ូច យូនលី ចាប់ផ្តើមសរសេរកំណត់នេះនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៥ និងបញ្ចប់នៅភូមិជីទាវជ្រែងនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៦ ជាថ្ងៃដែលគាត់ត្រូវបានចាប់ខ្លួន និងបាត់ខ្លួនជារៀងរហូត ។

**ខែសីហា**



កាលពីថ្ងៃទី១៧ ដល់ថ្ងៃ២២ ខែសីហា គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) របស់មជ្ឈមណ្ឌលឯកសារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) ដល់គ្រូបង្រៀនផ្នែកភូមិវិទ្យា-ប្រវត្តិវិទ្យា អក្សរសាស្ត្រខ្មែរ និង សីលធម៌-ពលរដ្ឋ មកពីខេត្តតាកែវ និងកំពត ចំនួន១០០នាក់ នៅសាលាគរុកោសល្យ និងវិក្រឹត្យការខេត្តតាកែវ ។ រហូតមកដល់ខែសីហា ឆ្នាំ២០១៣ នេះ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) មានគ្រូដែលបានទទួលការបណ្តុះបណ្តាលពីប្រវត្តិសាស្ត្រ និងវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប្រមាណជាង៣.០០០នាក់ ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលគ្រូបង្រៀននេះ គឺផ្តោតសំខាន់ទៅលើការគោរពសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។

## ខែកញ្ញា




ចាប់ពីខែសីហា រហូតដល់ពាក់កណ្ដាលខែកញ្ញា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលបុគ្គលិកភូមាពីររូបមកពីបណ្ដាញចងក្រងឯកសារស្ដីអំពីសិទ្ធិមនុស្សនៅប្រទេសភូមា ឬមានឈ្មោះជាភាសាអង់គ្លេសថា *Network for Human Rights Documentation-Burma (ND-Burma)* ដើម្បីរៀនសូត្រពីរបៀបចងក្រងឯកសារ របៀបធ្វើសម្ភាសន៍ជាមួយជនរងគ្រោះក្នុងរបបខ្មែរក្រហម និងអតីតកម្មាភិបាលខ្មែរក្រហម របៀបបញ្ចូលទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ និងកិច្ចការមួយចំនួនទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើ និងកំពុងធ្វើ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែធ្វើកិច្ចសហការជាមួយបណ្ដាញចងក្រងឯកសារស្ដីអំពីសិទ្ធិមនុស្សនៅប្រទេសភូមា ។ បណ្ដាញនេះបានបង្កើតគម្រោងមួយមានឈ្មោះថា «គម្រោងស្វែងរកការពិតមិនផ្លូវការ» ក្នុងគោលបំណងបង្កើតឲ្យមានការផ្លាស់ប្ដូរយោបល់គ្នាជាមួយសមាជិករបស់គណបក្សនយោបាយជួបជាមួយអ្នកដែលធ្លាប់ជាប់គុក ដោយរឿងនយោបាយនិងការប្រាស្រ័យទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាលនានានៅប្រទេសភូមា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានទស្សនៈថា រាល់អំពើជិះជាន់គាបសង្កត់ណាមួយពីសំណាក់រដ្ឋអំណាច ត្រូវតែមានចំណាត់ការ និងការឆ្លើយតបដោយខានមិនបានតាមរយៈវិធីសាស្ត្រសមរម្យណាមួយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានគាំទ្ររាល់ការប្រឹងប្រែងកិច្ចការចងក្រងឯកសារនៅប្រទេសភូមា ។

## ខែតុលា

ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី៣១ ខែតុលា សាលាក្ដីខ្មែរក្រហម



បានបើកកិច្ចសវនាការចុងក្រោយបញ្ចប់ការដេញដោលសម្រាប់ករណី០០២ វគ្គទីមួយ ទៅលើជនត្រូវចោទ នួន ជា និង ខៀវ សំផន ។ សវនាការករណី០០២ វគ្គទីមួយនេះផ្ដោតទៅលើឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ គ្រប់ភាគីទាំងអស់បានធ្វើការបកស្រាយអំណះអំណាងរៀងៗខ្លួន ។ នៅថ្ងៃចុងក្រោយ នួន ជា និង ខៀវ សំផន ត្រូវបានផ្ដល់ឱកាសឡើងថ្លែងសុន្ទរកថាការពារខ្លួន និងដើម្បីបញ្ជាក់ពីភាពគ្មានជាប់ពាក់ព័ន្ធរបស់ខ្លួនទៅនិងបទចោទមកលើខ្លួន ។ ខៀវ សំផន បានថ្លែងថា «ខ្ញុំមិនដែលបានចូលរួមធ្វើផែនការដែលនាំបង្កឲ្យមានទុក្ខវេទនាទាល់តែសោះ គឺមិនដែលទាល់តែសោះ មិនដែលទាល់តែសោះ» ។ ចំណែក នួន ជា វិញ បានចំណាយពេលជិតពីរម៉ោងដើម្បីអានសុន្ទរកថាដែលបានសរសេរទុកជាមុនរួចហើយ ។

## ខែវិច្ឆិកា

តុលាការយុត្តិធម៌អន្តរជាតិ បានប្រកាសសាលដីកាទាក់ទង



នឹងជម្លោះដីជុំវិញប្រាសាទព្រះវិហារ ដោយសម្រេចថា ដីនៅជុំវិញបរិវេណប្រាសាទព្រះវិហារជាកម្មសិទ្ធិរបស់កម្ពុជា ហើយតម្រូវឲ្យកងទ័ពថៃដកចេញពីតំបន់នោះជាបន្ទាន់ ។ ភ្លាមៗក្រោយពីប្រកាសសាលក្រម បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅអតីតតំបន់ខ្មែរក្រហមនៅខេត្តឧត្តមានជ័យដើម្បីជួបសម្ភាសន៍ជាមួយអតីតយោធាខ្មែរក្រហមដែលធ្លាប់ឈរជើងនៅប្រាសាទព្រះវិហារ និងធ្លាប់ដឹងរឿងរ៉ាវទាក់ទងនឹងដីនៅជុំវិញប្រាសាទ ។

**ខែធ្នូ**



មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាសាធារណៈមួយនៅថ្ងៃទី១៧ ខែធ្នូ នៅវត្តកំពង់ហ្លួង ស្រុកអង្គរបុរី ខេត្តតាកែវ ដោយមានការចូលរួមពីសំណាក់សហព្រះរាជអាជ្ញាជាតិ ជា លាង និងសហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស់ គុំចាន់ ។ គោលបំណងនៃវេទិកានេះគឺដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋទូទៅជ្រាបព័ត៌មានអំពីដំណើរការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ សហព្រះរាជអាជ្ញាជាតិ ជា លាង បានរៀបរាប់ប្រាប់អ្នកចូលរួមអំពីការបង្កើតសាលាក្តីខ្មែរក្រហម រំពុកអំពីការកាត់ទោស កាំង ហ្គេចអ៊ាវ ហៅ ឌុច អស់មួយជីវិតនិងកិច្ចដំណើរការក្នុងករណី០០២ វគ្គទីមួយដែលទើបតែបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានកាលពីចុងខែតុលាកន្លងទៅ ។ សហព្រះរាជអាជ្ញាជាតិ ជា លាង បញ្ជាក់ថា សាលាក្តីខ្មែរក្រហមនេះគឺបង្កើតឡើងដើម្បីស្វែងរកយុត្តិធម៌សម្រាប់ទាំងអស់គ្នា ។ អ្នកចូលរួមបានបង្ហាញនូវក្តីបារម្ភអំពីភាពវ័យចំណាស់របស់ជនត្រូវចោទ នួន ជា និង ខៀវ សំផន ដោយខ្លាចក្រែងសាលាក្តីខ្មែរក្រហមមួយនេះមិនអាចបញ្ចប់កិច្ចដំណើរការរបស់ខ្លួនចប់ចុងចប់ដើម ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



# ប្រាសាទព្រះវិហារ ក្នុងពេលខ្មែរក្រហមគ្រប់គ្រង

ប្រាសាទព្រះវិហារត្រូវកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាកាន់កាប់ក្រោយពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៩៣ កងយោធាខ្មែរក្រហមវាយយកបានប្រាសាទព្រះវិហារ ហើយបន្តគ្រប់គ្រងរហូតដល់ឆ្នាំ១៩៩៨ ។

អតីតយោធាខ្មែរក្រហមដែលធ្លាប់បានដឹងរឿងរ៉ាវ និងធ្លាប់ឈរជើងនៅលើប្រាសាទព្រះវិហារបាននិយាយប្រវត្តិរបស់ខ្លួន ។

ជិន គឹមថុង អាយុ៦៤ ជាអតីតយោធានៅកងពល៨០១ និងជាអ្នកតំណាងម្នាក់ក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងការចរចារកសន្តិភាពក្នុងអំឡុងទសវត្សរ៍៩០ ។ គឹមថុង បាននិយាយថា គាត់បានទៅដល់ប្រាសាទព្រះវិហារក្រោយពេលភាគីខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៩ ។ គាត់បានឡើងទៅដល់ប្រាសាទនេះតាមផ្លូវចាស់ដែលខ្មែរក្រហមធ្លាប់ប្រើប្រាស់សម្រាប់ដឹកជញ្ជូនគ្រាប់ឡើងទៅលើភ្នំ ដែលផ្លូវនោះមានតែរទេះគោប៉ុណ្ណោះដែលអាចបរកាត់បាន ។ គាត់បន្តថា នៅអំឡុងពេលនោះមិនឃើញមានកងទ័ពរបស់ថៃមកឈរជើងនៅលើប្រាសាទព្រះវិហារទេ ចំណែកផ្លូវពីផ្ទះក្រហមមកប្រាសាទព្រះវិហារក៏មិនឃើញមានសង់ផ្លូវថ្មីដូចបច្ចុប្បន្នដែរ ។

ចាន់ ស៊ាន់ ហៅ សាន អាយុ៦៨ឆ្នាំ ជាអតីតប្រធានវរសេនាធំនៃកងពល៥០២ ។ ក្រោយឆ្នាំ១៩៧៩ គាត់បានប្តូរមកនៅកងពល៦១២វិញដោយឈរជើងនៅជិតបឹងទន្លេសាប ។ រហូតមកដល់ឆ្នាំ១៩៨៨ទើបគាត់បានផ្លាស់មកនៅជួរភ្នំដងរែក ។



ប្រាសាទព្រះវិហារ ដែលបានក្លាយជាបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូ កាលពីខែកក្កដា ឆ្នាំ២០០៨ ។

គាត់បាននិយាយថា តាម៉ុក បានឈូសឆាយនិងធ្វើផ្លូវតាមបណ្តោយភ្នំដងរែកពីតំបន់អន្លង់វែងរហូតទៅដល់ផ្លូវឡើងទៅលើប្រាសាទព្រះវិហារចាប់តាំងពីឆ្នាំ១៩៩១ ដោយមិនមានភាគីថៃមកហាមឃាត់ទេ ។ ប៉ុន្តែនៅឆ្នាំ១៩៩៣ ពេលគាត់មកឈរជើងនៅលើប្រាសាទព្រះវិហារ គាត់បានឃើញកងទ័ពថៃមកបោះទីតាំងនៅមុំដុះក្រហម ប៉ុន្តែផ្លូវពីដុះក្រហមមកជើងប្រាសាទព្រះវិហារជាផ្លូវថ្ម មិនមែនជាផ្លូវកៅស៊ូដូចសព្វថ្ងៃនេះទេ ។ គាត់អះអាងទៀតថា ផ្លូវកៅស៊ូនេះធ្វើឡើងដោយថៃនៅពេលរាជរដ្ឋាភិបាលកម្ពុជាសហការជាមួយថៃ ដើម្បីបើកច្រកឲ្យភ្ញៀវទេសចរណ៍ចូលមកទស្សនាប្រាសាទព្រះវិហារតាមប្រទេសថៃ ។ ចំណែកនៅមុំវាលឥន្ទ្រី និងនៅលើប្រាសាទព្រះវិហារមិនមានកងទ័ពថៃមកឈរជើងទេ ។ ប៉ុន្តែ កងទ័ពថៃអាចមកលេងប្រាសាទព្រះវិហារ និងធ្វើទំនាក់ទំនងជាមួយយោធាខ្មែរក្រហមបានហើយវត្តកែវសិក្ខាគិរីស្វរក៏ពុំទាន់កសាងដែរនៅពេលនោះ ។

អែម សារិន អាយុ៦៦ឆ្នាំ ជាអតីតសមាជិកគណៈតំបន់ស្វយ័តក្របេះ ទទួលបន្ទុកមន្ទីរតំបន់ ។ ក្រោយមក គាត់ជាយោធានៅតំបន់មុំបី ជាប់ព្រំប្រទល់ប្រទេសឡាវ ថៃ និងកម្ពុជា ឬតំបន់ ១០០១ (មានទីតាំងស្ថិតនៅតាមបណ្តោយជួរភ្នំដងរែក) របស់ខ្មែរក្រហម ។ ក្រោយមកគាត់ជាអភិបាលរងស្រុកត្រពាំងប្រាសាទ ។ គាត់បាននិយាយថា "នៅជំនាន់ តាម៉ុក ដឹកនាំ តាម៉ុក មិនដែលធ្វើផ្លូវចូលទៅក្នុងទឹកដីរបស់ថៃទេសូម្បីតែបន្តិច ។ គាត់ក៏មិនដែលបញ្ជាឲ្យធ្វើចូលទៅដីគេ (ថៃ) ដែរ ។ គាត់ធ្វើទៅតាមខ្សែបន្ទាត់ព្រំដែន និងដែនទីដែលមានរាងជាធ្មេញរណា ដូចជាផ្លូវនៅច្រកជាំស្រុកអន្លង់វែង ។ គាត់បានហៅថៃឲ្យយកគ្រឿងចក្រមកជួយធ្វើផ្លូវដែលមានស្នាមកាយថ្មរហូតមកដល់សព្វថ្ងៃ ។

អ៊ិន ហឿន អាយុ៦៣ឆ្នាំ ជាអតីតប្រធានកងពល៦១២ របស់ខ្មែរក្រហមបានអះអាងថា កងទ័ពថៃបានមកឈរជើងនៅខាងជើងដុះក្រហមតាំងពីឆ្នាំ១៩៨១ ដែលកាលនោះមានមេបញ្ជាឈ្មោះ ណារ៉ុង តាមគាត់ដឹងសព្វថ្ងៃពាក់ផ្កាយ ។ គាត់បានបន្តថាថៃមកឈរជើងនៅដុះក្រហមនេះដើម្បីការពារទឹកដីរបស់ខ្លួន ។

ស្របគ្នានេះ វឿង ស៊ិន អាយុ៥៨ឆ្នាំ ជាអតីតប្រធានវរសេនាតូច១២ កងពល៦១៦ របស់ខ្មែរក្រហមមានប្រសាសន៍ថា "ថៃបានមកបោះទីតាំងនៅដុះក្រហម ភាសាថៃហៅថា ម៉ោយដែង តាំងពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨២ ដែលពេលនោះកងទ័ពរដ្ឋាភិបាលភ្នំពេញ និងវៀតណាម បោះទីតាំងនៅលើប្រាសាទព្រះវិហារ ។ ចាប់ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩២ ទើបកងទ័ពខ្មែរក្រហមវាយយកបាន ដែលពេលនោះកងទ័ពថៃបានឈរជើងនៅមុំដុះក្រហម ។

ចំណែក វ៉ាន់ កុសល ជាអតីតអភិបាលស្រុកត្រពាំងប្រាសាទ និងអនុប្រធានកងពល៦១២ របស់ខ្មែរក្រហមបានអះអាងថា កងពលរបស់លោកវាយយកប្រាសាទព្រះវិហារបានពីកងទ័ពរដ្ឋាភិបាលកម្ពុជានៅខែកក្កដា ឆ្នាំ១៩៩៣ រួចហើយបានបិទច្រកជាមួយថៃ ។ នៅពេលនោះ គាត់ក៏បានឃើញកងទ័ពថៃនៅឈរជើងនៅដុះក្រហម ។ ថៃបានយកពយ (ប្រាំងចោទនៅមុំដុះក្រហម) ធ្វើជាកន្លែងឃ្លាំមើល ហើយផ្លូវពីដុះក្រហមមកប្រាសាទព្រះវិហារនៅជាផ្លូវដីក្រហម ។ ចំណែកផ្លូវឡើងទៅលើប្រាសាទព្រះវិហារ តាម៉ុក បានបញ្ជាឲ្យឈូសឆាយធ្វើនៅឆ្នាំ១៩៩៧ ។ គាត់បានឈរជើងនៅលើប្រាសាទព្រះវិហាររហូតដល់សមាហរណ៍កម្មឆ្នាំ១៩៩៨ ទើបប្រគល់មកឲ្យខាងភាគីរាជរដ្ឋាភិបាលគ្រប់គ្រងវិញ ។ ប៉ុន្តែទោះបីយ៉ាងណាគាត់បានអះអាងថា ដុះក្រហម និងផ្លូវកៅស៊ូសព្វថ្ងៃ បានសង់នៅលើខ្សែបន្ទាប់ព្រំដែន ព្រោះគាត់ធ្លាប់បានដឹងតាមដែនទីរបស់មេបញ្ជាការរបស់គាត់ អ៊ិន ហឿន ។

ទោះបីការអះអាងខាងលើមិនស្របគ្នា និងមិនមែនជាភស្តុតាងផ្លូវច្បាប់ក៏ដោយ ក៏អតីតយោធាខ្មែរក្រហមទាំងអស់ដែលរស់នៅតាមបណ្តោយព្រំដែននៅតែអះអាងពីភាពត្រឹមត្រូវចំពោះទឹកដីដែលខ្លួនធ្លាប់ឈរជើង និងគ្រប់គ្រង ។ **សោម ប៊ុនថន**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# ថ្ងៃបញ្ចប់កិច្ចពិភាក្សាដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ទិដ្ឋភាពនាពេលព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ នៅក្នុងបរិវេណសាលាក្តីខ្មែរក្រហមមានសភាពកុះករ ខណៈពេលដែលដំណើរការនីតិវិធីក្នុងករណីសំណុំរឿង០០២/០១ កំពុងត្រូវបានរៀបចំឲ្យធ្វើការបញ្ចប់ការសួរដេញដោលនៅថ្ងៃបិទបញ្ចប់ ។ សវនាការចាប់ផ្តើមនៅវេលាម៉ោងប្រាំបួនព្រឹក ។ ជាកិច្ចចាប់ផ្តើម លោកប្រធានអង្គជំនុំជម្រះ និល ណុន បានផ្តល់វេទិកាជូនសហមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ។ ដោយមានការទាមទារឲ្យបកស្រាយផ្ទាល់ជាជាងការបកស្រាយតាមប្រព័ន្ធអេឡិចត្រូនិកពីចម្ងាយ នួន ជា ដែលមានអាយុ៨៧ឆ្នាំ បានមកកាន់បន្ទប់សវនាការផ្ទាល់ដើម្បីធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលផ្នែកសំណុំរឿង០០២/០១ ចុងក្រោយជាប្រវត្តិសាស្ត្រនេះ ។

### នួន ជា ប្រកាសថាខ្លួនគ្មានទោសកំហុស

មិនយូរប៉ុន្មានបន្ទាប់ពីមនុស្សម្នាដ៏ច្រើនកុះករចូលអង្គុយក្នុងបន្ទប់សវនាការ និងបន្ទប់សារព័ត៌មានដើម្បីតាមដានដំណើរការកាត់ក្តី នួន ជា បានពោលខ្លាំងៗថា “តាមរយៈសវនាការនេះបានបញ្ជាក់ប្រាប់យ៉ាងច្បាស់ថា ខ្ញុំមិនមានការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដូចលោកលោកស្រីសហព្រះរាជអាជ្ញាបានចោទប្រកាន់នោះទេ ។ និយាយឲ្យខ្លីទៅ ខ្ញុំមិនមានទោសអ្វីទាក់ទងទៅនឹងការចោទប្រកាន់ដូចបានលើកឡើងនោះទេ” ។

បន្ទាប់មក នួន ជា បានចំណាយពេលប្រហែលជាជិតមួយម៉ោងដើម្បីធ្វើការបកស្រាយ មុននឹងគាត់ដល់ពេលវេលាសម្រាកដោយសារបញ្ហាសុខភាពរបស់គាត់ ។ នួន ជា ចាប់ផ្តើមបកស្រាយទាំងកំហឹងលើដំណើរការនីតិវិធីតុលាការជុំវិញការកាត់ក្តីលើរូបគាត់ ។ គាត់លើកឡើងថា “តាមផ្លូវច្បាប់ គោលបំណងនៃការបង្កើតតុលាការនេះគឺមានទិសដៅ និងតួនាទីដើម្បីស្វែងរកការពិត និងយុត្តិធម៌ឲ្យខ្ញុំ និងជនរងគ្រោះតាមរយៈភស្តុតាងរឹងមាំ ស្របច្បាប់ និងអាចឲ្យជឿបាន ។ ផ្ទុយទៅវិញ មកដល់ពេលនេះ លោកលោកស្រីសហព្រះរាជអាជ្ញា មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបំពេញធាតុផ្សំបទល្មើសដែលបានចោទប្រកាន់ដាក់បន្ទុកមកលើរូបខ្ញុំ ហើយសិទ្ធិស្របច្បាប់របស់ខ្ញុំមួយចំនួនក៏មិនបានធានាត្រឹមត្រូវនៅក្នុងតុលាការនេះផងដែរ ដូចជាសិទ្ធិទទួលបានការកាត់សេចក្តីឲ្យបានឆាប់រហ័ស សិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ សិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិផ្សេងៗទៀត ដែលធានាដោយច្បាប់ជាតិនិងអន្តរជាតិ” ។

ក្នុងរយៈពេល៤៥នាទីបន្ទាប់មកទៀត នួន ជា បានរៀបរាប់ពីតួនាទីនិងសកម្មភាពរបស់ខ្លួនក្នុងបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសអំឡុងពេលពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ នួន ជា បានរៀបរាប់ថា “រូបខ្ញុំផ្ទាល់សូមបញ្ជាក់បន្ថែមនូវចំណុចសំខាន់ៗមួយចំនួនទៀតសម្រាប់ជាមូលដ្ឋានផ្តល់ជូនលោកលោកស្រីចៅក្រមជ្រាបឲ្យកាន់តែច្បាស់ចំពោះភាពគ្មានទោស និងសុចរិតភាពរបស់ខ្ញុំពាក់ព័ន្ធនឹងបទចោទប្រកាន់មកលើខ្ញុំ” ។ ក្រោយមក នួន ជា បានបន្ថែមទៀតថា “អ្វីដែលខ្ញុំនិយាយ គឺសុទ្ធសឹងតែជាការពិត” ។ នួន ជា បានបកស្រាយដោយលើកយកហេតុផលមកសម្អាងមួយចំនួនតទៅ ៖

◆ គាត់មិនមានអំណាចអ្វី និងមិនមានការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលកើតមានឡើងនៅក្នុងរបបប្រជាធិបតេយ្យនោះទេ ។ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តួនាទីចម្បងរបស់គាត់ដែលជាអនុលេខាបក្សទទួលខុសត្រូវខាងឃោសនាអប់រំអំពីគោលនយោបាយនៅក្នុងជួរសមាជិកបក្ស ។ គាត់និយាយថា “ខ្ញុំមិនដែលឃោសនាអប់រំឲ្យសមាជិកបក្សប្រព្រឹត្តអំពើអាក្រក់ដូចជាប្រើអំណាចអាជ្ញា ឬមានអាកប្បកិរិយាមិនល្អចំពោះប្រជាជននោះទេ ។ ខ្ញុំបានអប់រំឲ្យសមាជិកបក្សកុម្មុយនីស្តកម្ពុជា បេះគោរពប្រជាជន ស្រឡាញ់ប្រជាជន បម្រើប្រជាជននិងប្រទេសជាតិរបស់ខ្លួន ។ ខ្ញុំមិនដែលអប់រំ ឬណែនាំសមាជិកបក្សកុម្មុយនីស្តកម្ពុជាណាម្នាក់ឲ្យធ្វើបាបកាប់សម្លាប់ បង្អត់អាហារប្រជាជន ឬប្រល័យ

ពូជសាសន៍ណាម្ដងទេ ។ ខ្ញុំតែងតែលើកយកគោលការណ៍សំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជាមកបង្រៀន និងអប់រំដល់សមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងទិសដៅធ្វើយ៉ាងណាឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាទាំងអស់អនុវត្តការងារ និងបម្រើប្រជាជនឲ្យបានល្អប្រសើរ» ។ បន្ទាប់មក នួន ជា បានលើកយកគោលការណ៍ដែលមានចែងនៅក្នុងមាត្រា២នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងនោះ គាត់បានរៀបរាប់ថា «ខ្ញុំតែងតែអប់រំឲ្យសមាជិកបក្សទាំងអស់កុំប្រើអំណាចអាជ្ញា កុំស្រី កុំស្រា កុំពុករលួយនិងកុំលេងល្បែងស៊ីសង ។ល ។ ជាពិសេសឲ្យបេះសាមគ្គីគ្នា ទាំងក្នុងជួរបក្ស និងមហាជន... ។ និយាយឲ្យខ្លីទៅអ្វីដែលខ្ញុំបានអប់រំនិងបង្រៀនដល់សមាជិកបក្ស និងកងទ័ពនោះគឺជាការបណ្ដុះពុទ្ធិឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាត្រូវមានឆន្ទៈស្នេហាជាតិ ការពារជាតិ និងស្រឡាញ់ប្រជាជន និងសាមគ្គីភាពផ្ទៃក្នុងល្អក្នុងទិសដៅការពារនិងកសាងប្រទេសជាតិមួយឲ្យបានរីកចម្រើនរុងរឿង និងឯករាជ្យពិតប្រាកដហើយមិនអនុញ្ញាតឲ្យប្រទេសណាមួយ ធំក្ដី តូចក្ដី ជិតក្ដី ឆ្ងាយក្ដី ឈ្លានពាន និងធ្វើអាណានិគមមកលើប្រទេសកម្ពុជាបានជាដាច់ខាត» ។

◆ នួន ជា ក្នុងឋានៈជាអនុប្រធានគណៈកម្មាធិការទំនាក់ទំនងចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាមានតួនាទីកសាងទំនាក់ទំនងជាមួយនឹងបក្សកុម្មុយនីស្តក្នុងប្រទេសវៀតណាមដោយសារតែលេខាបក្ស ប៉ុល ពត មានកិច្ចការរវល់ច្រើន ។ «នៅពេលខ្ញុំចូលបម្រើចលនាបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៥០គឺមានវត្តមានកងទ័ពវៀតណាម វៀតកុង នៅទូទាំងប្រទេសកម្ពុជារួចជាស្រេចទៅហើយ ។ សមាសភាពនេះបានបង្កប់ខ្លួននៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជាទាំងនៅក្នុងជួរកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងថ្នាក់ដឹកនាំស៊ីវិលកម្ពុជា និងក្នុងប្រជាជនកម្ពុជា» ។

◆ នួន ជា សហការជាមួយក្រុមអ្នកបង្កើតបក្សកុម្មុយនីស្តឯករាជ្យដំបូងគេរបស់ប្រទេសវៀតណាម ។ គាត់បានលើកឡើងថា «នៅឆ្នាំ១៩៦៤ ប៉ុល ពត បានរំដោះបក្សចេញពីការគ្រប់គ្រងចាត់ចែងពីវៀតណាម ។ ប៉ុល ពត និងសមាជិកមជ្ឈិមបក្សមួយ



នួន ជា (ឆ្វេង) ពេលកំពុងបណ្ដុះបណ្ដាល និងបង្រៀនសមាជិកបក្សកុម្មុយនីស្តអំពីគោលនយោបាយបក្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជួរទីមួយរាប់ពីឆ្វេង គឺ វ៉ន វ៉េត, តាម៉ុក, មិនស្គាល់ និង កែ ពក ។ ជួរទីពី ខៀវ សំផន, មិនស្គាល់, អៀង សារី និង សុន សេន ។

ចំនួនបានទៅកសាងមូលដ្ឋានបង្អែករបស់ខ្លួនដែលមានឈ្មោះថា “មន្ទីរ១០០” ។ ក្រោយមក មន្ទីរនេះបានចល័តទៅខេត្តរតនគិរី ។ ពេលនោះ ការិយាល័យនោះមិនទាន់មានសេរីភាពពេញលេញទេ ។ វៀតណាមដែលមានមូលដ្ឋានសឹកនៅភូមិភាគ៥នៃប្រទេសវៀតណាមបានខំរកគ្រប់វិធីដើម្បីក្តោបក្តាប់បក្សកុម្មុយនីស្តកម្ពុជាគ្រប់ពេលវេលា ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធា ។ នួន ជា រំឭកទៀតថា “នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលធ្វើឡើងដោយចក្រពត្តិអាមេរិក និងបនក្បត់ជាតិ លន់ នល់, សិរីមតៈ និង សឺង ង៉ុកថាញ់ ។ នៅពេលនោះហើយ កងទ័ពប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើងហើយរីកចម្រើនធំធាត់យ៉ាងឆាប់រហ័ស ។ នៅពេលនោះដែរ វៀតណាមបានជ្រើសរើសខ្មែរមួយចំនួនប្រហែលបីពាន់នាក់ឲ្យទៅរៀនសូត្រនិងទទួលការបំពាក់បំប៉នទាំងផ្នែកបច្ចេកទេស នយោបាយ និងសតិអារម្មណ៍នៅប្រទេសវៀតណាមខាងជើង ។ នៅពេលពួកគេត្រឡប់មកប្រទេសកម្ពុជាវិញនៅពាក់កណ្តាលឆ្នាំ១៩៧៣ អ្នកទាំងនោះត្រូវបានចាត់តាំងឲ្យបម្រើការងារនៅក្នុងជួរបក្សនិងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ។ ទោះជាយ៉ាងនេះក្តី នួន ជា បន្តទៀតថា “បក្សកុម្មុយនីស្តកម្ពុជាក្រោមការខិតខំរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្សបានអនុវត្តនូវគោលការណ៍ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង” ។

បន្ទាប់មកទៀត នួន ជា ប្រាប់ថា “បក្សកុម្មុយនីស្តកម្ពុជាបានរកឃើញថា វៀតណាមបានបង្កប់ភ្នាក់ងាររសម្ងាត់របស់គេនៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងគោលបំណងបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា សម្លាប់ប្រជាជន និងលេបយកទឹកដីនៃប្រទេសកម្ពុជា ដែលវៀតណាមមានមហិច្ឆតាជាយូរមកហើយ ។ ប្រទេសវៀតណាមបានគ្រប់គ្រងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩១ នៅពេលប្រទេសកម្ពុជាមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១” ។

## ជាការពិតទេដែលថាកំហុសអាស្រ័យលើវៀតណាម

សម្តីរបស់ នួន ជា ទំនងជាបញ្ចុះបញ្ចូលឲ្យតុលាការជឿថា



នួន ជា (ស្តាំ) អង្គុយជាមួយ ប៉ុល ពត នៅក្នុងព្រៃក្នុងអំឡុងសង្គ្រាមស៊ីវិល

គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមិនបានបង្អត់អាហារ និងសម្លាប់ប្រជាជាជនទេ ។ ហើយសម្អាងលើហេតុផលនេះ នួន ជា បាននិយាយថា "ខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាមានការឈឺចាប់ណាស់នៅពេលដែលខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាបានដឹងថាបក្សកុម្មុយនីស្តកម្ពុជាចាញ់ល្បិចកលវៀតណាម ដែលធ្វើឲ្យប្រជាពលរដ្ឋខ្លួនស្លាប់ ហើយប្រទេសជាតិធ្លាក់ចូលទៅក្នុងភាពអន្តរាយបែបនេះ" ។

នួន ជា បន្តបកស្រាយថា "កិច្ចការការពារជាតិ និងការបញ្ជាកម្លាំងប្រយុទ្ធបានធ្លាក់ទាំងស្រុងទៅលើ សុន សេន ដែលជារដ្ឋមន្ត្រីនៃក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ។ ពេលនោះហើយ ដែលតួនាទីរបស់ខ្ញុំក្នុងគណៈកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម (គណបក្សកុម្មុយនីស្តវៀតណាម) ត្រូវបានបញ្ចប់ទាំងស្រុង" ។ នួន ជា បានប្រាប់ថា "តាមផ្លូវច្បាប់នៅក្នុងតួនាទីនេះ ខ្ញុំទទួលខុសត្រូវក្នុងការអនុម័តច្បាប់ ។ នៅពេលនោះ ដោយសារប្រទេសកម្ពុជាទើបតែចប់សង្គ្រាម ហើយក៏មានសង្គ្រាមបន្តជាមួយវៀតណាមទៀតនោះ ក្នុងរយៈពេលខ្លីបែបនេះ យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើច្បាប់ច្រើននោះទេ ។ ម្យ៉ាងវិញទៀត ដោយសារប្រទេសជាតិស្ថិតនៅក្នុងស្ថានភាពបែបនេះ កិច្ចការច្បាប់គឺមិនមែនជានិច្ចការជាអាទិភាពនោះដែរ" ។

នួន ជា ធ្វើការពន្យល់ពីទ្រឹស្តីនៃរបបកុម្មុយនីស្តនិងការដឹកនាំប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យថា "ក្នុងរបបកុម្មុយនីស្តមានបក្សដឹកនាំនិងរដ្ឋគ្រប់គ្រងប្រទេស ។ នៅក្នុងសម័យកាលនោះ បើទោះបីជាមានការបែងចែកអំណាចជាបីគឺ នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការដោយផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏វាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ។ ស្ថាប័ននីតិបញ្ញត្តិនិងតុលាការមិនបានដំណើរការពេញលេញទេ ។ ជាក់ស្តែងមានតែនីតិប្រតិបត្តិទេដែលបានដំណើរការងារពេញលេញ ហើយ ប៉ុល ពត បានទទួលដំណែងជានាយករដ្ឋមន្ត្រី ។ ដូច្នោះហើយ ប៉ុល ពត មានអំណាចជារួមក្នុងការដឹកនាំនិងគ្រប់គ្រងប្រទេស ទាំងនៅក្នុងជួរបក្ស និងនៅក្នុងរដ្ឋាភិបាល ដោយសារគាត់ជាលេខាបក្សនិងជានាយករដ្ឋមន្ត្រី ។ នៅក្នុងតួនាទីនេះ គ្មាននរណាម្នាក់អាចជំនួសគាត់បានឡើយ ។ ផ្អែកលើមូលដ្ឋាននេះបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានអំណាចអ្វីបន្តិចក្នុងការគ្រប់គ្រងនិងប្រតិបត្តិការងារនៃនីតិប្រតិបត្តិឡើយ " ។

នួន ជា បដិសេធចំពោះការចោទប្រកាន់លើមុខដំណែងផ្សេងទៀតថា "ខ្ញុំមានចម្ងល់យ៉ាងខ្លាំងចំពោះការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាថា ខ្ញុំធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទី ជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម និងមានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ទីរស-២១ ។ ការចោទប្រកាន់បែបនេះ បើទោះជាមានចេតនា ឬអចេតនាក៏ដោយ វាជាការនិយាយខុសពីការពិតទាំងស្រុង ហើយពុំមានភស្តុតាងជាក់លាក់ផងដែរ " ។

នួន ជា ថែមទាំងបានបដិសេធចំពោះការចោទថា គាត់ជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម បញ្ជាការលើកិច្ចការទាហាន ឬសន្តិសុខ ដោយរៀបរាប់ថា កិច្ចការទាំងអស់ សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់ ។ គាត់បន្ថែមថា "ខ្ញុំមិនដែលបានជួប មិនដែលគ្រប់គ្រងឬមិនបានបញ្ជា ឌុច ឲ្យធ្វើបាបឬសម្លាប់មនុស្ស



ប៉ុល ពត (អាវពណ៌ស) ពេលទទួលគណៈប្រតិភូវៀតណាមដឹកនាំដោយ ឡេ យន់ (ឆ្វេង)

នោះទេ ។ អស់លោកគួរតែជ្រាបហើយ សារជាតិជាទាហាន ឬសន្តិសុខ គឺមិនដែលស្តាប់អ្នកណាក្រៅពីមេបញ្ជាការផ្ទាល់របស់ខ្លួននោះទេ ។ ដូច្នេះ គ្មានហេតុផលអ្វីដែល ឌុច ស្តាប់ខ្ញុំនោះទេ ។ និយាយដោយត្រង់ទៅ ខ្ញុំទើបតែឮឈ្មោះ ឌុច នៅក្រោយឆ្នាំ ១៩៧៩ តែប៉ុណ្ណោះ» ។ គាត់បន្តបដិសេធលើអ្វីដែល ឌុច បានចោទប្រកាន់មកលើរូបគាត់សម្អាងថា អ្វីដែល ឌុច ចោទប្រកាន់ព្រោះចង់គេចពីការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ ។ នួន ជា លើកឡើងថា «ខ្ញុំមិនបានបំពេញកិច្ចការនេះទាល់តែសោះ ហើយក៏គ្មានឯកសារណាមួយដាក់លាក់បញ្ជាក់ពីរឿងនេះដែរ » ។

គោលបំណងរបស់គាត់ក្នុងការចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះគឺ «ចង់រំដោះប្រទេសជាតិពីអាណានិគមនិយមបារាំង និងការពារទឹកដី ការឈ្លានពានពីប្រទេសជិតខាងដែលពួកគេមានបំណងចង់លេបយកតាំងពីយូរយារណាស់មកហើយនោះទេ ។ ខ្ញុំស្រឡាញ់ប្រជាជនខ្ញុំ ខ្ញុំមិនមានបំណង និងចេតនាណាមួយធ្វើបាប កាប់សម្លាប់ ឬប្រល័យពូជសាសន៍ឯងនោះទាល់តែសោះ» ។

បង្វែរមកលើការចោទប្រកាន់នៅឯទួលពោធិ៍ជ្រៃវិញ នួន ជា បញ្ជាក់ម្តងទៀតអំពីការគ្មានភ័ស្តុតាងគ្រប់គ្រាន់នៅក្នុងបទចោទជាពិសេសគឺការសម្លាប់អតីតទាហាន លន់ នល់ ។ នួន ជា អះអាងថា «បើតាមខ្ញុំដឹង បក្សកុម្មុយនីស្តកម្ពុជាមិនដែលបានបង្កើតគោលនយោបាយឲ្យកងកម្លាំងរបស់ខ្លួនកាប់សម្លាប់អតីតទាហាន លន់ នល់ ឬប្រជាជនទេ ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះឈ្លើយសឹក គឺសន្តោសប្រណី និងលើកលែងទោសពីព្រោះអ្នកទាំងនោះត្រូវគេចាប់បង្ខំមកឲ្យធ្វើទាហានសម្រាប់មកប្រយុទ្ធស្លាប់ជំនួសគេ ហើយពួកគេជាកូនចៅរបស់ប្រជាជននៅក្នុងមូលដ្ឋានរំដោះរបស់បក្សកុម្មុយនីស្តកម្ពុជា» ។ បន្ទាប់មកទៀតគាត់រំឭកគុលាការអំពីការផ្តល់សក្ខីកម្មដែលពោរពេញដោយចំណុចមន្ទិលសង្ស័យ និងសក្ខីកម្មផ្ទុយគ្នាលើចំនួនទាហាន លន់ នល់ ដែលត្រូវបានសម្លាប់ ចំនួនឡានដឹកអ្នកទាំងនោះ និងទិដ្ឋភាពអ្នកដែលបានលួចចូលទៅមើលនៅពេលនោះ ។ គាត់ចាត់ទុកថា ចម្លើយសាក្សីទាំងនោះមិនអាចឲ្យជឿ និងយកជាការបានទេ និងថា «ពោរពេញទៅដោយការភូតកុហក» ។ ក្រៅពីនេះ គាត់បន្ថែមថា «ខ្ញុំសួរថា នៅពេលនោះ ក្នុងនាមជាអ្នកដឹកនាំម្នាក់ តើមានពេលវេលាឯណាសម្រាប់គិតគូរពីបញ្ហានេះ? ពួកយើងមានកិច្ចការរួមសំខាន់ៗនិងបន្ទាន់ជាច្រើននៅទីក្រុងភ្នំពេញ ជាពិសេសនៅអំឡុងពេលពីរឬបីខែដំបូង ។ បញ្ហាសំខាន់គឺដោះស្រាយជីវភាពរបស់ប្រជាជននិងការពារជាតិឲ្យផុតពីការប៉ុនប៉ងគ្រប់គ្រងពីបក្សកុម្មុយនីស្តវៀតណាម និងពីគូបដិបក្ខ» ។

## យុទ្ធសាស្ត្រប្រយុទ្ធ ការស្តីបន្ទោស និងខ្លួនក្រពើ

បន្ទាប់មកទៀត នួន ជា បានលើកយកព្រឹត្តិការណ៍នៃជ្រុងម្ខាងដែលធ្លាប់បានកើតឡើងមករៀបរាប់បន្តទៀតដើម្បីលាតត្រដាងពីអំពើហិង្សាមកលើកសិករក្រីក្រ និងជនស្លូតត្រង់នៅក្នុងខេត្តមួយក្នុងប្រទេសកម្ពុជា ។ នួន ជា បានអះអាងថា «សូមកុំភ្លេចថា មុនពេលសម្រេចចិត្តតស៊ូដោយអាវុធក្នុងបុព្វហេតុរំដោះប្រទេសជាតិ សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនជាច្រើនរូប ត្រូវបានគេលួចសម្លាប់ ចាប់ខ្លួន ធ្វើទារុណកម្មដោយគ្មានហេតុផល និងបាត់ខ្លួនជារៀងរាល់ថ្ងៃ» ។ គាត់ក៏បានរំឭកពីអំពើហិង្សាដែលកើតឡើងក្នុងសម័យអាណានិគមនិយមបារាំងជាងរយៈពេលជិតមួយទសវត្សរ៍ «ពួកគេបានរំលោភបំពានយកដីពីប្រជាកសិករដែលធ្លាប់បានរស់នៅទីនោះតកូនតចៅរាប់ជំនាន់មកហើយនោះ» ។ គាត់លើកឡើងពីការចាប់រំលោភស្ត្រី ការសម្លាប់ប្រជាជន និងទាហាន លន់ នល់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក និងព្រឹត្តិការណ៍ថ្មីៗនេះ ។ គាត់នៅតែមានការជឿជាក់ថា ហេតុអ្វីបានជាទង្វើទាំងអស់នោះមិនត្រូវរាប់បញ្ចូលថាជាអំពើប្រល័យពូជសាសន៍ ឬក៏បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ។ «នៅក្នុងឆ្នាំ១៩៧៩ វៀតណាមបានចូលឈ្លានពាន និងកាន់កាប់ប្រទេសកម្ពុជា ហើយនៅឆ្នាំបន្តបន្ទាប់មក ពួកគេបានបាញ់ផ្លោងដាក់ជំរំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ធ្វើឲ្យឆេះលំនៅដ្ឋាន ទ្រព្យសម្បត្តិ បាត់បង់ជីវិតមនុស្សរាប់សិបនាក់ ក្នុងនោះមានទាំងកុមារ ស្ត្រីភេទ មនុស្សចាស់ជរា និងជនពិការផងដែរ ។ តើនេះមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេឬ?»

ពេលខ្លះ នួន ជា នៅបន្តរក្សាគោលជំហររបស់ខ្លួនដើម្បីផ្សារ

ភ្ជាប់នឹងការពិត និងអ្វីដែលបានកើតឡើងជាប្រព័ន្ធ «បើចាត់ទុកការកាប់សម្លាប់គ្នាក្នុងពេលធ្វើសង្គ្រាមថាជាផែនការធ្វើឡើងជាប្រព័ន្ធ ហេតុអ្វីមិនចោទប្រកាន់លើគូបដិបក្ខម្ខាងទៀតនៃសង្គ្រាមផងទៅ? ជាការពិតណាស់ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើផែនការធ្វើសង្គ្រាមដើម្បីរំដោះប្រទេសជាតិពីភាពអន្តរាយ ។ យុទ្ធសាស្ត្រប្រយុទ្ធសម្រាប់សត្រូវ ពិតជាត្រូវបានប្រើប្រាស់ដើម្បីទទួលបានជ័យជម្នះ ។ ការធ្វើបែបនេះ ខ្ញុំគិតថា វាមិនមែនជាការខុសច្បាប់ទេ» ។ គាត់លើកយកប្រទេសចំនួនប្រាំ ដែលធ្លាប់ជួបនូវសង្គ្រាមស៊ីវិល ថាប្រទេសទាំងនោះសុទ្ធសឹងតែមានផែនការដើម្បីកម្ទេចសត្រូវរបស់ខ្លួនទៅវិញទៅមក ។

គាត់បន្ថែមថា «ប្រសិនបើតុលាការចាត់ទុកថា ការធ្វើផែនការប្រយុទ្ធនៅពេលធ្វើសង្គ្រាមរបស់ភាគីដើម្បីទទួលជ័យជម្នះជាចេតនាប្រព្រឹត្តបទល្មើសដូចលោកលោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់មែននោះ ម៉្លេះសមមេដឹកនាំនៃប្រទេសទាំងអស់នោះ មិនថា រាជរដ្ឋាភិបាល ឬក្រុមប្រឆាំងទេ ត្រូវតែយកមកកាត់ទោសដូចគ្នា ជាពិសេស សហរដ្ឋអាមេរិក វៀតណាម រួមទាំងមេដឹកនាំខ្មែរដទៃទៀតផង ។ កុំយកតែខ្លួនក្រពើមកកាត់ទោសតែក្បាល និងកន្ទុយ ទុកនៅដោយឡែករួចពីសំណាញ់ច្បាប់» ។

ចុងក្រោយ នួន ជា បង្វែរសំណួរវិញទៅលើផែនការប្រយុទ្ធគ្នា ឬកម្ទេចសត្រូវត្រូវបានបញ្ចប់នៅពេលបញ្ចប់សង្គ្រាម និងវិសាលភាពនៃការកាត់ទោសចំពោះតែអំពើទាំងឡាយណាដែលកើតឡើងក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

ជិតដល់ម៉ោង១០ព្រឹក មេធាវីការពារក្តីរបស់ នួន ជា ឈ្មោះ សុន អរុណ បានបង្អាក់ការធ្វើសេចក្តីសន្និដ្ឋានរបស់កូនក្តីខ្លួនដោយត្រូវនឹងពេលដែលគាត់ត្រូវសម្រាក ។ ប្រធានអង្គជំនុំជម្រះ និល ណុន ក៏ប្រកាសសម្រាកចាប់តាំងពីពេលនេះតទៅរហូតដល់ម៉ោង ១០:១៥នាទី ។

## ការបកស្រាយការសម្រេចចិត្តជម្លៀសចេញពីទីក្រុងភ្នំពេញ

នៅពេលត្រឡប់មកកាន់អង្គសវនាការវិញនៅម៉ោង ១០:១៥នាទីព្រឹក នួន ជា បន្តធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ ដោយលើកយកការជម្លៀសប្រជាជនជាប្រធានបទ ។ គាត់បានបដិសេធដោយបញ្ជាក់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមិនមែនធ្វើឡើងក្រោមការបង្ខិតបង្ខំទេ ។ គាត់លើកយកនូវហេតុផលលម្អិតចំនួនពីរនៃការជម្លៀសនេះ ទីមួយ ការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងបញ្ហាប្រឈមកង្វះស្បៀងអាហារនៅពេលប្រទេសមានសង្គ្រាម ។ គាត់រំឭកអ្នកស្តាប់ទាំងអស់គ្នាថា នៅពេលនោះ ប្រទេសកម្ពុជាមិនទាន់មានជំនួយពីបរទេសទេ ។

នួន ជា រៀបរាប់ថា «ស្ថិតនៅក្នុងកាលៈទេសៈបន្ទាន់បែបនេះ បានជាថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំផែនការជម្លៀសប្រជាជនឲ្យទៅតាមតំបន់ និងខេត្តណាដែលមានធនធានសេដ្ឋកិច្ច ស្រូវ អង្ករ អាចចិញ្ចឹមប្រជាជនបាន និងទាមទារឲ្យប្រជាជនចូលរួមក្នុងការបង្កបង្កើនផលដោយខ្លួនឯងសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ និងកសាងប្រទេសជាតិ» ។ គាត់បន្តថា គ្រប់លេខាភូមិភាគដែលជាសមាជិកគណៈមជ្ឈិមបក្ស បានចូលរួមកិច្ចប្រជុំនេះ «ពេលនោះខ្ញុំចាំបានថា គ្រាន់តែភូមិភាគពាយ័ព្យបានធានាទទួលយកប្រជាជនចំនួន ១លាន ៥សែននាក់ ហើយភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគកណ្តាល បានធានាទទួលយកប្រជាជនដែលនៅសេសសល់» ។ គាត់បន្ថែមទៀតថា ក្នុងផែនការនោះ គឺភូមិភាគនីមួយៗមានស្វ័យភាពក្នុងការជួយសម្រួលគ្នាទៅវិញទៅមកទាក់ទងនឹងការជម្លៀសនេះ «ទោះជាមានហេតុផលទាំងពីរនេះក្តី ការជម្លៀសប្រជាជននៅពេលនោះ ធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំ គ្មានប្រើអំពើហិង្សា ឬសម្លាប់ប្រជាជននោះទេ ។ ប្រការនេះត្រូវបានអនុវត្តតាមរយៈការពន្យល់ប្រជាជនឲ្យបានដឹងច្បាស់ពីស្ថានភាពគ្រោះថ្នាក់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុង និងតម្រូវការចាំបាច់នៃការដោះស្រាយជីវភាព និងកសាងប្រទេសដោយខ្លួនឯង» ។

នួន ជា បន្តថា នៅពេលនោះប្រជាជនបានយល់ពីស្ថានភាពគ្រោះថ្នាក់ និង «តម្រូវការចាំបាច់» របស់ប្រទេសជាតិ ជាពិសេសប្រជាជន «បានគាំទ្រនិងស្រឡាញ់បដិវត្តន៍» ។ ទាក់ទងនឹងចំណុចនេះគាត់សូមបំភ្លឺចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាថា «ចុះសហព្រះរាជអាជ្ញាធ្លាប់បានគិតទេថា ពួក លន់ នល់ បានបាញ់

ផ្លោងដោយកាំភ្លើងធំដែលសហរដ្ឋអាមេរិកផ្តល់ឲ្យអស់រាប់លាន គ្រាប់ និងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកច្រើន ជាងកន្លះលានតោន បំផ្លាញផ្ទះសម្បែង វត្តអារាម ទ្រព្យសម្បត្តិ ស្រែចម្ការ សត្វពាហនៈរបស់ប្រជាជន ។ ជាពិសេស បណ្តាលឲ្យស្លាប់មនុស្សរាប់សិបម៉ឺននាក់ មានទាំងចាស់ជរា ទាំងកុមារ ទាំងស្ត្រីភេទ តើនេះមិនមែនជាអំពើអមនុស្សធម៌ឬជាឧក្រិដ្ឋកម្មទេឬ» ?

បង្វែរទៅកាន់ការចោទប្រកាន់មួយវិញទៀត ចំពោះអ្វីដែលបានលើកឡើងអំពីកម្ពុជាប្រជាធិបតេយ្យជា «រដ្ឋទាសករ» ធ្វើឲ្យ នួន ជា បដិសេធទាំងស្រុងថា «នេះវាជារឿងមួយមិនអាចទទួលយកបានទេ ។ ខ្ញុំសូមជម្រាបជូនបងប្អូនជនរួមជាតិថាបក្សកុម្មុយនីស្តកម្ពុជាមិនមែនតស៊ូរំដោះប្រទេសកម្ពុជាក្នុងគោលបំណងដាក់ប្រជាជនកម្ពុជាជាទាសករ ដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ» ។ តាមគំនិតផ្ទាល់របស់គាត់ បក្សកុម្មុយនីស្តកម្ពុជារំដោះប្រជាជនពីទាសភាព ព្រោះបណ្តាលមកពីការចាក់ឫសយ៉ាងជ្រៅនៃអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គមកម្ពុជា ។ គាត់រៀបរាប់ពីពួកនាយទុនឆ្កៀតពេលដែលប្រជាជនមានទុក្ខលំបាក ទារបង់ពន្ធ និងការប្រាក់តាមទំនើងចិត្តនៅពេលដែលពួកគេខ្ចីបុលពួកនាយទុន ប្រឈមមុខនឹងការប្រាក់ហួសហេតុដែលនាំឲ្យប្រជាជនទាំងនោះគ្មានលទ្ធភាពសងបំណុល ហើយត្រូវបានម្ចាស់បំណុលរឹបអូសយកដីស្រែចម្ការ និងផ្ទះសម្បែង ដែលពេលនេះប្រជាជនទាំងនោះត្រូវបង្ខំចិត្តស៊ីឈ្នួលគេដើម្បីកាត់បំណុល ឬបង្ខំចិត្តឲ្យលក់កូនធ្វើជាខ្ញុំគេ ជីវភាពកាន់តែក្រទៅៗ ។ នួន ជា សង្កត់ធ្ងន់ថា គោលបំណងរបស់គាត់គឺកសាងប្រទេសជាតិឲ្យប្រជាជនរស់នៅស្មើភាពគ្នាក្នុងគោលជំហរឯករាជ្យ ម្ចាស់ការខ្លួនទីពឹងខ្លួន ហើយសម្រេចជោគវាសនាជាតិខ្លួនដោយខ្លួនឯង ។

## គម្រោងផែនការបួនឆ្នាំ ៖ បន្លែមជារៀងរាល់ថ្ងៃ

នួន ជា បន្តពិពណ៌នាលើស្ថានភាពដែលកម្ពុជានឹងប្រែក្លាយក្នុងអំឡុងពេលបួនឆ្នាំខាងមុខ ប្រសិនបើគម្រោងផែនការដែលរៀបចំឡើងដោយគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានេះអាចសម្រេចបាន ។ ការកសាងសង្គមនិយមតាមមាគ៌ា និងអនុវត្តតាមផែនការបួនឆ្នាំនេះបាន ប្រជាជនម្នាក់ៗនឹងទទួលបានផ្លែផ្កាដូចតទៅ «របបអាហាររបស់ប្រជាជនម្នាក់ៗចំនួន១៣ថាំង ឬ ១.៣១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ ។ ដូច្នេះ ប្រជាជនហូបគ្រប់គ្រាន់សម្រាប់ពីបីពេលទៅបួនពេលក្នុងមួយថ្ងៃ ។ ចំពោះម្ហូបគឺពីរមុខ មានសម្លទឹក និងសម្លគោក ។ លើសពីនេះ បានសម្រេចបន្ថែមលើរបបអាហារ នូវចំណី និងបង្អែមផ្សេងៗ ដោយផ្តល់ឲ្យបីថ្ងៃម្តង ក្នុងឆ្នាំ១៩៧៧ ។ ពីរថ្ងៃម្តង ក្នុងឆ្នាំ១៩៧៨ ហើយមួយថ្ងៃម្តង ចាប់ពីឆ្នាំ១៩៧៩តទៅ ។ ចំពោះការងារវិញគឺឲ្យប្រជាជនធ្វើការងារប្រាំបីម៉ោងក្នុងមួយថ្ងៃ និងឲ្យឈប់សម្រាកបីថ្ងៃក្នុងមួយខែ ។ នារីមានផ្ទៃពោះ និងឆ្លងទន្លេ ឲ្យឈប់សម្រាកពីរខែ ។ អ្នកជំងឺឲ្យឈប់សម្រាកតាមជាក់ស្តែង ។ លើសពីនេះ យើងបានរៀបចំបង្កើនគ្រឿងចក្រឲ្យកាន់តែច្រើនសម្រាប់សម្រាលទម្ងន់ការងារដោយកម្លាំងកាយផ្ទាល់របស់ប្រជាជន ។ នេះបង្ហាញថាគោលជំហរបក្សកុម្មុយនីស្តកម្ពុជាមិនបានបង្ខំឲ្យប្រជាជនធ្វើការយ៉ាងធ្ងន់ធ្ងរនោះឡើយ ។ ខ្ញុំនៅចាំបានថា មានថ្ងៃមួយខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តសៀមរាបកាត់តាមខេត្តកំពង់ធំនៅពេលយប់ ។

## នួន ជា ធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ដាក់កំហុសលើអ្នករាល់គ្នាមិនមែនរូបគាត់

នួន ជា បន្ទោសលើយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការជ្រើសរើសកម្មាភិបាលមួយចំនួនខុស មិនបានវែកញែកឲ្យដាច់នូវសត្រូវ ភ្នាក់ងារបង្កប់របស់វៀតណាម និងអាមេរិកដែលក្បត់បដិវត្តន៍ អ្នកដែលមិនធ្វើតាមផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា «បែរជានាំគ្នាកាប់សម្លាប់ និងធ្វើបាបប្រជាជនដោយការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំងតាមទំនើងចិត្តរបស់ខ្លួន ហើយលាក់បាំង និងរាយការណ៍ភូតកុហកមកមជ្ឈិមបក្ស ។ ពួកគេធ្វើគ្រប់វិធីដើម្បីធ្វើឲ្យប្រជាជនមានសតិអារម្មណ៍ថ្នាំងថ្នាក់ងាកមកប្រឆាំងនឹងបដិវត្តន៍បណ្តាលឲ្យបក្សកុម្មុយនីស្តកម្ពុជាចុះខ្សោយ ហើយសត្រូវបរទេសយកលេសថាមករំដោះប្រជាជនកម្ពុជា ដើម្បីឲ្យការឈ្លានពានរបស់គេក្លាយជាអំពើស្របច្បាប់» ។

នួន ជា និយាយថា «លោក លោកស្រីចៅក្រមត្រូវតែរំពឹងលើសក្ខីកម្មទាំងនេះ ទោះបីជាមានការរំខានពីអារម្មណ៍ផ្ទាល់ខ្លួនដើម្បីយុត្តិធម៌ ។ ដោយមើលឃើញពីភាពអយុត្តិធម៌បែបនេះ ទាំងរូបខ្ញុំ ក៏ដូចជាលោក ខៀវ សំផន បានសម្រេចចិត្តឈប់ផ្តល់

សក្ខីកម្មជូនតុលាការពីព្រោះយើងយល់ថា បើទោះជាយើងផ្តល់ចម្លើយជូនចៅក្រមក៏វាមិនមានន័យអ្វីដែរ ដោយហេតុថាចៅក្រមមានភាពលម្អៀង ហើយអ្វីដែលអនុវត្តនៅចំពោះមុខតុលាការនោះ វាគ្រាន់តែជាការបន្ត្រប់នីតិវិធី ឬបំពេញទម្រង់ឲ្យល្អមើលតែប៉ុណ្ណោះ» ។

នួន ជា ធ្វើការសន្និដ្ឋានដោយផ្អែកលើមូលដ្ឋានទាំងបីខាងលើយោងតាមភ័ស្តុតាងបង្ហាញថា «ខ្ញុំមិនបានធ្វើផែនការប្រព្រឹត្តបទល្មើស ខ្ញុំមិនបានជួយឧបត្ថម្ភ ឬលើកទឹកចិត្តជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើស ។ បើទោះជាខ្ញុំមានតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា ខ្ញុំមិនបានដឹងអំពីការប្រព្រឹត្តបទល្មើសនៅតាមមូលដ្ឋាននោះទេ ។ ទើបតែនៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបខ្ញុំបានដឹងអំពីអំពើក្បត់របស់មេដឹកនាំនៅតាមភូមិភាគ តំបន់ មូលដ្ឋានខ្លះដែលមានបំណងបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ហើយនៅពេលនោះ ខ្ញុំពិតជាគ្មានអំណាចក្នុងការទប់ស្កាត់អំពើក្បត់ទាំងនោះបានឡើយពីព្រោះខ្ញុំពុំមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំងយោធាឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ ។ ប្រសិនបើក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្ញុំពិតជាមានអំណាចដឹកនាំឬបានប្រព្រឹត្តដូចការចោទប្រកាន់នៅពេលនេះ ប្រាកដជាតុលាការដែលបង្កើតឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៧៩ ពិតជាកាត់ទោសខ្ញុំដូចជា ប៉ុល ពត និង អៀង សារី ទៅហើយ ពីព្រោះពេលនោះភ័ស្តុតាងនៃឧក្រិដ្ឋកម្មនៅបន្សល់ទុកថ្មីៗនៅឡើយ មិនបាច់រង់ចាំពេល៣៨ឆ្នាំដើម្បីកាត់ទោសខ្ញុំទេ ។ តែដោយសារដឹងថាខ្ញុំគ្មានអំណាចអ្វីនិងមិនបានប្រព្រឹត្ត ។ ទោះបីជាយ៉ាងណាខ្ញុំនៅតែសម្តែងនូវការសោកស្តាយជាទីបំផុត និងសូមទទួលខុសត្រូវផ្នែកសីលធម៌ចំពោះជនរងគ្រោះទាំងអស់ និងប្រជាជនកម្ពុជាទាំងមូលដែលបានទទួលរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាការពិតសម្រាប់ប្រវត្តិសាស្ត្រ ទាំងគោលនយោបាយ ទាំងមាគ៌ា និងទាំងផែនការរបស់ចលនាបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងក្នុងគោលបំណងតែមួយគត់គឺរំដោះប្រទេសជាតិនិងប្រជាជនឲ្យរួចផុតពីអាណានិគមនិយម ចក្រពត្តិនិយម និងការជិះជាន់កេងប្រវ័ញ្ចភាពក្រីក្ររកទីបំផុតគ្មានការជ្រៀតជ្រែក និងការឈ្លានពានពីប្រទេសជិតខាងពិសេសពីប្រទេសវៀតណាម ។ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយជាក់លាក់ គ្មានការភូតភរ គឺកសាងប្រទេសមួយស្មើភាពគ្នា និងប្រជាជនជាម្ចាស់ប្រទេសពិតប្រាកដក្នុងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង» ។

នួន ជា និយាយបន្ថែមទៀតអំពីសោកនាដកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសូមអភ័យទោសចំពោះជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូលថា «ខ្ញុំនៅតែប្រកាន់ជំហរទទួលខុសត្រូវលើផ្នែកសីលធម៌ចំពោះការគ្រប់គ្រងមិនបានជិតដល់ និងមិនបានគ្រប់ជ្រុងជ្រោយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធដល់ប្រជាជនដែលរងគ្រោះដោយគ្រប់យថាហេតុទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខ្ញុំឃើញច្បាស់ថា យុត្តិធម៌អាចប្រែប្រួលទៅតាមកាលៈទេសៈ តែសច្ចធម៌ជាអមតៈធម៌មិនប្រែប្រួលជាដាច់ខាត ។ ពពកខ្មៅមិនអាចបិទបាំងពន្លឺព្រះអាទិត្យបានទេ ។ យ៉ាងណាមិញ មនុស្សអគតិ អសីលធម៌ មិនអាចភូតភរកុហក និងបិទបាំងភ្នែកប្រជាជន និងមហាជនមិនឲ្យមើលឃើញនូវសច្ចធម៌នៃការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា និងការឧបត្ថម្ភគាំទ្ររបស់ប្រជាជន ស្នេហាសន្តិភាព និងយុត្តិធម៌លើសកលលោកបានឡើយ ។ អាស្រ័យហេតុនេះ ដោយផ្អែកលើភ័ស្តុតាង និងហេតុផលទាំងអស់ខាងលើនេះ និងជាពិសេសសេចក្តីសន្និដ្ឋានរបស់មេធាវីខ្ញុំ ខ្ញុំសូមសំណូមពរតុលាការមេត្តាសម្រេចឲ្យខ្ញុំបានរួចផុតពីបទចោទប្រកាន់ក្នុងសំណុំរឿងនេះ និងសូមដោះលែងខ្ញុំឲ្យមានសេរីភាពវិញទៅតាមផ្លូវច្បាប់ ។

### មេធាវី វីកទ័រ កូប៉េ បន្តដំណើរការនីតិវិធីធ្វើសេចក្តីសន្និដ្ឋានតបស្នាពចុងក្រោយ មុនបិទបញ្ចប់

នួន ជា បានធ្វើការបិទបញ្ចប់នៅវេលាម៉ោង១០ៈ៥០ព្រឹក ដោយចំណាយពេលពីរម៉ោងលើការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ហើយក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន មានបំណងចង់ខ្ចីពេលវេលាខ្លះដែលនៅសល់ តែមេធាវីការពារក្តី កូប៉េ របស់ នួន ជា បានប្រើពេលវេលាប្រមាណ៤៥នាទីក្នុងការធ្វើសេចក្តីសន្និដ្ឋានតបស្នាពចុងក្រោយ ។

ដូចអ្វីដែលមេធាវីការពារក្តីបានធ្វើរាល់ដងនៅពេលបិទ

បញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួន មេធាវី កូប៉េ បានលើកយកទន្សឹករណ៍របស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឆ្លើយតប ដោយចាប់ផ្តើមទៅនឹងការគ្រាប់តាមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃ្លារបស់សហព្រះរាជអាជ្ញាដែលហៅថា «រដ្ឋទាសករ» ។ មេធាវី កូប៉េ និយាយថា ឃ្លានេះហាក់បីដូចជា «ដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាបានបំភ្លឺមកបញ្ចាំងមុខយើងដូចជាភ្លើងណេអុងដូច្នោះដែរ ។ ហើយការប៉ុនប៉ងរបស់គាត់គឺចង់អះអាងថា ការធ្វើបែបនេះឆ្លុះបញ្ចាំងពីគោលបំណងរួមរបស់បក្សកុម្មុយនីស្តកម្ពុជា» ។ ប៉ុន្តែគាត់បដិសេធថា ការប្រើពាក្យនៅឃ្លានេះជាពាក្យស្លោកថា «រដ្ឋទាសករ» នោះមិនត្រឹមត្រូវទេ ហើយធ្វើឲ្យមានការភ័ន្តច្រឡំនោះដែរ ។ មេធាវី កូប៉េ លើកឡើងថា មិនត្រឹមត្រូវ និងមិនបានផ្អែកទៅលើភ័ស្តុតាងដែលស្ថិតនៅក្នុងបញ្ហា ត្រូវពិភាក្សានៅចំពោះតុលាការទេ ប៉ុន្តែមូលដ្ឋាននៅក្នុងចម្លើយសាក្សី និងភ័ស្តុតាងទាំងអស់នោះគឺស្ថិតនៅក្រៅវិសាលភាពនៃរឿងក្តី០០២/០១ ។ គាត់បន្ថែមថា ចម្លើយសារភាពរបស់សាក្សីត្រូវបានព្យាយាមដាក់បញ្ចូលតាម «ទ្វារក្រោយ» ដែលរំពុកពីលក្ខខណ្ឌសហករណ៍ ដើម្បីបង្ហាញពីបុគ្គលមួយចំនួនដែលត្រូវបានគេចាត់ទុកដូចជាទាសករ ប៉ុន្តែចម្លើយទាំងអស់ដែលត្រូវបានលើកឡើងនោះគឺជាការអះអាងក្រៅវិសាលភាពនៃរឿងក្តី០០២/០១ ។


មេធាវី វីកទើ កូប៉េ រូបថត អ.វ.ត.ក

មេធាវី កូប៉េ ធ្វើការបញ្ជាក់ម្តងទៀតថា អ្វីដែលគេលើកឡើងនេះគឺជាការអះអាងដើម្បីធ្វើឲ្យទ្រឹស្តីរបស់ខ្លួនឲ្យតុលាការជឿថាជាការពិតតែផ្អែកលើភ័ស្តុតាង ចំណុចនេះមិនមែនជាផ្នែកនៃសវនាការទេ ហើយគ្មានពាក់ព័ន្ធខ្លឹមសារដែលត្រូវលើកមកដែរ ។ ជាឧទាហរណ៍ គាត់បានសួរថា មានការស្លាប់មនុស្សពីរលាននាក់ផ្អែកទៅលើភ័ស្តុតាងដែលមិនបានដេញដោលគ្នាជាការត្រឹមត្រូវដែរឬទេ? នេះគ្រាន់តែជាឧទាហរណ៍មួយដែលបង្ហាញពីបទចោទមិនមែនជាផ្នែកនៃការជំនុំជម្រះនោះទេ ។ មេធាវីកូប៉េ បន្តទៀតថា ដូចគ្នាយ៉ាងដូច្នេះដែរ ការអះអាងដែលមិនស្ថិតនៅក្នុងវិសាលភាពក្នុងការដេញដោលនៅក្នុងតុលាការគឺមិនត្រូវបានគេយកមកជំនុំជម្រះទេ ។ ការចោទប្រកាន់ផ្សេងៗដូចជាកម្មាភិបាលខ្មែរក្រហមបានសម្លាប់ទារកហើយនិងអ្នកណាដែលពាក់វ៉ែនតានឹងត្រូវសម្លាប់ ។ មេធាវី កូប៉េ បកស្រាយថា «ការចោទបែបនេះមិនអាចផ្អែកទៅលើការសន្និដ្ឋានថាមានអំពើនេះកើតនៅក្នុងកម្ពុជាប្រជាធិបតេយ្យទេ ។ ការអះអាងបែបនេះគឺគ្មានភ័ស្តុតាងណាបញ្ជាក់មិនមានអ្នកណាបញ្ជាក់សាក្សីណាបញ្ជាក់ទេ ។ ការប្រើពាក្យខុសអំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងន័យនេះ អង្គជំនុំជម្រះគួរតែប្រានចោលការអះអាងនេះ» ។

បន្ទាប់មក មេធាវី កូប៉េ ធ្វើការឆ្លុះបញ្ចាំងអំពីការចោទប្រកាន់ដោយដើមបណ្តឹងរដ្ឋប្បវេណីដែលថាគាត់ការពារកូនក្តីរបស់គាត់ហើយគាត់បានធ្វើការចំអកឡកឡឺយទៅដើមបណ្តឹងរដ្ឋប្បវេណី ។ គាត់ថ្លែងបន្តទៀតថា មេធាវីការពារក្តីគឺមិនដែលបដិសេធការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ តាមពិតយើងបានផ្តល់សន្តានចិត្តដ៏ខ្លាំងទៅដល់ការឈឺចាប់របស់ដើមបណ្តឹងទាំងនោះ ។ មេធាវី កូប៉េ បញ្ជាក់ថា «ពួកគាត់បានយោងទៅលើសារណារបស់ខ្ញុំក្នុងការប៉ុនប៉ងបង្ហាញថា ការអះអាងរបស់យើងគឺនៅក្រៅវិសាលភាពនៃការពិតរបស់កម្ពុជាប្រជាធិបតេយ្យដោយបញ្ជាក់ថាយើងប្រើភាសា «ការជម្លៀស» និង «ការរំដោះ» ប្រជាជន យោងទៅលើរឿងប្រលោមលោករបស់ អូវែលលៀន **(Orwellian)** ថាជាភាសាថ្មីនោះ ។ ក្នុងករណីនេះ យើងរំពុកដល់ភាគីទាំងអស់ថាយើងប្រើពាក្យនេះជាបន្តបន្ទាប់ដោយភាគីទាំងអស់នៅក្នុងតុលាការនេះក្នុងការជំនុំជម្រះ ។ ពាក្យទាំងអស់នេះ ដកស្រង់ពីដីការដំណោះស្រាយដោយខ្លួនឯង ។ យើងបានបន្សល់ទុកនូវសារណារបស់យើងដែលមានការប្រើប្រាស់ភាសាយ៉ាងត្រឹមត្រូវ» ។

មេធាវី កូប៉េ បង្វែរចម្លើយតបទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញានិយាយអំពីភាពយុត្តិធម៌នៃការជំនុំជម្រះនេះ ។ សហព្រះរាជអាជ្ញាបញ្ជាក់ថា ក្នុងរយៈពេលពីរថ្ងៃនេះមេធាវីការពារក្តីពិតជាបានលើកឡើងនៅក្នុងទន្សឹករណ៍ផ្ទាល់មាត់ គឺអង្គ

ជំនុំជម្រះបង្ហាញពីការប្តេជ្ញាដើម្បីផ្តល់ការជំនុំជម្រះយុត្តិធម៌ និងថាការបំពានទៅលើការជំនុំជម្រះដោយយុត្តិធម៌នោះគឺត្រូវដោះស្រាយរួចហើយ ។ «តើនេះមកពីស្តង់ដាមានកម្រិតទាបឬ?» គាត់សួរទៅកាន់អង្គជំនុំជម្រះ ហើយគាត់ពោលថា «ចម្លើយទៅនឹងបញ្ហាដែលខ្ញុំសួរនេះ គឺថាពិតជាអ៊ីចឹងមែន» ។

## ការខូចខាតការជំនុំជម្រះដោយយុត្តិធម៌

មេធាវី កូប៉េ មានសេចក្តីក្រេវក្រោធចំពោះតុលាការដែលមិនគាំទ្រគាត់ក្នុងការកោះហៅសាក្សី ហេង សំរិន ដែលជាសាក្សីស្នូលនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ គាត់មិនត្រឹមតែជាសាក្សីស្នូលទេ តែជាថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ក្នុងពេលបច្ចុប្បន្នផង ។ មេធាវី កូប៉េ រៀបរាប់ថា មិនមាននរណាម្នាក់ឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តីថាតើហេតុអ្វីបានជាយើងមិនអាចកោះហៅ ហេង សំរិន ឲ្យមកធ្វើជាសាក្សីបាន ។ មេធាវី កូប៉េ លើកយកនូវហេតុផលជាច្រើនដែលអាចទៅរួច ប៉ុន្តែចុងក្រោយ បែរជានិយាយថា «លោក លោកស្រីចៅក្រម លោក ហេង សំរិន គឺដូចជាដំរីនៅក្នុងបន្ទប់មួយអ៊ីចឹង គឺថាយើងឃើញច្បាស់ទាំងអស់ទាំងសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមិនហ៊ានលើកយកមកនិយាយ ។ ហេតុអ្វីបានជាគេមិននិយាយអ្វីទាល់តែសោះអំពីគាត់បែបនេះ? យើងអាចឃើញមានមូលហេតុពីរ គេអាចយល់ស្របថាវត្តមានរបស់គាត់គឺមានសារសំខាន់ណាស់ដើម្បីការជំនុំជម្រះ ដោយយុត្តិធម៌មិនអាចទប់ទល់បាននឹងសក្ខីកម្មរបស់គាត់ ឬមួយក៏យើងមិនចាំបាច់សូម្បីតែបញ្ចេញឈ្មោះគាត់ក៏មិនចាំបាច់ដែរ» ។

មេធាវី កូប៉េ បន្តទៀតថា «ការជំនុំជម្រះនេះមានលក្ខណៈជានយោបាយមូលដ្ឋាន ។ ដំណើរការនីតិវិធីបែបនេះមិនអាចបំបែកចេញឲ្យដាច់ចេញពីច្បាប់និងនយោបាយនោះទេ ។ សាលាក្តីបែបនេះគឺអាចនឹងប្រើច្បាប់លាយជាមួយនឹងនយោបាយ ។ នេះជាទស្សនៈដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រនៃដំណើរការព្រហ្មទណ្ឌអន្តរជាតិជាយូរមកហើយ ។ តើអ្នកដែលឈ្នះនៅក្នុងសង្គ្រាមគប្បីតែកាត់ទោសដូចជាអ្នកចាញ់ដែរអាចមានឬទេ?»

សហព្រះរាជអាជ្ញាបានដាក់បញ្ចូល៤០ទំព័រជាការវិភាគប្រវត្តិសាស្ត្រក្នុងសារណារបស់ខ្លួន តែត្រូវមេធាវី កូប៉េ សួរថា «ប្រវត្តិសាស្ត្រជាអ្វី? ហេតុអ្វីបានជាអះអាងថាអំពើហិង្សារបស់បក្សកុម្មុយនីស្តកម្ពុជាមុនឆ្នាំ១៩៧៥មិនមានរៀបរាប់ពីការទម្លាក់គ្រាប់បែកអាមេរិកាំង? តើមានចម្លល់ទេអំពីចេតនារបស់បក្សកុម្មុនីស្តកម្ពុជាទាក់ទងទៅនឹងអំពើឃោរឃៅរបស់ខ្មាំងរបស់គេក្នុងចម្បាំងនោះដែរឬទេ? តើសហព្រះរាជអាជ្ញាអាចហ៊ានចោទប្រកាន់អ្នកទាំងឡាយនៅក្នុងប្រទេសទាំងនេះដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តគោលនយោបាយរបស់កូនក្តីខ្ញុំ? លោកប្រធាន លោក-លោកស្រីចៅក្រម គឺថាចម្លើយគឺគេនឹងឆ្លើយថា «ទេ» ។

មេធាវី កូប៉េ បន្តលើកយកករណី នួន ជា លើការសម្រេចចិត្តបដិសេធមិនដាក់ខ្លួនគាត់ឲ្យតុលាការសួរដេញដោល ។ មេធាវី កូប៉េ បានរំឭកឡើងវិញអំពីការភ័ន្តច្រលំពីសហព្រះរាជអាជ្ញាដែលបានបកស្រាយខុសនូវការលើកឡើងដែលថា ការជម្លៀសលើកទីពីរត្រូវបានធ្វើឡើងមេដឹកនាំ «ភូមិភាគក្រហម» តែតាមពិតយើងមិនដែលមេធាវីរបស់ នួន ជា មិនដែលបកស្រាយបែបនេះទេហើយវាមិនមានន័យអ្វីទាល់តែសោះ ។ មេដឹកនាំតំបន់ភូមិភាគទេជាអ្នកគ្រប់គ្រង ហើយមានសិទ្ធិអំណាចទៅលើការជម្លៀសនេះមិនមែនមេដឹកនាំភូមិភាគក្រហមទេ ។

## ប្រាំមួយចំណុចសំខាន់ៗ លើការពិភាក្សាអំពីទួលពោធិ៍ជ្រៃ

មេធាវី កូប៉េ បានលើកយកចំណុចចុងក្រោយអំពីទួលពោធិ៍ជ្រៃមកនិយាយជាដំណាក់ការតាមពេលវេលាកំណត់ដែលនៅសល់ ។ ចំណុចគោលសំខាន់ៗមានដូចខាងក្រោមៈ

◆ សហព្រះរាជអាជ្ញាមិនបានជំទាស់ និងមិនបានប្រឆាំងអ្វីទាំងអស់លើការមិនលើកឡើងទាក់ទងនឹងភ័ស្តុតាងផ្ទាល់ដែលថាមានគោលនយោបាយក្នុងការសម្លាប់ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ហើយក៏មិនបានប្រាប់អង្គជំនុំជម្រះថាវាមិនអាចទុកចិត្តបានទេ ។

◆ យោងទៅតាមការលើកឡើងរបស់មេធាវី កូប៉េ រូបថតពីរសន្លឹកជាភ័ស្តុតាងដែលបានបង្ហាញគឺមិនអាចយកជាការបានទេ ។ សារណារបស់យើងគឺថា សហព្រះរាជអាជ្ញាមិនបានបង្ហាញឲ្យបានត្រឹមត្រូវនិងគ្រប់គ្រាន់អំពីអត្ថិភាពនៃគោលនយោបាយដែលដឹកនាំដោយមជ្ឈិមនោះឡើយ ។

ណាមួយដែលថា មនុស្សបែបនេះ ឬថាក្រុមមនុស្សបែបនេះត្រូវបានសម្លាប់ជាប្រព័ន្ធនោះឡើយ ។

◆ ទ្រឹស្តីវណ្ណៈដែល ឌុច បានអះអាងថា អាននៅក្នុងទស្សនាវដ្តីទង់បដិវត្តគឺមិនមែនមានន័យថាជាការសម្លាប់នោះទេ ។ មេធាវី កូប៉េ អះអាងថា «ហេតុផលតែមួយគត់នេះ ក៏គ្រប់គ្រាន់ដើម្បីឲ្យអង្គជំនុំជម្រះបានចោទទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ» ។

◆ ការបញ្ចប់នូវការប្រយុទ្ធសង្គ្រាមស៊ីវិលបង្ហូរឈាមរយៈពេលមួយឆ្នាំ ។ ការសម្លាប់ដោយសងសឹកប្រហែលជាអាចកើតមាន ។

ការសន្និដ្ឋានចុងក្រោយរបស់មេធាវី កូប៉េ សំដៅលើការវិភាគរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹង រស់ ញឹម នៅក្នុងតួនាទីបក្សកុម្មុយនីស្តកម្ពុជា និងនៅក្នុងតួនាទីនៃអ្នកដឹកនាំមជ្ឈិមនៃអ្នកដឹកនាំទាំងមូល ។ មេធាវី កូប៉េ និយាយថា «ចំណុចសំខាន់គឺថា ខ្ញុំមិនអាចនិយាយឲ្យច្បាស់លើសពីនេះទេថា រស់ ញឹម មិនមែនគ្រាន់តែមេដឹកនាំភូមិភាគទេ ។ គាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍ បើផ្អែកទៅតាមការលើកឡើងរបស់ព្រះរាជអាជ្ញាគឺបានចូលរួមដូចគ្នានៅក្នុងការអនុវត្តរបស់គណៈមជ្ឈិមទាក់ទងទៅនឹងការអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំ ។ នួន ជា ជួប រស់ ញឹម ជារៀងរាល់បីខែម្តងនៅក្នុងភូមិភាគពាយ័ព្យ ។ ដូច្នេះសំណួរខ្ញុំគឺថា តើម៉េចដែរប្រសិនបើការពិតថា រស់ ញឹម ជួប នួន ជា? តើពួកគាត់អាចនិយាយអ្វីអំពីទំនាក់ទំនងនោះបានគ្រាន់តែជួបគ្នាប៉ុណ្ណឹង? ពាក្យសម្តីរបស់ អៀង សារី គឺថា "ភូមិភាគនីមួយៗគឺឯករាជ្យ សម្លាប់អ្វីតាមដែលខ្លួនចង់ធ្វើតាមដែលខ្លួនចង់» ។ ការពិតនោះគឺថា ចុងក្រោយគាត់ត្រូវគេសម្លាប់ ត្រូវគេបោសសម្អាតផងដែរ ។ ប្រសិនបើ នួន ជា អាចគ្រប់គ្រង រស់ ញឹម ដោយងាយស្រួលនោះ ហេតុអ្វីពួកគេគិតថាវាចាំបាច់ត្រូវប្រើប្រាស់កម្លាំងទាហានប្រឆាំងជាមួយ រស់ ញឹម នោះ»?

## មេធាវី វែកតែន សហមេធាវីការពារក្តី ខៀវ សំផន ធ្វើសេចក្តីសន្និដ្ឋាន

បន្ទាប់ពីសវនាការសម្រាកអាហារថ្ងៃត្រង់ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នៅរសៀលម៉ោង ១:៣០នាទី ដោយផ្តល់វេទិកាជូនដល់សហមេធាវីការពារក្តី ខៀវ សំផន ដើម្បីធ្វើសេចក្តីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោលតបចុងក្រោយ ។ ការលើកឡើងរបស់មេធាវី វែកតែន មានលក្ខណៈខ្លីដោយបញ្ជាក់ «យើងមិនបានឮអ្វីដែលធ្វើយុត្តិកម្មមកលើចម្លើយរបស់យើងកាលពីម្សិលមិញទេ ដូនដោយហេតុថា អំណះអំណាងដែលខាងម្ខាងទៀតបានលើកឡើងនោះមិនមានភាពពាក់ព័ន្ធ ។ ដោយសារយើងបានឆ្លើយតបទៅនឹងបញ្ហានេះអស់ហើយ នៅក្នុងសារណាបញ្ចប់របស់យើង ហើយនិងតាមការនិយាយនៅក្នុងសវនាការនេះផ្ទាល់តែម្តង» ។

មេធាវី វែកតែន បានលើកយកអំណះអំណាងមួយទៀតដែលស្ថិតនៅក្នុងវិសាលភាពរឿងក្តី «អំណះអំណាងរបស់យើងមិនមានប្រយោជន៍អីទេ មិនបាច់វែងឆ្ងាយទៀតទេ យើងបានឆ្លើយតបហើយ ផ្តល់អំណះអំណាងអស់ហើយ» ។

មានការលើកយកពីបញ្ហាបរិបទប្រវត្តិសាស្ត្រលើស្ថានភាពផ្សេងៗយកមកបកស្រាយ តែការបកស្រាយត្រូវបានបញ្ចប់យ៉ាងឆាប់រហ័ស ។

ទាក់ទងនឹងការជម្លៀសប្រជាជនលើកទីពីរ មេធាវី វែកតែន បាននិយាយម្តងហើយម្តងទៀតថា «ការពិតនៅពេលនោះគឺថា ខៀវ សំផន ស្ថិតនៅក្រៅប្រទេស ហើយមិនមានភស្តុតាងណាមួយបញ្ជាក់ថា ខៀវ សំផន បានចូលរួមក្នុងការអនុវត្តចលនានេះទេ (អំឡុងខែសីហា ឆ្នាំ១៩៧៥-១៩៧៦) ។

មេធាវី វែកតែន បញ្ចប់ការសន្និដ្ឋានឆ្លើយតបចុងក្រោយដោយលើកយកចំណុចមួយទៀតទាក់ទងទៅនឹងទម្រង់ទំនួលខុសត្រូវគឺសហឧក្រិដ្ឋកម្មរួម ។ គាត់រំឭកឡើងវិញនៅពេលដែលសហព្រះរាជអាជ្ញាស្នើឲ្យតុលាការអនុវត្តលក្ខណៈវិនិច្ឆ័យនៃទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម ។ ក្រៅពីហេតុផលទាំងអស់នេះដែលទាក់ទងនឹងវិសាលភាពនៃសំណុំរឿងនេះ មេធាវី វែកតែន រំឭកថាបើសិនជាយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតប្រភេទនៃទម្រង់ជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួមនេះដែលក្នុងទម្រង់នេះ (គឺកម្រិតនៃភស្តុតាងចាំបាច់ដើម្បីបង្ហាញចេតនាទាបជាងហ្នឹងនោះ) គឺថាមានមូលហេតុច្បាស់លាស់ និងមានបរិបទជាក់លាក់មិនមែនបង្កើតហ្នឹងមកដើម្បីធ្វើជាកាដូឲ្យពិភពលោកទេហើយនឹងឲ្យខាងសហព្រះរាជអាជ្ញានេះ ។ មូលហេតុហ្នឹងគឺថា ពិរុទ្ធជននៃ

សហឧក្រិដ្ឋកម្មរួមក្នុងទម្រង់ជាប្រព័ន្ធបង្កើតឲ្យចូលរួមក្នុងការបង្កើតជំរំប្រហារជីវិត ។ មេធាវី វ៉េកគែន បន្តថា "អ្វីដែលសហព្រះរាជអាជ្ញាស្នើអស់លោក-លោកស្រីចៅក្រមធ្វើនៅពេលថ្ងៃនេះគឺថាឲ្យអស់លោក-លោកស្រីចៅក្រមយល់ឃើញថា ប្រទេសកម្ពុជាជាជំរំប្រមូលផ្តុំមនុស្ស ។ ហើយសូមឲ្យអនុវត្តទម្រង់សហឧក្រិដ្ឋកម្មរួមនេះ ។ នេះមិនត្រឹមត្រូវទាល់តែសោះ ព្រោះថានៅក្នុងបរិបទដែលខ្ញុំបានលើកឡើងនេះហើយដែលថាយុត្តិសាស្ត្រនៃខស្សរាហកម្មឧក្រិដ្ឋកម្មរួមនេះត្រូវបានបង្កើតឡើង ។ អ្វីចឹងវាមិនត្រឹមត្រូវនឹងស្មារតីច្បាប់ទេចំពោះការយល់ឃើញដូច្នេះនោះ" ។

## ខៀវ សំផន ធ្វើសេចក្តីសន្និដ្ឋានបទបញ្ចប់កិច្ចពិភាក្សាតបចុងក្រោយ


មេធាវី វ៉េកគែន រូបថត អ.វ.ត.ក

មេធាវី វ៉េកគែន ធ្វើការសរុបសេចក្តីសន្និដ្ឋាននៅរសៀលវេលាម៉ោង ១:៤៥នាទី ហើយប្រគល់វេទិកានេះដល់កូនក្តីរបស់លោកគឺ ខៀវ សំផន ឡើងធ្វើសេចក្តីថ្លែងការណ៍ដែលមានរយៈពេលប្រមាណជាម្ភៃនាទី។ នៅវេលាម៉ោង ២:១០នាទីរសៀល ប្រធានអង្គជំនុំជម្រះ និល ណុន ធ្វើការប្រកាសបិទបញ្ចប់ការស្តាប់ និងការធ្វើសេចក្តីសន្និដ្ឋាន "ឥឡូវនេះដំណើរការនីតិវិធីសវនាការស្តាប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីលើសំណុំរឿង០០២/០១នៃសំណុំរឿង០០២បានចប់សព្វគ្រប់អស់ហើយ" ។ លោកប្រធានអង្គជំនុំជម្រះធ្វើការសរុបសេចក្តីសំណុំរឿង០០២/០១ ដូចតទៅៈ

◆ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការសវនាការជំនុំជម្រះលើអង្គសេចក្តីពិនិត្យភ័ស្តុតាងលើសំណុំរឿង០០២/០១ ដែលជាផ្នែកដំបូងនៃសំណុំរឿង០០២ ដែលមានជនជាប់ចោទចំនួនពីររូបគឺ នួន ជា និង ខៀវ សំផន ដែលត្រូវជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

◆ ដំណើរការសវនាការពិភាក្សាដេញដោល ពិនិត្យភ័ស្តុតាងបានចាប់ផ្តើមពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ចំណាយពេលអស់២១២ថ្ងៃ និងសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីចាប់ផ្តើមពីថ្ងៃទី១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ដែលចំណាយពេលវេលាអស់ដប់ថ្ងៃ។ គិតមកដល់នឹងពេលនេះ កិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីលើសំណុំរឿង០០២/០១ បានប្រព្រឹត្តទៅអស់រយៈពេលសរុប២២២ថ្ងៃ ។

◆ គិតចាប់តាំងពីពេលចាប់ផ្តើមសវនាការដេញដោយលើភ័ស្តុតាងរហូតមកទល់នឹងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១នេះ មានបុគ្គលចំនួន៩២រូបដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដែលក្នុងនោះរួមមាន អ្នកជំនាញចំនួនបីរូប សាក្សីចំនួន៥៧រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣២រូប ។ បន្ថែមលើនេះមានវេជ្ជបណ្ឌិតព្យាបាលចំនួនពីររូប និងអ្នកជំនាញវេជ្ជសាស្ត្រចំនួនពីររូបបានផ្តល់សក្ខីកម្មទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទផងដែរ ។

◆ នៅក្នុងអំឡុងពេលធ្វើសវនាការលើសំណុំរឿង០០២/០១ ភាគីនានាបានប្តឹងសុំជាលាយលក្ខណ៍អក្សរចំនួនជាង២៩០បណ្តឹង ហើយជាលទ្ធផលគឺមានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងសេចក្តីសម្រេចផ្ទាល់មាត់ជាង២៥០សេចក្តីសម្រេចដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូង ។

◆ ឯកសារចំនួនជាង៤.០០០ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកជាភ័ស្តុតាងនៅក្នុងសំណុំរឿង០០២/០១ ដែលសរុបទាំងអស់មានចំនួនប្រមាណ១៦៦៥០០ទំព័រ ដែលមានបីភាសា ។

ប្រធានអង្គជំនុំជម្រះ និល ណុន បង្ហាញពីការស្នើសុំរបស់ភាគីនានាក្នុងការលើកយកឯកសារសម្ភារជាច្រើនដើម្បីជាភ័ស្តុតាងនៅក្នុងដំណើរការនីតិវិធី ។ គាត់ក៏បានលើកយកទម្រង់ឯកសារផ្សេងៗជាច្រើនមកបង្ហាញដែរ ។ ហើយនាពេលនេះ ដំណើរការសវនាការលើអង្គសេចក្តីចំពោះសំណុំរឿង០០២/០១ ឃើញថាបានចប់សព្វគ្រប់ហើយ ។ មុននឹងប្រកាសបិទសវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល លោក និល ណុន

តំណាងឲ្យអង្គជំនុំជម្រះសាលាដំបូង សូមថ្លែងអំណរគុណចំពោះគ្រប់ភាគីទាំងអស់ដែលបានមកចូលរួមដំណើរការសំណុំរឿងនេះ ។ គាត់ក៏សូមថ្លែងអំណរគុណទៅដល់សក្ខីជននិងការិយាល័យរដ្ឋបាល (ជាពិសេសអង្គភាពបកប្រែភាសា និងដោយឡែកចំពោះអ្នកបកប្រែភាសាផ្ទាល់មាត់) និងអង្គភាពចំណុះទាំងអស់ ។ គាត់ក៏ថ្លែងលោកប្រធានអង្គជំនុំជម្រះ និល ណុន ក៏ថ្លែងអំណរគុណដល់មន្ត្រីមកពីស្ថាប័នអង្គភាពនានារបស់រាជរដ្ឋាភិបាលដូចជា មន្ត្រីផ្នែកពន្លត់អគ្គីភ័យ ផ្នែកពេទ្យ និងផ្នែកដទៃទៀតដែលពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះ ។ ចុងក្រោយ គាត់ថ្លែងអំណរគុណដល់បុគ្គលិកមន្ត្រីមកពីអង្គការនិងមជ្ឈមណ្ឌលមួយចំនួនដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយជ្រោមជ្រែងគាំទ្រដល់កិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង០០២/០១ អស់ពីកម្លាំងកាយចិត្ត បញ្ញាស្មារតីតាំងពីថ្ងៃចាប់ផ្តើមដំបូងរហូតដល់ទីបញ្ចប់ប្រព្រឹត្តទៅដោយរលូននិងទទួលបានលទ្ធផលល្អប្រសើរ ។

លោក និល ណុន ប្រកាសថា “អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសបិទកិច្ចពិភាក្សាដេញដោលពិនិត្យភ័ស្តុតាងលើសំណុំរឿងក្តី០០២/ ០១ ត្រឹមនេះ ហើយសូមប្រកាសជូនដល់ភាគី និងសាធារណជនបានជ្រាបថា បន្ទាប់ពីនេះទៅអង្គជំនុំជម្រះនឹងចាប់ផ្តើមនូវកិច្ចការថ្មីមួយទៀតរបស់ខ្លួន គឺការពិភាក្សា ពិចារណាសម្រេចសេចក្តី និងរៀបចំនូវសាលក្រមវិនិច្ឆ័យលើសំណុំរឿងលេខ០០២/០១នេះ ។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់អាចកំណត់ជាក់លាក់បាននៅឡើយទេ ដោយហេតុថា សំណុំរឿងក្តីនេះមានទ្រង់ទ្រាយធំធេង និងមានលក្ខណៈស្មុគស្មាញ ហើយនឹងត្រូវធ្វើជាបីភាសានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ យើងនឹងជម្រាបជូនដំណឹងអំពីកាលបរិច្ឆេទសវនាការប្រកាសសាលក្រមដល់ភាគី និងសាធារណជនបានជ្រាបជាមុនក្នុងកាលវេលាសមស្របមុនពេលប្រកាសសាលក្រម” ។

សវនាការបញ្ចប់នៅវេលាម៉ោង២:២០នាទីរសៀល ។

**ខាត់ថារី ឡើណខូរអើ**



សហចៅក្រមជាតិ និងអន្តរជាតិ ក្នុងអំឡុងពេលបញ្ចប់សេចក្តីសន្និដ្ឋាននៅសាលាក្តីខ្មែរក្រហម នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។ រូបថត : អ.វ.ត.ក

# សម្រាប់មនុស្សភាគច្រើន រណសិរ្សជាអ្នកផ្តល់ជីវិតថ្មី

កាលពី៣៥ឆ្នាំមុន នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីរំដោះជាតិកម្ពុជា ឬហៅដោយខ្លីថា រណសិរ្សបានចាប់កំណើតឡើងនៅលើតំបន់ដីក្រហមនៃទីប្រជុំជនស្នួល ខេត្តក្រចេះចម្ងាយប្រមាណជា២៥គីឡូម៉ែត្រពីព្រំដែនវៀតណាម ។ កងទ័ពរណសិរ្ស គឺជាកងតស៊ូប្រដាប់អាវុធមួយមានការចូលរួមពីសំណាក់កងទ័ពវៀតណាមនិងកងទ័ពកម្ពុជា ដែលមួយចំនួនជាពលរដ្ឋកម្ពុជារស់នៅប្រទេសវៀតណាម ហើយមួយចំនួនទៀតជាអតីតកម្មាភិបាលខ្មែរក្រហមដែលបានភៀសខ្លួនទៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨នៅពេលដែលមជ្ឈឹមបក្សខ្មែរក្រហមបញ្ជាឲ្យចាប់ខ្លួនអ្នកទាំងនោះដោយចោទថាក្បត់និងបដិវត្តន៍ ។

គោលបំណងរបស់រណសិរ្សនេះគឺដើម្បីវាយផ្តួលរំលំរបបខ្មែរក្រហមដែលបាន និងកំពុងកាប់សម្លាប់ប្រជាជនកម្ពុជាជារៀងរាល់ថ្ងៃ ។ ថ្ងៃនៃការបង្កើតរណសិរ្សត្រូវបានរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នអះអាងថាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ។ ពេលនេះ បូជនីយដ្ឋានដើម្បីរំឭកដល់ព្រឹត្តិការណ៍នៃការបង្កើតរណសិរ្សដែលមានឈ្មោះថា «វិមានអនុស្សាវរីយ៍ពីរធ្នូ» ត្រូវបានសម្ពោធជាផ្លូវការនៅចំទីតាំងដដែលដែលរណសិរ្សនេះចាប់កំណើតឡើង ។ ពិធីនេះត្រូវបានចូលរួមជាអធិបតីដោយសម្តេច ហេង សំរិន ដែលជាស្ថាបនិកមួយរូបរបស់រណសិរ្សពីរធ្នូនិងជាអតីតប្រធានាធិបតីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ - ១៩៨៩) ។

ថវិកាដែលបានចំណាយសម្រាប់ «វិមានអនុស្សាវរីយ៍ពីរធ្នូ»គឺ បីលានប្រាំបីសែនដុល្លាសហរដ្ឋអាមេរិក ជាចំនួនដែលប្រហាក់ប្រហែលទៅនិងរយៈពេលកាន់កាប់របស់ខ្មែរក្រហមដែលមានរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ

បីសប្តាហ៍ក្រោយពីរណសិរ្សចាប់កំណើតឡើង កងទ័ពរណសិរ្សបានវាយសម្រុកចូលទឹកដីកម្ពុជាគ្រប់ច្រកល្ហកពីព្រំដែនវៀតណាមនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ និងវាយដណ្តើមបានទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយផ្តួលរំលំរបបខ្មែរក្រហមជាស្ថាពរ ។

៣៥ឆ្នាំក្រោយមក ភាពចម្រូងចម្រាស់ទាក់ទងទៅការបង្កើតរណសិរ្សនេះនៅតែកើតមានជាហូរហែរ ។ អ្នកខ្លះបានបន្ទោសថារណសិរ្សនេះបានបើកផ្លូវឲ្យកងទ័ពបរទេស(វៀតណាម) ចូលទន្ទ្រានទឹកដីកម្ពុជា ហើយបានកាន់កាប់ប្រទេសរយៈពេលដប់ឆ្នាំក្រោយមកទៀត ចាប់ពីឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៨៩ ។ ចំណែកឯអ្នកផ្សេងទៀត ដែលជាប្រជាជនកម្ពុជាភាគច្រើន បានសរសើរដល់រណសិរ្សព្រោះកងទ័ពរណសិរ្សបានជួយសង្គ្រោះជីវិតខ្លួនពីខ្មែរក្រហមដែលមនុស្សភាគច្រើនស្លាប់ជាខ្លាំង ។ អ្នកទាំងនោះយល់ឃើញថា រណសិរ្សគឺជាអ្នកផ្តល់កំណើតថ្មី នាំទៅរកសេរីភាពនិងសិទ្ធិរស់រានមានជីវិតដែលប្រជាជនកម្ពុជារីករាយជាថ្មីម្តងទៀត



ពិធីសម្ពោធ «វិមានអនុស្សាវរីយ៍ពីរធ្នូ» នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣ រូបថត : លឹម ដាវុត្ថា

ក្រោយពេលរបបខ្មែរក្រហមដួលរលំ ។

ទោះជាយ៉ាងណាក៏ដោយ កាលពី៣៥ឆ្នាំមុន មនុស្សមិនច្រើនទេដែលដឹងពីការបង្កើតរណសិរ្សនេះ ។ កម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាលមួយចំនួនដែលកាន់កាប់តំបន់មួយចំនួននៅជិតទីប្រជុំជនស្នួល មិនបានដឹងពីការបង្កើតរណសិរ្សនេះដែរ ។ ករណីមួយចំនួនដូចជា ឡុង ម៉ារី ដែលជាអតីតយុទ្ធនារីមួយរូបក្នុងកងពល៧០៣របស់ខ្មែរក្រហម ដែលកងពលនេះបានលុកលុយចូលទឹកដីវៀតណាមក្នុងឆ្នាំ១៩៧៧ និង ឆ្នាំ១៩៧៨ ។ ម៉ារី មិនបានដឹងអំពីការបង្កើតទ័ពរណសិរ្សទេ រហូតទាល់តែកងទ័ពវៀតណាមវាយចូលទឹកដីកម្ពុជាតែម្តងនាចុងឆ្នាំ១៩៧៨ ។ ឯម សារិន ដែលជាអតីតគណៈតំបន់ក្រចេះនាដំណាក់កាលចុងក្រោយនៃរបបខ្មែរក្រហមក៏មិនដឹងអំពីការបង្កើតកងទ័ពរណសិរ្សដូចនិង ម៉ារី ដែរ ។ សារិន ដែលសព្វថ្ងៃរស់នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ បាននិយាយថា គាត់មិនដឹងទាល់តែសោះអំពីរណសិរ្សនៅស្រុកស្នួលនេះ ។

អ្វីដែលគាត់ដឹងគឺថា វៀតណាមបានវាយលុកចូលមក ហើយគាត់ក៏នាំប្រជាជននិងយោធាខ្មែរក្រហមរត់ ដោយឆ្លងកាត់ទន្លេមេគង្គ រួចបន្តដំណើរទៅភ្នំដងរែក ជាកន្លែងដែលគាត់បម្រើចលនាខ្មែរក្រហមអស់រយៈពេលជាង១៥ឆ្នាំក្រោយមកទៀត ។ ចំណែកអតីតប្រធានកងចល័តនារីប្រចាំភូមិភាគឦសានឈ្មោះ ចេង បូរី ក៏មិនបានដឹងអំពីការបង្កើតរណសិរ្សនេះដែរ ។ បូរី បាននិយាយថា នារំឡុងខែធ្នូឆ្នាំ១៩៧៨ គាត់កំពុងតែដឹកនាំកងចល័តរបស់គាត់ធ្វើការដូចធម្មតា ស្រាប់តែថ្ងៃមួយ ថ្នាក់លើជូនដំណឹងមកគាត់ឲ្យរៀបចំខ្លួនដើម្បីរត់គេចព្រោះកងទ័ពវៀតណាមបានវាយលុកចូលមកហើយ ។

ប្រជាជនទូទៅដែលមិនមែនជាកម្មាភិបាលខ្មែរក្រហមក៏មិនដឹងអំពីផែនការនិងមូលហេតុនៃការបង្កើតរណសិរ្សនេះដែរ ។ ក៏ប៉ុន្តែ អ្នកទាំងនោះស្គាល់ច្បាស់ថ្ងៃ “៧ មករា” ជាថ្ងៃដែលកងទ័ពរណសិរ្សវាយយកបានទីក្រុងភ្នំពេញ និងផ្តួលរំលំរបបខ្មែរក្រហម ។ អ្វីដែលប្រជាជនកម្ពុជាធម្មតាដឹងគឺថា កងទ័ពរណសិរ្សនិងកងទ័ពវៀតណាមបានចូលមកសង្គ្រោះ និងនាំមកនូវសេរីភាពនិងក្តីសង្ឃឹមថាបានរួចរស់ជីវិតពីរបបខ្មែរក្រហមដែលខ្លួនបានរស់នៅយ៉ាងឈឺចាប់អស់រយៈកាលជិតបួនឆ្នាំ ។

ខណៈពេលដែលប្រជាជនកម្ពុជាទូទៅរីករាយនិងស្វាគមន៍ដល់កងទ័ពរណសិរ្សដែលបានផ្តួលរំលំរបបខ្មែរក្រហម មនុស្សមួយចំនួនទៀតមិនបានកោតសរសើរដល់កងទ័ពរណសិរ្សទេ តែបែរជាចោទប្រកាន់កងទ័ពរណសិរ្សថាបានអនុញ្ញាតឲ្យកងទ័ពបរទេសលុកលុយចូលប្រទេសកម្ពុជាទៅវិញ ។ ដោយសារតែបទចោទអំពីការលុកលុយចូលប្រទេសមួយផ្សេងទៀតនេះហើយបានជាសហគមន៍អន្តរជាតិ ដូចជាសហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ និងបណ្តាប្រទេសផ្សេងទៀតលើ លោកមិនទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលគាំទ្រដោយវៀតណាម ។ ជាមួយគ្នានោះដែរ ប្រជាជនកម្ពុជាមួយចំនួនទៀតក៏មិនបានគាំទ្ររដ្ឋាភិបាលនេះដែរ ។

ប្រជាជនកម្ពុជាដែលគាំទ្រការចូលមករំដោះរបស់កងទ័ពរណសិរ្សព្រោះខ្លួនយល់ថា បើសិនជាកងទ័ពរណសិរ្សមកយឺតតែបន្តិច ខ្លួនក៏មិនមានមានជីវិតរហូតមកដល់សព្វថ្ងៃដែរ ។ មនុស្សមួយចំនួនធំយល់បែបនេះព្រោះកាលនោះកម្មាភិបាលខ្មែរក្រហមបានគាប់សង្កត់ប្រជាជនយ៉ាងខ្លាំងនៅពេលដែលសង្គ្រាមនៅតាមព្រំដែនវៀតណាមកាន់តែមានសភាពខ្លាំងឡើងៗ ។ មានមនុស្សមិនតិចទេដែលបានបាត់បង់ជីវិតដោយកណ្តាប់ដៃរបស់កម្មាភិបាលខ្មែរក្រហម នៅមុនពេលកងទ័ពរណសិរ្សមកដល់បន្តិច ។

ពេលនេះ វិមានអនុស្សាវរីយ៍ពីរធ្នូ ត្រូវបានសម្ពោធនៅទីកន្លែងកំណើតរបស់ខ្លួន ។ ទោះបីជាអត្ថន័យនិងកាលបរិច្ឆេទនៃកំណើតកងទ័ពរណសិរ្សនៅតែជាបញ្ហាចម្រូងចម្រាសក៏ដោយ ទីតាំងរបស់វិមានអនុស្សាវរីយនេះនិងត្រូវបានចងចាំថាជាទីតាំងមួយនៃកំណើតសេរីភាពរបស់មនុស្សភាគច្រើននៅប្រទេសកម្ពុជា ។ រាល់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយក៏មិនអាចជៀសផុតពីការរិះគន់របស់សាធារណជនបានឡើយ ព្រោះមនុស្សគ្រប់រូបមានគំនិតយោបល់ខុសៗគ្នា ។ ប៉ុន្តែ អ្វីដែលត្រូវចងចាំរួមគ្នានោះគឺថាប្រជាជនកម្ពុជាបានរស់ពានជីវិតឡើងវិញដោយសារកំណើតពីរធ្នូនិងថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ព្រោះរបបខ្មែរក្រហមដ៏ប្រល័យដែលពិភពលោកទាំងមូលស្អប់ខ្ពើមត្រូវបានដួលរលំ ។

**ញាណ សុជាតិ**

# ការអត់ឃ្មាន ការចងចាំ និងយុត្តិធម៌

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

*កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី១០)*

ក្នុងវគ្គបញ្ចប់នេះ យើងខ្ញុំនឹងធ្វើការសង្ខេបឡើងវិញនូវបញ្ហាមួយចំនួនដែលបានលើកយកមកពិភាក្សាកាលពីវគ្គទី១ដល់វគ្គទី៩ ដែលកម្មវិធីវិទ្យុយើងខ្ញុំបានផ្សាយកន្លងមក ។ លើសពីនេះទៅទៀត យើងខ្ញុំនឹងផ្តល់ជាសេចក្តីសន្និដ្ឋានខ្លះៗទាក់ទងទៅនឹងបញ្ហាយុត្តិធម៌ ការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម និងបង្ហាញថាតើកេរដំណែលនៃសោកនាដកម្មដែលបានបន្សល់ពីរបបខ្មែរក្រហមបានបន្តប៉ះពាល់ដល់សង្គម ក៏ដូចជានយោបាយរបស់ប្រទេសកម្ពុជាយ៉ាងដូចម្តេចខ្លះ ។

**ការអត់ឃ្លាន និងយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា ៖ តើយើងបានរៀនសូត្រអ្វីខ្លះពីបញ្ហានេះ?**

ខណៈដែលកម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំឈានមកដល់វគ្គទី១០ ដែលជាវគ្គចុងក្រោយ សំណុំរឿង០០២ផ្នែកទីមួយ នៅឯតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏ឈានដល់ដំណាក់កាលចុងបញ្ចប់ដែរ ។ នាពេលថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទសំណុំរឿង០០២ ផ្នែកទីមួយ ដែលពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និងខៀវ សំផន ។ ខណៈដែលសំណុំរឿង០០២ផ្នែកទីមួយផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនដែលពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងព្រឹត្តិការណ៍ផ្សេងៗទៀត ដែលបានកើត



យោធា និងកម្មាភិបាលខ្មែរក្រហមកំពុងគាស់ថ្មដើម្បីលើកទំនប់ នៅជាយក្រុងភ្នំពេញ ក្នុងរបបខ្មែរក្រហម

ឡើងមុនពេលខ្មែរក្រហមឡើងកាន់អំណាច ។ បញ្ហានៃការអត់ឃ្លាន និងការបង្អត់អាហារ ដូចជា ការកំណត់របបអាហារ ការនាំស្រូវចេញទៅក្រៅប្រទេស និងគោលនយោបាយទូទៅចំពោះការធ្វើកសិកម្ម និងការចែកចាយអាហារនៅក្នុងរបបខ្មែរក្រហម ក៏បានលើកយកមកពិភាក្សាក្នុងអំឡុងពេលនៃសវនាការនៅក្នុងសំណុំរឿង០០២ផ្នែកទីមួយនេះដែរ ។ ប៉ុន្តែ ដោយផ្អែកទៅលើវិសាលភាពនៃសំណុំរឿង០០២ ផ្នែកទីមួយនេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនលើកយកបញ្ហានៃការអត់ឃ្លាន និងការបង្អត់អាហារមកធ្វើការពិនិត្យពិច័យនៅក្នុងសាលក្រមនោះឡើយ ។ សាលក្រមនៃសំណុំរឿង០០២ផ្នែកទីមួយ ត្រូវបានរំពឹងថានឹងប្រកាសនៅពាក់កណ្តាលឆ្នាំ២០១៤ ខាងមុខនេះ ។ លក្ខខណ្ឌរស់នៅទូទៅរបស់ប្រជាជនកម្ពុជាក្រោមរបបខ្មែរក្រហមរួមមាន ការបង្អត់អាហារ និងការធ្វើការហួសកម្លាំង អាចនឹងត្រូវលើកយកមកពិនិត្យពិច័យនៅក្នុងសំណុំរឿងផ្នែកផ្សេងទៀតនៃសំណុំរឿង០០២ នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក វីលៀម ស្មីត **(William Smith)** សហព្រះរាជអាជ្ញាអន្តរជាតិនៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានកត់សម្គាល់ថា សំណុំរឿង០០២ផ្នែកទីមួយ ដែលទើបតែបញ្ចប់ «គឺជាចំណុចចាប់ផ្តើមនៃសំណុំរឿង០០២ ។ សំណុំរឿងផ្នែកផ្សេងៗទៀតនៃសំណុំរឿង០០២គួរតែចាប់ផ្តើមឲ្យបានលឿន ។ វាមានសារសំខាន់ណាស់ដែលបទចោទប្រកាន់ផ្សេងទៀតត្រូវតែលើកយកមកកាត់សេចក្តីដោយសារតែរហូតមកដល់បច្ចុប្បន្ននេះមានតែមួយភាគបីប៉ុណ្ណោះនៃរឿងរ៉ាវនៃរបបខ្មែរក្រហមត្រូវបានលើកយកមកពិភាក្សា» ។ ទោះបីជាតុលាការបានបញ្ចប់សំណុំរឿង០០២ផ្នែកទីមួយក៏ដោយ ក៏យើងនៅតែស្ថិតក្នុងភាពស្រពេចស្រពិលនៅឡើយថាតើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងជនជាប់ចោទទាំងពីររូបអាចមានលទ្ធភាពបន្តចូលរួមនៅក្នុងសវនាការនៃសំណុំរឿងផ្សេងទៀតរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរឬទេ ។

បទពិសោធដែលទទួលបានពីការបើកសវនាការពិនិត្យភស្តុតាង បានជួយឲ្យសហគមន៍ជាតិ និងអន្តរជាតិយល់ដឹងកាន់តែច្បាស់អំពីលក្ខខណ្ឌរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម និងបានដឹងថាតើមេដឹកនាំខ្មែរក្រហមដែលបានអះអាងថា ខ្លួនបានរំដោះប្រទេសកម្ពុជាឲ្យចេញពីអំពើពុករលួយ និងការជ្រៀតជ្រែករបស់បរទេសបានធ្វើឲ្យប្រជាជនរបស់ខ្លួនធ្លាក់ចូលទៅក្នុងអន្លង់នៃសេចក្តីឈឺចាប់ និងការស្លាប់រង្គាលដោយរបៀបណា ។

ផ្អែកទៅលើភស្តុតាងដែលបានលើកឡើងនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងឯកសារស្រាវជ្រាវផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម ក៏ដូចជាអត្ថបទសម្ភាសផ្សេងៗបានបង្ហាញថា មេដឹកនាំខ្មែរក្រហមមានបំណងធ្វើការកែប្រែប្រទេសកម្ពុជាឲ្យទៅជាប្រទេសសង្គមនិយមមួយក្នុងល្បឿនដែលពិបាកនឹងសម្រេចបាន ។ នៅក្នុងដំណើរការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសសង្គមនិយម មេដឹកនាំខ្មែរក្រហមបានរឹបអូសទ្រព្យសម្បត្តិ និងបំបិទកម្មសិទ្ធិឯកជន ដូចជា ការធ្វើស្រែចម្ការ ការចម្អិនអាហារ ការបរិភោគអាហារជាលក្ខណៈគ្រួសារ និងសកម្មភាពផ្សេងៗដែលមានលក្ខណៈឯកជន ។ មិនតែប៉ុណ្ណោះ មេដឹកនាំខ្មែរក្រហម មានបំណងធ្វើឲ្យបដិវត្តន៍របស់ខ្លួនមានភាពស្អាតស្អំ និងមានភាពជឿនលឿនជាងប្រទេសកុម្មុយនីស្តដទៃទៀត ដូចជា ប្រទេសចិន និងប្រទេសវៀតណាម ជាដើម ។ ជាងនេះទៅទៀត មេដឹកនាំខ្មែរក្រហមបានសម្រេចចិត្តបិទប្រកព្រំដែន និងអនុវត្តគោលនយោបាយពឹងពាក់លើខ្លួនឯង ដោយសារតែមេដឹកនាំខ្មែរក្រហមយល់ថា មានការជ្រៀតជ្រែកពីសំណាក់ចលនាបដិវត្តន៍សង្គមនិយមនៅអាស៊ីអាគ្នេយ៍ ដោយក្នុងនោះរួមមានបក្សកុម្មុយនីស្តឥណ្ឌូចិនដឹកនាំដោយវៀតណាម និងការជ្រៀតជ្រែកពីប្រទេសចក្រពត្តិនិយម ។

លទ្ធផលនៃការប្រែប្រទេសឲ្យទៅជាប្រទេសសង្គមនិយមស្អាតស្អំ និងឯករាជ្យក្នុងល្បឿនលឿនពេក បានបំផ្លាញសង្គមកម្ពុជាស្ទើរតែទាំងស្រុង ហើយបានបណ្តាលឲ្យប្រជាជនជាច្រើននាក់ស្លាប់ ដោយសារការសម្លាប់ និងលក្ខខណ្ឌការរស់នៅយ៉ាងអាក្រក់ ដូចជា ការអត់ឃ្លាន និងការបង្អត់អាហារ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ទំនងជាមិនធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅលើឧក្រិដ្ឋកម្មដែលពាក់ព័ន្ធទៅនឹងការអត់ឃ្លានដែលបានកើតមានឡើងចំពោះប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះទេ ។ ប៉ុន្តែ នេះមិនបាន

បញ្ជាក់ថា យើងគួរតែបំភ្លេចចោលនូវសោកនាដកម្មដែលបានកើតឡើងដោយសារការអត់ឃ្លាន ឬចាត់ទុកថា រឿងរ៉ាវទាំងនេះគឺជាគ្រោះមហន្តរាយធម្មជាតិ ដូចជា គ្រោះរាំងស្ងួតដី ឬទឹកជំនន់ តែមិនមែនជាឧក្រិដ្ឋកម្មនោះឡើយ ។ យើងខ្ញុំធ្លាប់បានលើកឡើងក្នុងវគ្គមុនហើយថា ការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម គួរតែត្រូវបានចងចាំទុក និងលើកយកមកពិភាក្សាតាមផ្លូវច្បាប់ ជាពិសេសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## កេរដំណែលពីការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

បើទោះបីរបបខ្មែរក្រហមបានកន្លងផុតទៅជាងបីទសវត្សរ៍



ប្រជាជនកម្ពុជាកំពុងសម្រាកដើម្បីទទួលការព្យាបាលក្នុងខែមករា ឆ្នាំ១៩៧៩ ក្រោយរបបខ្មែរក្រហមដួលរលំ ។

ហើយក៏ដោយ ក៏ស្លាកស្នាមដែលសល់ពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម ដោយរួមបញ្ចូលទាំងលក្ខខណ្ឌនៃការអត់ឃ្លាននៅតែបន្តប៉ះពាល់ទៅលើសង្គម និងនយោបាយរបស់កម្ពុជានាពេលបច្ចុប្បន្ន ។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតែទទួលរងការប៉ះពាល់ទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយសារតែលក្ខខណ្ឌនៃការអត់ឃ្លានដ៏អាក្រក់ដែលបានកើតឡើង ។ អត្រាកំណើតទារកក៏មានការថយចុះ ដោយសារតែការអត់ឃ្លានដែលទទួលរងនៅក្នុងរបបខ្មែរក្រហម ។ នេះមានន័យថា គ្រួសារជាច្រើនមិនត្រឹមតែបាត់បង់សមាជិក គ្រួសារប៉ុណ្ណោះទេ ថែមទាំងមិនអាចផ្តល់កំណើតដល់សមាជិកថ្មី ក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ប្រសិនបើមានការផ្តល់កំណើតនៅក្នុងរបបនោះ ម៉្លោះបុគ្គលទាំងនោះ ក្លាយជាមនុស្សធំពេញវ័យមិនខាន ។ ជាងនេះទៅទៀត សមាជិកថ្មីដែលបានចាប់កំណើតនៅក្នុងរបបខ្មែរក្រហម ដែលម្តាយរបស់ខ្លួនជួបប្រទះការអត់ឃ្លាន អាចប្រឈមមុខនឹងបញ្ហាសុខភាព នេះបើយោងតាមការសិក្សាផ្នែកវេជ្ជសាស្ត្រ ។

ទន្ទឹមនឹងការប៉ះពាល់ដោយផ្ទាល់ទៅលើបុគ្គល និងក្រុមគ្រួសារដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បទពិសោធនៃការឆ្លងកាត់ការអត់ឃ្លាន ក៏បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គម និងនយោបាយរបស់កម្ពុជាដែរ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ សង្គមជាតិទាំងមូលបានបន្តប្រឈមមុខនឹងជម្លោះផ្ទៃក្នុងដ៏រ៉ាំរ៉ៃ ។ អស់រយៈពេលជាច្រើនទសវត្សរ៍ ការភ័យខ្លាចចំពោះការកើតឡើងនូវជម្លោះ និងការចងចាំពីការអត់ឃ្លានបានធ្វើឲ្យប្រជាជនកម្ពុជាភាគច្រើនយកចិត្តទុកដាក់ទៅលើតែការរស់នៅរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ ប្រជាជនកម្ពុជាចាប់ផ្តើមមានភាពសង្ស័យទៅលើរបត់នយោបាយ ការធ្វើបាតុកម្ម និងចលនាដទៃទៀតដែលអាចបង្កជាភាពមិនប្រក្រតីនៅក្នុងសង្គម ។ នៅពេលដែលអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមពិចារណាពីគុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើបាតុកម្ម ឬការទាមទារផ្សេងៗ បុគ្គលទាំងនោះរមែងតែសម្រេចចិត្ត ដោយផ្អែកទៅលើអ្វីដែលខ្លួនបានចងចាំទាក់ទងយ៉ាងច្បាស់ទៅនឹងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ដែលជាលទ្ធផលនៃការធ្វើបដិវត្តន៍របស់ខ្មែរក្រហមចំពោះអំពើពុករលួយ

និងភាពអយុត្តិធម៌ដែលធ្លាប់បានកើតឡើង ។ ជាលទ្ធផល មនុស្សភាគច្រើនផ្តោតការយកចិត្តទុកដាក់ស្ទើរតែទាំងស្រុងទៅលើការសម្រេចឲ្យបាននូវស្ថេរភាព និងសន្តិភាព ជាជាងការអភិវឌ្ឍសង្គមប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្ស ។

ការឈឺចាប់ និងរបួសដែលសេសសល់ពីរបបខ្មែរក្រហមចាប់ផ្តើមធូរស្រាលមកវិញ ដោយសារតែពេលវេលា និងកិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកយុត្តិធម៌ ការផ្សះផ្សាជាតិ និងការដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម តាមរយៈការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងសកម្មភាពដទៃទៀត ។ លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា បានឈានទៅរកភាពប្រសើរជាងមុន នៅពេលដែលមានការពិភាក្សា និងការផ្លាស់ប្តូរយោបល់គ្នា ។ និស្សិតកម្ពុជាដែលសិក្សាផ្នែកច្បាប់ជាច្រើន ចាប់ផ្តើមចាប់អារម្មណ៍ទៅលើបញ្ហាសិទ្ធិមនុស្ស ច្បាប់ និងភាពឯករាជ្យរបស់ស្ថាប័នច្បាប់ ។ ប្រជាជនកម្ពុជា ចាប់ផ្តើមហ៊ានបញ្ចេញមតិយោបល់នៅពេលដែលយល់ឃើញថា សិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពាន ឬក៏មិនទាន់ទទួលបានសិទ្ធិប្រជាធិបតេយ្យពេញលេញ តាមរយៈការធ្វើបាតុកម្មអហិង្សា និងការពិភាក្សាជាសាធារណៈ ។

នេះសបញ្ជាក់ឲ្យឃើញថា ប្រជាជនកម្ពុជាដែលកាលពីប៉ុន្មានទសវត្សរ៍មុនជាមនុស្សគិតតែពីជីវភាពប្រចាំថ្ងៃដោយសារតែខ្លួនធ្លាប់ឆ្លងកាត់ការអត់ឃ្លាន អំពើហិង្សា និងការបំបិទសិទ្ធិសេរីភាព ចាប់ផ្តើមហ៊ានសង្ឃឹមច្រើនជាងមុន ពោលគឺលើសពីការរស់នៅប្រចាំថ្ងៃនិងសង្ឃឹមថា ប្រទេសរបស់ខ្លួននឹងចាកផុតពីសង្គ្រាមរ៉ាំរ៉ៃ និងអំពើហិង្សា ។

តាមរយៈការខិតខំប្រឹងប្រែងពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍប្រកបដោយសមភាព សបញ្ជាក់ពីភាពវិជ្ជមានដែលតាមរយៈកិច្ចខិតខំប្រឹងប្រែងនេះ ប្រជាជនកម្ពុជាទាំងអស់នឹងអាចព្យាបាលរបួសដែលបានបន្សល់ទុកពីរបបខ្មែរក្រហម ។



ប្រជាជនកម្ពុជាធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញក្រោយរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ។ ដោយខ្វះកម្លាំងសត្វពាហនៈដើម្បីអូសទាញ ស្ត្រីពីរនាក់ បានអូសរទេះដោយធ្វើដំណើររាប់រយគីឡូម៉ែត្រដើម្បីត្រឡប់ទៅស្រុកកំណើតវិញ ។

*តទៅនេះគឺជាសំណួរ និងចម្លើយរបស់ប្រិយមិត្តអ្នកស្តាប់វិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកស្តាប់បានផ្ញើសំណួរនេះមកមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា វ៉ែនដល ដឺហ្វាលកូ ជាអ្នកឆ្លើយសំណួរ ។*

**១) ហេតុអ្វីបានជាខ្មែរក្រហមបង្អត់បាយប្រជាជនខ្លួនឯងនៅពេលដែលផលដំណាំមានច្រើន? តើផលដំណាំទាំងនោះត្រូវបានខ្មែរក្រហមដឹកជញ្ជូនទៅណា?**

◆ *ទីមួយ ខ្មែរក្រហមមានគម្រោងផលិតស្រូវឲ្យបានច្រើន ពោលគឺ បីតោនក្នុងមួយហិចតា ។ ប៉ុន្តែ ទិន្នផលនេះមិនធ្លាប់ទទួលបានជោគជ័យនោះទេ នៅពេលដែលខ្មែរក្រហមកាន់អំណាច ។ ទីពីរ ផែនការសេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសឧស្សាហកម្មជឿនលឿនតាមរយៈការលក់ស្រូវទៅកាន់ទីផ្សារអន្តរជាតិដើម្បីរកប្រាក់ចំណូលបន្ថែមសម្រាប់អនុវត្តផែនការរបស់ខ្លួន ។ កត្តាទាំងអស់នេះបានបង្កជាសម្ពាធយ៉ាងខ្លាំងដល់កម្មាភិបាលថ្នាក់ក្រោមតាមតំបន់ដោយធ្វើយ៉ាងណាផ្តល់នូវទិន្នផលស្រូវឲ្យបានគ្រប់តាមផែនការកំណត់របស់ថ្នាក់ដឹកនាំមជ្ឈិមដើម្បីផ្គត់ផ្គង់ដល់យោធាខ្មែរក្រហមនិងលក់ទៅប្រទេសដទៃ សម្រាប់ដោះដូរជា ប្រាក់កាស និងទំនិញដែលខ្មែរក្រហមមិនអាចផលិតបាន ។*

**២) ហេតុអ្វីបានជាខ្មែរក្រហមឲ្យប្រជាជនធ្វើការធ្ងន់?**

◆ *ខ្មែរក្រហមបានថ្លែងថា គោលនយោបាយរបស់ខ្លួនគឺរស់នៅឯករាជ្យម្ចាស់ការ នេះមានន័យថា មិនមានជំនួយបរទេសនោះទេ ។*

*ខ្មែរក្រហមក៏មានគម្រោងធ្វើឲ្យប្រទេសកម្ពុជាឈានឆ្ពោះទៅមុខ "មហាលោតផ្លោះ" ដើម្បីក្លាយជាប្រទេសសង្គមនិយមមួយដ៏រីកចម្រើន និងធ្វើឲ្យប្រទេសកម្ពុជាមានការរីកលូតលាស់ជាងប្រទេសសង្គមនិយមដទៃទៀត ដូចជា ប្រទេសចិន និងប្រទេសវៀតណាមជាដើម ។ ដោយសារតែខ្មែរក្រហមពឹងផ្អែកទាំងស្រុងទៅលើកម្លាំងពលកម្មប្រជាជន ដើម្បីសម្រេចឲ្យផែនការរបស់ខ្លួន ជាលទ្ធផលប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងច្រើនម៉ោង ។*

**៣) ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯង?**

◆ *វាមានកត្តាជាច្រើនដែលបានបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់ក្នុងទ្រង់ទ្រាយធំ ។ កត្តាទាំងនោះ រួមមានការកាប់សម្លាប់ លក្ខខណ្ឌរស់នៅ និងការបង្អត់អាហារ ។ ខ្មែរក្រហមមានបំណងប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាប្រទេសសង្គមនិយមមួយដ៏បរិសុទ្ធ ។ ខ្មែរក្រហមយល់ឃើញថា ខ្លួនមានសត្រូវជាច្រើនទាំងជនជាតិខ្មែរ និងជនជាតិបរទេស ដែលធ្វើការរារាំងផែនការបដិវត្តន៍របស់ខ្លួន ។ ជាលទ្ធផល ខ្មែរក្រហមមានការភ័យខ្លាច និងព្រួយបារម្ភកាន់តែខ្លាំងឡើងៗចំពោះបញ្ហានេះ ។ មេដឹកនាំខ្មែរក្រហមក៏បានស្តីបន្ទោសទៅលើខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលបានធ្វើឲ្យផែនការផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតារបស់ខ្លួនបរាជ័យ ។*

*ដូច្នេះ នៅតំបន់ណាដែលមិនអាចបំពេញតាមផែនការរបស់ខ្មែរក្រហមបាន ខ្មែរក្រហមចាប់ផ្តើមធ្វើការបោសសម្អាតតំបន់នោះដោយអំពើហិង្សា ។ ដោយសារតែមានការប្រើអំពើហិង្សា និងលក្ខខណ្ឌរស់នៅមិនសមរម្យ កត្តាទាំងអស់នេះបានបង្កឲ្យមានការសម្លាប់ប្រជាជនក្នុងលក្ខណៈទ្រង់ទ្រាយធំ ។*

**៤) ហេតុអ្វីបានជាខ្មែរក្រហមបំបែកគ្រួសារមិនឲ្យរស់នៅជុំគ្នា?**

◆ *មេដឹកនាំខ្មែរក្រហមដឹងថា គ្រួសារមានសារសំខាន់ និងទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសង្គមខ្មែរ ។ មេដឹកនាំខ្មែរក្រហមគិតថា ប្រជាជនកម្ពុជាគ្រប់រូបគួរតែស្មោះត្រង់នឹងបដិវត្តន៍របស់ខ្លួនជាងសមាជិកគ្រួសារ ។ មេដឹកនាំខ្មែរក្រហមក៏ប្រមើលមើលឃើញថា គ្រួសារគឺជាបញ្ហាប្រឈមមួយចំពោះផែនការប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជារដ្ឋសង្គមនិយមមួយដ៏ស្អាតស្អំ ។ ដូច្នេះ ដើម្បីសម្រេចផែនការនេះ ខ្មែរក្រហមមិនបានគិតពីទំនាក់ទំនងគ្រួសារនៅក្នុងសង្គមកម្ពុជានោះទេ ។ ហេតុផលមួយផ្សេងទៀតចំពោះការបំបែកបំបាក់គ្រួសារ ដោយសារតែខ្មែរក្រហមត្រូវការកម្លាំងពលកម្មដើម្បីបំពេញការងារទៅតាមគោលដៅបដិវត្តន៍ ដូច្នេះ ប្រជាជនត្រូវបានខ្មែរក្រហមបញ្ជូនទៅកាន់តំបន់ផ្សេងៗពីគ្នា ។*

**៥) ហេតុអ្វីបានជាមិនមានប្រជាជនណាម្នាក់ធ្វើការ**

***បះបោរនឹងខ្មែរក្រហម?***

◆ បានជាប្រជាជនមិនធ្វើការបះបោរនឹងខ្មែរក្រហម ដោយសារតែ ទីមួយ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចខ្មែរក្រហមបានជម្លៀសប្រជាជនទៅកាន់តំបន់ផ្សេងៗគ្នាដែលធ្វើឲ្យប្រជាជនមានការពិបាកក្នុងការបង្កើតក្រុម ដើម្បីធ្វើការប្រឆាំងតបតនឹងយោធាខ្មែរក្រហម ។ ទីពីរ នៅតាមទីជនបទ ប្រជាជនខ្មែរត្រូវបានខ្មែរក្រហមឃ្លាំមើលគ្រប់ពេលវេលា ។ ប្រសិនបើប្រជាជនណាម្នាក់ត្រូវបានចោទប្រកាន់ថាបាននិយាយអ្វីមិនល្អប៉ះពាល់ដល់បដិវត្តន៍ ប្រជាជនរូបនោះនឹងត្រូវខ្មែរក្រហមចាប់ឃុំឃាំងធ្វើទារុណកម្ម និងអាចត្រូវបានខ្មែរក្រហមសម្លាប់ ។ កត្តានេះបានបង្កឲ្យមានភាពលំបាកកាន់តែខ្លាំងឡើងសម្រាប់ប្រជាជនកម្ពុជា ដើម្បីរៀបចំក្រុមបះបោរប្រឆាំងនឹងខ្មែរក្រហម ។ ទីបី ដោយសារតែប្រជាជនកម្ពុជាត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការធ្ងន់ស្ទើរតែស្លាប់ និងការបង្អត់អាហារ ។

ដូច្នេះ ប្រជាជនកម្ពុជាពុំមានកម្លាំងគ្រប់គ្រាន់ក្នុងការប្រឆាំងតបតនឹងខ្មែរក្រហមនោះទេ ។ ទីបួន កម្មាភិបាលខ្មែរក្រហមគ្រប់ភូមិស្រុកមានអាវុធកាន់គ្រប់ដៃ ចំណែកឯប្រជាជនកម្ពុជាពុំមានអាវុធអ្វីអាចធ្វើការវាយបកនឹងខ្មែរក្រហមបាននោះទេ ។ នៅក្នុងរបបខ្មែរក្រហម ក៏ធ្លាប់មានព្រឹត្តិការណ៍បះបោរកើតឡើងដែរ ។

ព្រឹត្តិការណ៍កើតឡើងនៅក្នុងភូមិមួយ នៅពេលដែលមេដឹកនាំខ្មែរអ៊ីស្លាមនៅក្នុងភូមិមួយត្រូវបានខ្មែរក្រហមសម្លាប់ និងការប្រតិបត្តិសាសនា និងប្រពៃណីត្រូវបានលុបបំបាត់ ។ ប៉ុន្តែការបះបោររបស់ប្រជាជនខ្មែរអ៊ីស្លាមនៅក្នុងភូមិនោះត្រូវបានខ្មែរក្រហមបង្ក្រាបទៅវិញ នៅពេលដែលប្រជាជនខ្មែរអ៊ីស្លាមទាំងនោះពុំមានអាវុធអ្វី ក្រៅពីកាំបិត និងដាវ ។ បន្ទាប់មកប្រជាជនខ្មែរអ៊ីស្លាមដែលបានចូលរួមបះបោរត្រូវបានខ្មែរក្រហមចាប់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ។

***៦) តើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬទេ?***

◆ បច្ចុប្បន្ន តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានចេញសាលក្រមទាក់ទងនឹងជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាមេគុកទួលស្លែង ។ ស្របពេលជាមួយគ្នានេះដែរ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងបន្តដំណើរការកាត់ក្តីទៅលើជនជាប់ចោទពីររូបផ្សេងទៀតដែលជាអតីតមេដឹកនាំខ្មែរក្រហម រួមមាន នួន ជា និង ខៀវ សំផន ។ បុគ្គលម្នាក់ៗមានការយល់ឃើញខុសគ្នាទៅលើអត្ថន័យនៃពាក្យ "យុត្តិធម៌" ហើយថាតើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះខ្មែរក្រហមដែរឬយ៉ាងណានោះជាការយល់ឃើញរបស់ជនរងគ្រោះម្នាក់ៗ ។

**រ៉េនដល ដឺហ្វាលកូ, ម៉ែន ពិចិត្រ និង លន់ ដាលីន**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី "សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្លាន" ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០៩២ ១៦៨ ៥៤៣ ។

***សូមអរគុណ!***

# ការរៀបចំសំណង ការប្រឈមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

*(តពីលេខមុន)*

*ទិដ្ឋភាពដ៏សំខាន់នៃសេចក្តីសម្រេចក្នុងសំណុំរឿង ឡូបានហ្គា ត្រូវបានប្តឹងសារទុក្ខ ។ ផ្នែកជាប់ពាក់ព័ន្ធជាច្រើនក្នុងអត្ថបទនេះ គឺថា ក្រុមការពារក្តី និងជនរងគ្រោះជំទាស់ទៅនឹងការផ្ទេរការទទួលខុសត្រូវរបស់តុលាការទៅមូលនិធិសំណងជនរងគ្រោះ ដោយលើកឡើងថា នេះគឺជាការរំលោភលក្ខន្តិកៈទីក្រុងរ៉ូម ។ ក្រុមការពារក្តី និងជនរងគ្រោះជំទាស់ទៅនឹងការបង្វែរការត្រួតពិនិត្យដំណើរការនីតិវិធីក្នុងការផ្តល់សំណងដល់អង្គជំនុំជម្រះ ដោយលើកឡើងថា នេះគឺជាការរំលោភមាត្រា ៧៨(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងពិចារណាបទដ្ឋាននៃភ័ស្តុតាងដែលត្រូវបានកំណត់សម្រាប់បង្កើតសម្ពន្ធហេតុដែលទាក់ទងទៅនឹងការផ្តល់សំណង ដែលក្រុមការពារក្តីបានលើកឡើងថា វាមិនច្បាស់លាស់រហូតដល់មូលនិធិសំណងជនរងគ្រោះ មិនអាចអនុវត្តបានដែលមិនមានជាអង្គភាពកាត់សេចក្តី ហើយវាមិនអនុញ្ញាតឲ្យក្រុមការពារក្តីឆ្លើយតបទៅនឹងការចោទប្រកាន់របស់ជនរងគ្រោះឡើយ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិមិនទាន់បានចេញសេចក្តីសម្រេចនៅឡើយទេ ។ ប៉ុន្តែភាពលំបាកដែលគោលការណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងគួរតែបង្ហាញយ៉ាងច្បាស់ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយគួរតែប្រាប់អំពីសេចក្តីសម្រេចរបស់គោលការណ៍នោះដល់ការផ្តល់សំណង ។ ជាពិសេស អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកត់សម្គាល់អំពីថាតើការផ្តល់ថវិកាត្រូវបានកំណត់ក្នុងគម្រោងផ្តល់សំណងដោយរបៀបណា និងពេលណា ព្រមទាំងការយល់ឃើញរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលថា ការត្រួតពិនិត្យរបស់តុលាការត្រូវតែធ្វើឡើងតាមរយៈដំណើរការផ្តល់សំណង ។*

***ឃ) ការកែប្រែវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីការផ្តល់សំណង បានធ្វើឲ្យក្របខណ្ឌផ្លូវច្បាប់ស្តីពីការផ្តល់សំណងរបស់តុលាការកាន់តែមានលក្ខណៈស្របវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។***

*ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនមិនពេញចិត្តជាមួយនឹងការផ្តល់សំណង ដែលបានកំណត់ក្នុងសំណុំរឿង០០១នោះឡើយ ។ ការប្រតិកម្មតបបានជំរុញឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើការកែប្រែវិធានផ្ទៃក្នុងរបស់ខ្លួនស្តីពីការផ្តល់សំណង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើវិសោធនកម្មវិធានផ្ទៃក្នុង ក្នុងការផ្តល់មធ្យោបាយផ្សេងដើម្បីផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដើម្បីពង្រឹងអង្គភាពគាំពារជនរងគ្រោះ ។ វិធានថ្មីបានផ្តល់ផ្លូវពីរផ្សេង ក្នុងការផ្តល់សំណង និងការអនុវត្តគម្រោងសម្រាប់ផ្តល់អត្ថប្រយោជន៍ដល់ជនរងគ្រោះ ក្រៅពីការជំនុំជម្រះ ។ មធ្យោបាយជួយសង្គ្រោះជនរងគ្រោះបីយ៉ាងរួមមាន ទី១) ចុងចោទត្រូវផ្តល់ថវិកាក្នុងការផ្តល់សំណង ដែលបង្គាប់ដោយតុលាការ ឬតាមរយៈការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ទី២) ការផ្តល់សំណងជាថវិកាតាមរយៈជំនួយខាងក្រៅដែលបង្គាប់ដោយតុលាការ ឬតាមរយៈ «គម្រោងផ្តួចផ្តើមក្នុងការផ្តល់សំណង» ទី៣) ចំណាត់ការក្រៅប្រព័ន្ធតុលាការអាចត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តដោយអង្គភាពគាំពារជនរងគ្រោះ មុនពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចេញសេចក្តីសម្រេចផ្តន្ទាទោស ។ មានភាពច្របូកច្របល់មួយចំនួននៅក្នុងពាក្យពេចន៍ ដែលការផ្តល់សំណង ដែលបង្គាប់ដោយតុលាការ ជារឿយៗបង្កភាពច្របូកច្របល់ក្នុងគម្រោងផ្តល់សំណងនៅក្រោមបរិបទតុលាការ ហើយជួនកាលជាមួយនឹងជំនួយអភិវឌ្ឍន៍ទៅ ។ អត្ថបទនេះនឹងផ្តោតលើការផ្តល់សំណង ដែលបង្គាប់*

ដោយតុលាការ ដោយផ្តោតជាចម្បងដល់គម្រោងផ្តួចផ្តើមក្នុងការផ្តល់សំណង ។ ការផ្តល់សំណងដែលបង្គាប់ដោយតុលាការមានសារសំខាន់ ដោយសារការផ្តល់សំណងនោះបានផ្តល់នូវនិមិត្តរូបផ្លូវច្បាប់ តាមរយៈការផ្សារភ្ជាប់ជំនួយ ទៅនឹងការផ្តន្ទាទោសបទឧក្រិដ្ឋ ហើយបានបង្កើតនូវអ្វីដែលមិនធ្លាប់មានពីមុន ។ ដោយសារតុលាការព្រហ្មទណ្ឌអន្តរជាតិដំបូងបានបង្គាប់ឲ្យផ្តល់សំណង អ្វីដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតឡើងពីមុនទាក់ទងទៅនឹងគម្រោងផ្តល់សំណង នឹងជះឥទ្ធិពលអាក្រក់ដល់ទិដ្ឋភាពច្បាប់អន្តរជាតិ ។

### ៤) ការបកស្រាយផ្លូវច្បាប់ចំពោះការទាមទារឲ្យមានប្រសិទ្ធភាព និងតម្រូវការសម្រាប់ការទទួលបានថវិកា ។

ក) ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតនូវសំណើទាមទារឲ្យមានប្រសិទ្ធភាពដែលកើតចេញពីបទដ្ឋាន និងការអនុវត្តរបស់អន្តរជាតិសម្រាប់ការផ្តល់សំណង ។

ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានសំណងដ៏មានប្រសិទ្ធភាពក្រោមបទដ្ឋានដែលបង្កើតឡើងដោយអន្តរជាតិ ។ តុលាការបានបកស្រាយអំពីការផ្តល់សំណងដ៏មានប្រសិទ្ធភាពដែលថវិកាអាចទទួលបានត្រូវបានកំណត់រួចជាស្រេច ។ ទី២) ដែលមិនទាមទារឲ្យមានការត្រួតពិនិត្យដ៏សាំញ៉ាំ និងការគ្រប់គ្រងដែលហួសពីអាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទី៣) មិនបង្វែរការទទួលខុសត្រូវទៅឲ្យរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យ ។ ការទាមទារឲ្យមានការផ្តល់សំណងប្រកបដោយប្រសិទ្ធភាព ដែលបង្កើតឡើងដោយតុលាការបានធ្វើឲ្យមានការប្រឈមយ៉ាងសំខាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ។ ជាពិសេស ទី១) នៅពេលដែលជនជាប់ចោទ ត្រូវបានប្រកាសថា ជាជនក្រីក្រ ។ ទី២) អង្គភាពគាំពារជនរងគ្រោះខ្វះថវិកា ។ ទី៣) សំណើសុំឲ្យមានសំណងភាគច្រើននឹងទាមទារឲ្យមានការគ្រប់គ្រង និងការត្រួតពិនិត្យ បន្ទាប់ពីសំណុំរឿង០០២បានបញ្ចប់ ប្រសិនបើរដ្ឋាភិបាលកម្ពុជាចូលរួមក្នុងការត្រួតពិនិត្យ និងការជំរុញឲ្យមានការផ្តល់សំណង ។ ការទាមទារឲ្យមានប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកើតចេញពីបទដ្ឋាន និងការអនុវត្តរបស់អន្តរជាតិ ។ ក្នុងសំណុំរឿង០០២ តុលាការគួរតែធ្វើឲ្យយុត្តាធិការផ្តល់សំណងរបស់ខ្លួនមានលក្ខណៈស្របគ្នាទៅនឹងយុត្តាធិការរបស់តុលាការអន្តរជាតិ ជាពិសេសយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រើប្រាស់សំណើទាមទារឲ្យមានប្រសិទ្ធភាពនៅពេលដែលកំណត់នូវការផ្តល់សំណង ។ ការប្រើប្រាស់សំណើទាមទារឲ្យមានប្រសិទ្ធភាពរបស់តុលាការ កើតចេញពីការអនុវត្តរបស់អន្តរជាតិ ។ សំណុំរឿងតែមួយប៉ុណ្ណោះដែលលើកឡើងដើម្បីគាំទ្រ និងទាញហេតុផលដល់សំណើទាមទារឲ្យមានប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺសំណុំរឿង ECHR's B and L v. United Kingdom ។ តុលាការមានភាពច្រឡំក្នុងការយល់ដឹងអំពីសំណុំរឿង ។ នៅក្នុងសំណុំរឿង ECHR's B and L v. United Kingdom តុលាការសិទ្ធិមនុស្សអឺរ៉ុប បានពិពណ៌នាអំពីប្រសិទ្ធភាពក្នុងបរិបទនៃការប្រើប្រាស់ដំណោះស្រាយក្នុងស្រុក ឬក៏គោលការណ៍ច្បាប់ ដែលអ្នកដាក់ពាក្យស្នើសុំដំបូងត្រូវតែប្រើប្រាស់ដំណោះស្រាយក្នុងវគ្គប្រព័ន្ធច្បាប់ក្នុងស្រុក មុនពេលដែលអាចប្រើប្រាស់តុលាការក្នុងតំបន់ ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបមិនបានប្រើប្រាស់ "ប្រសិទ្ធភាព" ដើម្បីទាញហេតុផលមិនផ្តល់សំណងនោះឡើយ ។ ពិតប្រាកដណាស់ ប្រសិទ្ធភាព មិនមែនជាផ្នែកមួយនៃការវិភាគអំពីការខូចខាតនោះឡើយ ។ ច្បាប់សន្ធិសញ្ញាតុលាការសិទ្ធិមនុស្សអឺរ៉ុប "ប្រសិទ្ធភាព"

គម្រោងឃ្លាំមើល
តុលាការខ្មែរក្រហម
CAMBODIA TRIBUNAL MONITOR
តាមដានដំណើរកាត់ទោស ករណី០០២ រៀងរាល់ថ្ងៃ
ចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ តទៅ
សូមចុច www.cambodiatribunal.org

សំដៅទៅរកការវិភាគដែលតុលាការធ្វើឡើងចំពោះថាតើសំណង ត្រូវផ្ដល់ដោយតុលាការក្នុងស្រុក ហើយបានផ្ដល់ឲ្យអ្នកដាក់ពាក្យ ស្នើសុំនូវការកែតម្រូវគ្រប់គ្រាន់ ។ ប្រសិនបើសំណងមិនមាននោះ ទេ អ្នកដាក់ពាក្យស្នើសុំប្រហែលជាមានជំហរ ក្នុងការស្វែងរកការ កែតម្រូវបន្ថែមនៅចំពោះមុខតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប ។ ក្នុងច្បាប់តុលាការសិទ្ធិមនុស្សអឺរ៉ុប ការទាមទារឲ្យមានប្រសិទ្ធភាព ធានាថា ជនរងគ្រោះមានឱកាសក្នុងការទាមទារសំណងគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ។ អង្គភាពសិទ្ធិមនុស្សអន្តរជាតិ បានក្លាយទៅ ជាវេទិកានៃដំណោះស្រាយចុងក្រោយ ក្នុងការជួយបុគ្គលដែល រងគ្រោះពីសំណាក់ជនដាប់ចោទ ។ សរុបសេចក្ដីមក ការទាមទារឲ្យ មានប្រសិទ្ធភាព ត្រូវបានប្រើប្រាស់ដើម្បីវិភាគផលប៉ះពាល់នៃ ការផ្ដល់សំណងដែលបានសម្រេចរួចជាស្រេច ជាជាងតុលាការ ធ្វើការសាកល្បង មុនពេលផ្ដល់សំណង ។ ប្រសិនបើមានការទាម ទារឲ្យមានប្រសិទ្ធភាព ត្រូវបានប្រើប្រាស់ដើម្បីពង្រីកអំណាច របស់តុលាការតាមរយៈការផ្ដល់ជំហរ ការផ្ដល់អំណាចតុលាការ ដើម្បីស្ដាប់សំណុំរឿង ឬតាមរយៈការផ្ដល់ឲ្យតុលាការនូវកាតព្វកិច្ច ក្នុងការគិតពិចារណាកំណត់ថាតើខ្លួនអាចផ្ដល់សំណង ដែលមាន ប្រសិទ្ធភាពដោយរបៀបណា ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាមានការភាន់ច្រឡំក្នុងការបកស្រាយអំពីសំណើទាមទារនេះ ។

សំណើទាមទារឲ្យមានប្រសិទ្ធភាពត្រូវបានប្រើប្រាស់ក្នុង បរិបទដទៃ ដើម្បីពង្រីកអំណាចរបស់តុលាការក្នុងការផ្ដល់សំណង ដល់ជនរងគ្រោះ ជាជាងទប់ស្កាត់សមត្ថភាពរបស់តុលាការក្នុងការ ចេញសេចក្ដីបង្គាប់ផ្ដល់សំណង ។ ក្នុងសំណុំរឿង កូហ្វូ ចាន់ នែល តុលាការយុត្តិធម៌អន្តរជាតិបានប្រើប្រាស់គោលការណ៍ "ប្រសិទ្ធ ភាព" ដើម្បីបន្តការសាកសួរនៅចំពោះមុខខ្លួន ។ ក្រៅពីនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានប្រើប្រាស់ ទស្សនៈនៃសំណងប្រកបដោយប្រសិទ្ធភាពដែលកើតចេញពីការ បកស្រាយលក្ខន្តិកៈរបស់ខ្លួន ។ ក្នុងសេចក្ដីសម្រេចលើការផ្ដល់ សំណងសមស្រប តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ជំនុំជម្រះ ប្រទេសរ៉្វាន់ដា បានផ្ដល់សំណងសម្រាប់ការរំលោភសិទ្ធិជនជាប់ ចោទក្នុងការទទួលបានជំនួយផ្លូវច្បាប់ពីសំណាក់ការិយាល័យ រដ្ឋបាល ថ្វីបើការពិតដែលថាលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌ អន្តរជាតិសម្រាប់ជំនុំជម្រះប្រទេសរ៉្វាន់ដា មិនបានផ្ដល់ឲ្យតុលាការ នូវសិទ្ធិក្នុងការផ្ដល់សំណង ។ តុលាការបានលើកឡើងអំពីកាតព្វកិច្ច របស់ខ្លួនដើម្បីសម្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក្នុងការ ទាញហេតុផលការបកស្រាយលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ៉្វាន់ដា ។ តុលាការបានលើកឡើងក្នុងមាត្រា២(៣) (ក) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលធានានូវសិទ្ធិក្នុងការទទួលបានសំណងប្រកបដោយប្រសិទ្ធភាព ។ តុលាការបានចាត់ទុកកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ថាជាអំណាចជំរុញ ។ យោងតាមតុលាការ ការ ចេញសេចក្ដីសម្រេចផ្ដល់សំណងប្រកបដោយប្រសិទ្ធភាព មាន សារសំខាន់ក្នុងការអនុវត្តតួនាទីរបស់តុលាការរួមមានកិច្ចការផ្សារ រដ្ឋបាលក្នុងការស្វែងរកយុត្តិធម៌ដ៏ត្រឹមត្រូវ និងសមស្រប ។ ជាថ្មី ម្ដងទៀត តម្រូវការក្នុងការផ្ដល់សំណងប្រកបដោយប្រសិទ្ធភាព មិនត្រូវបានប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា នៅពេលដែលពិចារណាអំពីការខូចខាតដែលត្រូវទាញ ហេតុផល អំពីការមិនផ្ដល់សំណង ដែលជាកត្តាលំបាកក្នុងការ អនុវត្ត ប៉ុន្តែជាតម្រូវការក្នុងការពង្រីកសមត្ថភាពរបស់តុលាការ ក្នុងការផ្ដល់សំណងគ្រប់គ្រាន់ដែលតុលាការមិនមានការយល់ស្រប តាមលក្ខន្តិកៈក្នុងការផ្ដល់សំណង ។

កត្តា២ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានដាក់បញ្ចូលក្នុងការទាមទារសំណងប្រកបដោយប្រសិទ្ធភាព កើតចេញពីការអនុវត្តរបស់អន្តរជាតិ ជាពិសេស តម្រូវការផ្នែក ថវិកា និងភាពអសមត្ថភាពរបស់តុលាការក្នុងការចេញសេចក្ដី បង្គាប់សំណង ដែលទាមទារឲ្យមានការគ្រប់គ្រង និងការត្រួតពិនិត្យ បន្ទាប់ពីសំណុំរឿងបានបញ្ចប់ ។

១) ថវិកាមិនគួរជាកត្តាកំណត់ នៅពេលដែលសម្រេចចិត្តថា តើត្រូវចេញសេចក្ដីបង្គាប់សំណងសមូហភាពឬអត់ ។

ក្រោមសំណើទាមទារឲ្យមានប្រសិទ្ធភាព ដែលបានបង្កើត ឡើងក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបានកត់ សម្គាល់ថា ចាំបាច់ត្រូវមានថវិកាសម្រាប់អនុវត្តតាមសេចក្ដី បង្គាប់ឲ្យផ្ដល់សំណង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្ដីថ្លែងការណ៍ទាក់ទងនឹងភាពក្រីក្ររបស់ ឌុច ដែល

បដិសេធមិនព្រមផ្តល់សំណើក្នុងការផ្តល់សំណង ដោយសារ ឌុច មិនមានថវិកាផ្តល់តាមសំណើនោះបាន ។ អង្គជំនុំជម្រះតុលាការកំពូល មានការព្រួយបារម្ភចំពោះការជំរុញឲ្យមានការចេញសេចក្តីបង្គាប់ផ្តល់សំណងរបស់ខ្លួន ។ តុលាការបានសរសេរថាវាមានសារសំខាន់ក្នុងការកំណត់សំណង ដែលអាចត្រូវបានអនុវត្តជាក់ស្តែង ។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល សំណងដែលបង្គាប់ប្រឆាំង ឌុច មិនអាចត្រូវបានបង្គាប់បាននោះឡើយ ។ វាគ្រាន់តែជា "ការសន្មត" ។ អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញអំពីលទ្ធភាព ដែល ឌុច នឹងទទួលបានចំណូលនាពេលអនាគត ឬក៏ជាភាគីទី៣ នឹងផ្តល់ថវិកាក្នុងការផ្តល់សំណង ឬមិនមានលទ្ធភាពក្នុងការចេញសេចក្តីបង្គាប់សំណង ។ ការចេញសេចក្តីបង្គាប់បែបនោះនឹងបំភ័ន្តគោលបំណងក្នុងការផ្តល់សំណងប្រកបដោយប្រសិទ្ធភាព ហើយវាធ្វើឲ្យមានភាពច្របូកច្របល់ និងបំបាក់ទឹកចិត្តដល់ជនរងគ្រោះ ។ តុលាការមិនបានផ្តល់សំណើសុំសំណងមួយចំនួននោះឡើយ ដោយសារសំណើនោះមិនបានឆ្លើយតបទៅនឹងតម្រូវការថវិកា ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងទំនងជាបកស្រាយអំពីគម្រោងផ្តួចផ្តើមក្នុងការផ្តល់សំណងដើម្បីទាមទារឲ្យមានថវិកានៅក្នុងសំណុំរឿង០០២ ។ អង្គជំនុំជម្រះតុលាការកំពូលទំនងជាកំណត់នូវតម្រូវការនេះក្នុងកំណត់សំគាល់ក្នុងសំណុំរឿង០០១ ដោយសរសេរថា "ទោះបីជាវិធានផ្ទៃក្នុង ត្រូវបានធ្វើវិសោធនកម្មថ្មី ដើម្បីពង្រីកមធ្យោបាយក្នុងការផ្តល់សំណងដែលមាននៅក្នុងអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា រួមមានថវិកាផ្នែកខាងក្រៅសម្រាប់ការផ្តល់សំណង មធ្យោបាយនោះ នៅតែធានាហេតុផលដូចគ្នាដែលពិចារណាអំពីការដែលមានថវិកា ។ ប្រការនេះស្របជាមួយនឹងវិធាន ២៣នៃវិធានដែលធ្វើវិសោធនកម្ម ដែលនិយាយថា គម្រោងផ្តួចផ្តើមផ្តល់សំណងត្រូវតែធានាឲ្យមានប្រភពថវិកាផ្នែកខាងក្រៅគ្រប់គ្រាន់ ។ ក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងត្រូវកំណត់ថវិកាគ្រប់គ្រាន់ ដូចដែលបានចែងក្នុងវិធាន២៣ ហើយត្រូវសម្រេចថាតើថវិកាកម្រិតណា ដែលអង្គភាពគាំពារជនរងគ្រោះត្រូវតែសម្រេចមុនពេលចេញសេចក្តីបង្គាប់ ប្រសិនបើ មានថវិកានោះ ។ ប៉ុន្តែនៅមានសំណួរចោទសួរមួយចំនួន ។ តើគម្រោងនោះត្រូវតែបានគាំទ្រផ្នែកថវិកាពេញលេញមុនពេលដែលតុលាការទទួលស្គាល់គម្រោងនោះថាជាសំណង? ប្រសិនបើគម្រោងនោះត្រូវបានគាំពារផ្នែកថវិកាពេញលេញ តើការទទួលស្គាល់សំណើស្នើសុំសំណងមានឥទ្ធិពលលើអ្វី? តើតុលាការនឹងធានាថា គម្រោងសំណងត្រូវបានកំណត់តាមរយៈការទាមទាររបស់ជនរងគ្រោះដោយរបៀបណា ដោយសារវាជំទាស់ទៅនឹងចំណាប់អារម្មណ៍និងរបៀបវារៈរបស់ម្ចាស់ជំនួយ? ទន្ទឹមពេលដែលអាណត្តិក្នុងការផ្តល់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានលក្ខណៈដោយឡែកតម្រូវការ ផ្នែកថវិការបស់តុលាការ កើតចេញពីច្បាប់ប្រទេសកម្ពុជា, ការអនុវត្តរបស់អន្តរជាតិ និងវិសាលភាពនៃការខូចខាត ។ ក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែដាក់ការគណនាអំពីការផ្តល់សំណងស្របជាមួយនឹងអ្វីដែលមិនធ្លាប់មានពីមុនរបស់អន្តរជាតិ ។

ការបកស្រាយអំពីផលប៉ះពាល់អំពីភាពក្រីក្ររបស់ ឌុច ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយអនុលោមតាមក្រមនិតិវិធីព្រហ្មទណ្ឌប្រទេសកម្ពុជាឆ្នាំ២០០៧ ភាពក្រីក្ររបស់ ឌុច នឹងមិនរារាំងតុលាការពីការផ្តល់សំណងនោះទេ ។ ក្រមនីតិវិធីនោះ សន្មតថាសូម្បីតែចុងចោទរដ្ឋប្បវេណី មានភាពក្រីក្រ គាត់អាចទទួលបានចំណូលនៅពេលអនាគត ឬភាគីទីបី ប្រហែលជាអាចផ្តល់សំណងជំនួស ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលបានចែងថា ភាពក្រីក្ររបស់ ឌុច បានបង្ហាញអំពីរបាំងដែលពុំអាចជម្នះបាន ក្នុងការផ្តល់សំណងដែលទាមទារថវិកា ។

**(នៅមានត)**

**គ្រីស្ទីន ប័រគ័រលី**

> ◆ និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា
>
> ◆ រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬកា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល : truthpechet@dccam.org ។

**◆ ទីកន្លែង : អាគារ “ក” ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# នីកូឡាស គុំចាន់
# បញ្ជាក់ពីចំណង់ស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា

*នីកូឡាស គុំចាន់ សហព្រះរាជអាជ្ញាអន្តរជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលទើបកាន់តំណែងថ្មីផ្តល់បទសម្ភាសជាមួយ កង កល្យាណ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ នៅសាលាក្តីខ្មែរក្រហម ។*



សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គុំចាន់

**សំណួរ ៖** កាលពីពេលថ្មីៗនេះ សាលាក្តីខ្មែរក្រហមបានប្រកាសតែងតាំងសហព្រះរាជអាជ្ញាអន្តរជាតិថ្មីមួយរូបទៀតមកជំនួសដំណែងលោក អេនឌ្រូ ខេលី ដែលបានលាឈប់ពីដំណែងសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា កាលពីខែកញ្ញាកន្លងទៅ ។ សហព្រះរាជអាជ្ញាអន្តរជាតិដែលបានមកជំនួសដំណែងលោក អេនឌ្រូ ខេលី នេះ គឺជាលោក នីកូឡាស គុំចាន់ សញ្ជាតិអាមេរិក ។ តើលោកអាចប្រាប់អំពីប្រវត្តិលោក មុនមកកាន់តួនាទីដែរឬទេ?

**ចម្លើយ ៖** ខ្ញុំមានសេចក្តីរីករាយនិងជម្រាបដល់ទស្សនិកជន និងប្រជាជនខ្មែរទាំងអស់អំពីការងារនៅសាលាក្តីនេះ ។ ខ្ញុំធ្លាប់គឺជាមេធាវីនៅទីក្រុងឡូសអែនជឺឡេស សហរដ្ឋអាមេរិកអស់រយៈពេលសាមសិបបួនឆ្នាំ ។ ក្រោយមក ខ្ញុំទៅធ្វើការនៅតុលាការអន្តរជាតិមួយចំនួនដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ទីម័រខាងកើត បូស្នៀហេសាហ្គោវីណាជាដើម ។ ខ្ញុំបានធ្វើការជាប្រធានកម្មវិធីសិទ្ធិមនុស្សនៅប្រទេសកូឡុំបៀទីបអាមេរិកខាងត្បូង ហើយបន្ទាប់មកខ្ញុំធ្វើការនៅតុលាការពិសេសសម្រាប់អតីតប្រទេសសេរ៉ាឡេអូនប្រហែលជាមួយឆ្នាំកន្លះ ដោយធ្វើការកាត់ក្តីលោក ឆាល ថៃល័រ ។ អង្គជំនុំជម្រះនោះធ្វើឡើងនៅទីក្រុងឡាអេ ប្រទេសហូឡង់ ។ ឆាល ថៃល័រ មានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មជាច្រើន និងត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន៥០ឆ្នាំ ។ នៅថ្ងៃទី៣១ ខែកញ្ញា ឆ្នាំ២០១៣នេះ ខ្ញុំបានជិះយន្តហោះមក អ.វ.ត.ក ដើម្បីមកឲ្យទាន់សវនាការបញ្ចប់សេចក្តីសន្និដ្ឋានពិភាក្សាដេញដោល ។

**សំណួរ ៖** លោកបានធ្វើការងារជាច្រើនជាលក្ខណៈអន្តរជាតិ និងកម្រិតឧក្រិដ្ឋកម្មអន្តរជាតិ ។ ហេតុអ្វីបានជាលោកឈប់ធ្វើការនៅតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីមកកាន់មុខតួនាទីការងារនៅក្នុងប្រទេសកម្ពុជា?

**ចម្លើយ ៖** មុននឹងខ្ញុំមកទីនេះ ខ្ញុំបានបញ្ចប់រឿងក្តី ឆាល ថៃល័រ រួចហើយ ហើយខ្ញុំក៏បានធ្វើការនៅតុលាការអន្តរជាតិទាក់ទងរឿងក្តីនៅ ដាហ្វ័រ ដែរ ។ ខ្ញុំយល់ថា ខ្ញុំមានសំណាងណាស់ដែលបានធ្វើការងារបែបនេះ ។ តុលាការនេះមានសារសំខាន់ដល់សង្គមដែលអំពាវនាវឲ្យមានយុត្តិធម៌ ។ ឪពុកម្តាយនិងជីដូនជីតារបស់ខ្ញុំមានកំណើតនៅប្រទេសមួយដែលមានអំពើហិង្សាកាលពីសម័យសង្គ្រាមលោកលើកទីមួយ ។ បន្ទាប់មក ខ្ញុំមានកិត្តិយសណាស់ដែលបានធ្វើការងារក្នុងផ្នែកនេះ ជាពិសេស ទាក់ទងទៅនឹង

វិស័យយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ។ ហើយក្នុងខណៈពេលដែលមានការវិវឌ្ឍទៅមុខដែរនោះ យើងសង្កេតឃើញមានការអភិវឌ្ឍទៅមុខដែរ គឺការចោទប្រកាន់អ្នកប្រព្រឹត្តឧក្រិដ្ឋទាំងអស់ ។ យើងមិនអាចបញ្ចប់រាល់ការសម្លាប់ទាំងអស់បានទេ ក៏ប៉ុន្តែយើងអាចស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ហើយជាពិសេស យើងនឹងធ្វើការពិនិត្យលើបទឧក្រិដ្ឋធំៗដូចជា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិជាដើម ហើយវាមានសារសំខាន់ណាស់ដែលយើងត្រូវពិនិត្យមើល ហើយធ្វើការចោទប្រកាន់នូវបទឧក្រិដ្ឋទាំងអស់នេះ ដើម្បីជួយឲ្យប្រទេសមួយមានយុត្តិធម៌សម្រាប់អន្តរជាតិ ។

**សំណួរ ៖** តើមានលក្ខណៈយ៉ាងណារវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការអន្តរជាតិដែលលោកបានបំពេញការងារកន្លងមក?

**ចម្លើយ ៖** នៅក្នុងតុលាការផ្សេងៗទៀតដែលខ្ញុំបានធ្វើនោះ គឺថាមានភាពខុសគ្នាក្នុងរចនាសម្ព័ន្ធតិចតួច រីឯ អ.វ.ត.ក ជាតុលាការដែលធ្វើការជាគំរូមួយ ដែលមានចម្រុះជាតិ និងអន្តរជាតិធ្វើការជាមួយគ្នា ។ ពេលខ្ញុំមកដល់ទីនេះ ខ្ញុំសង្កេតឃើញថា នៅក្នុងការិយាល័យរបស់ខ្ញុំ មានកិច្ចសហប្រតិបត្តិការគ្នាជាច្រើនរវាងបុគ្គលិកជាតិនិងអន្តរជាតិ ។ យើងរៀនពីគ្នាទៅវិញទៅមក ចែករំលែកការងារគ្នាទៅវិញទៅមក ។ កិច្ចព្រមព្រៀងបានបង្កើតតុលាការនេះឡើង គឺកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា ។ តុលាការនេះអាចដំណើរការទៅបានដោយមូលនិធិស្ម័គ្រចិត្ត ហើយជារៀងរាល់ឆ្នាំ តុលាការស្វែងរកមូលនិធិដើម្បីបន្តកិច្ចការផ្ទាល់ខ្លួនទៅទៀត ។ ក្រុមប្រឹក្សាអង្គការសហប្រជាជាតិមានឧត្តមក្រុមប្រឹក្សាដែលបានសម្រេចថា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីមានស្ថេរភាពថវិកា ប៉ុន្តែតុលាការនេះមិនសូវមានស្ថេរភាពទេ ដោយសារយើងពឹងផ្អែកលើមូលនិធិស្ម័គ្រចិត្ត ។ ប៉ុន្តែ តាមបទពិសោធគឺថា ម្ចាស់ជំនួយនឹងស្ម័គ្រចិត្តផ្តល់ជំនួយឲ្យយើងបន្តទៀត ដែលដំណើរការនោះគឺទៅមុខរហូតដល់យើងបញ្ចប់ការងាររបស់យើង ។ តុលាការនេះគឺដំណើរការមួយហើយយើងមិនចង់ឲ្យជាតុលាការអចិន្ត្រៃយ៍នោះទេ ក៏ប៉ុន្តែវាត្រូវតែមានអាណត្តិមួយ ត្រូវបញ្ចប់នូវកិច្ចការងាររបស់ខ្លួនដែលស្វែងរកយុត្តិធម៌មួយចំនួនតាមរយៈពេលដែលយើងនៅសេសសល់ដើម្បីឲ្យការងារយើងមានប្រសិទ្ធភាពទៅតាមការកំណត់នោះ ។ យើងនឹងអាចសម្រេចលទ្ធផលដូចដែលយើងបានគ្រោងទុក ។

**សំណួរ ៖** អង្គការសហប្រជាជាតិ និងម្ចាស់ជំនួយបរទេសបានចំណាយពេលវេលានិងថវិការយ៉ាងច្រើនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តើហេតុអ្វីបានជាតុលាការមានសារសំខាន់ចំពោះអង្គការសហប្រជាជាតិ និងម្ចាស់ជំនួយបរទេសទាំងនោះ?

**ចម្លើយ ៖** ខ្ញុំយល់ថា តើយើងរស់នៅក្នុងពិភពណា ។ តើយើងចង់ឲ្យពិភពលោកមានលក្ខណៈដូចម្តេច ។ តើយើងចង់បានពិភពលោកមួយដែលមានបទឧក្រិដ្ឋធ្ងន់ធ្ងរហ្នឹងនៅសេសសល់ឬក៏យើងបញ្ចប់វាឬក៏យើងធ្វើមិនដឹងមិនឮ ។ តើយើងចង់រស់នៅក្នុងពិភពលោកមួយដែលមនុស្សលោកទាំងអស់ដែលសហគមន៍អន្តរជាតិទទួលស្គាល់អំពីការទទួលខុសត្រូវរបស់ខ្លួនពីអំពើឧក្រិដ្ឋហើយរកយុត្តិធម៌ចំពោះបទឧក្រិដ្ឋនោះ ។ នេះហើយជាគំនិតដែលសហគមន៍អន្តរជាតិចង់ផ្តល់មូលនិធិឲ្យតុលាការ ហើយយើងគិតថាអាចបញ្ចប់ការងាររបស់យើងនៅទីនេះបាន ។ មានមនុស្សជាច្រើនដែលមិនដឹងមិនឮថាមានបទឧក្រិដ្ឋនោះ ប៉ុន្តែក៏មិនបានចាត់វិធានការដើម្បីបញ្ឈប់ដែរ ។ ប៉ុន្តែយើង ត្រូវកែប្រែទស្សនៈនេះ ។ យើងអាចរកភស្តុតាង ហើយនិងបង្កើតជាឯកសារប្រវត្តិសាស្ត្រ ហើយនិងជំនុំជម្រះ និងស្វែងរកយុត្តិធម៌ដើម្បីរកឲ្យឃើញថាតើអ្វីពិតជាបានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ ។

**សំណួរ ៖** តុលាការនេះត្រូវបានអង្គការសហប្រជាជាតិ រួមទាំងម្ចាស់ជំនួយដទៃសុទ្ធតែផ្តល់សារសំខាន់យ៉ាងខ្លាំងណាស់ចំពោះការស្វែងរកយុត្តិធម៌នេះ ។ តើលោកគិតថាតុលាការបានរួមចំណែកជួយប្រទេសកម្ពុជាដែរឬទេ?

**ចម្លើយ ៖** តុលាការនេះបង្កើតឡើងដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយមិនមែនជាតុលាការដែលនឹងចោទប្រកាន់គ្រប់បុគ្គលទាំងអស់ដែលប្រព្រឹត្តបទឧក្រិដ្ឋនៅសម័យកាលនោះទេ ។ យើងក៏មិនមានចេតនាធ្វើដូច្នោះដែរ ។ យើងមានយុត្តាធិការកម្រិតណាស់ចំពោះតែមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ ប៉ុន្តែការជំនុំជម្រះជនដែលទទួលខុសត្រូវខ្ពស់បំផុត

មេដឹកនាំជាន់ខ្ពស់នេះ ខ្ញុំជឿជាក់ថា នឹងអាចផ្តល់នូវការពេញចិត្ត ដល់ជនរងគ្រោះរាប់លាននាក់ ជាពិសេស ចំពោះបទល្មើសដែលពួកគាត់បានទទួលរង ហើយនឹងអាចផ្តល់ដល់សង្គមនូវការជឿជាក់មួយថា បទឧក្រិដ្ឋ និងការឈឺចាប់មិនត្រូវបានបំភ្លេចចោលទេ ហើយពន្លឺយុត្តិធម៌ត្រូវតែបង្ហាញខ្លួននៅកម្ពុជានិងនៅទូទាំងពិភពលោក ។ អ្នកដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់នេះ មិនអាចរួចខ្លួននៅក្នុងនិទ្ទណ្ឌភាពជារៀងរហូតទេ ។ អ្វីដែលសំខាន់នេះគឺថាធ្វើម៉េចកុំឲ្យបទឧក្រិដ្ឋហ្នឹងកើតឡើងម្តងទៀត និងធ្វើឲ្យប្រជាជនជឿជាក់ថាគេអាចរស់នៅក្នុងសង្គមមួយដែលមានយុត្តិធម៌ត្រឹមត្រូវ ។

***សំណួរ*** ៖ មកដល់បច្ចុប្បន្ននេះ តុលាការបានបញ្ចប់ជំនុំជម្រះក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ លោកបានមកដល់ ចំពេលចូលរួមធ្វើអំណះអំណាងទាញហេតុផលចុងក្រោយក្នុងការជំនុំជម្រះក្តី នួន ជា និង ខៀវ សំផន ដំបូងលើបទចោទប្រកាន់ការជម្លៀសប្រជាជននៅទីក្រុងដោយបង្ខំនៅខែមេសា ឆ្នាំ១៩៧៥ ការបន្លាស់ទីប្រជាជននៅតាមជនបទនៅចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ នៅខែមេសា ឆ្នាំ១៩៧៥ ។ តើសាលក្រមអំពីសំណុំរឿងនោះនឹងត្រូវធ្វើឡើងនៅពេលណា? លោកបានស្នើសុំឲ្យមានការកាត់ទោសយ៉ាងដូចម្តេច?

***ចម្លើយ*** ៖ សហព្រះរាជអាជ្ញាជាតិលោកជំទាវ ជា លាង បានស្នើទៅតុលាការឲ្យដាក់ទោសបទឧក្រិដ្ឋនេះ ក្នុងកម្រិតទោសធ្ងន់ដោយជាប់ពន្ធនាគារអស់មួយជីវិត ។ យើងបានស្នើបែបនោះដោយផ្អែកលើអង្គហេតុថា ការកាប់សម្លាប់នៅទួលពោធិ៍ជ្រៃ ហើយនិងការជម្លៀសដោយបង្ខំនាំឲ្យមានការស្លាប់មនុស្សជាច្រើន ហើយនិងការបង្កឈឺចាប់ទៅដល់មនុស្សរាប់លាននាក់ត្រូវបានបង្ខំឲ្យចេញពីតំបន់មួយទៅតំបន់មួយ ពីភូមិភាគមួយទៅភូមិភាគមួយទៀត ។ នេះជាបទឧក្រិដ្ឋដ៏ធំធេងមួយ ។ ខ្មែរក្រហមបានជម្លៀសមនុស្សចេញពីទីក្រុង ដើរហាលថ្ងៃតាមផ្លូវ ហើយស្ត្រីមានផ្ទៃពោះ ចាស់ជរា កុមារ ក៏មិនត្រូវបានអនុគ្រោះដែរ ។ នេះជាបទចោទប្រកាន់ដ៏ធ្ងន់ធ្ងរណាស់អំពីកំហុសអំពើឧក្រិដ្ឋនោះ ។ ហើយក៏មានបទឧក្រិដ្ឋធ្ងន់ធ្ងរកើតឡើងបន្ទាប់ពីការជម្លៀសនោះដែរ ។ យើងសង្ឃឹមថានឹងអាចជំនុំជម្រះបន្តទៅទៀតរឿងក្តី០០២ ដំណាក់កាលទីពី ដើម្បីបញ្ចប់អង្គហេតុផ្សេងទៀត ការចោទប្រកាន់ផ្សេងទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ។

***សំណួរ*** ៖ តើលោកគិតថា សំណុំរឿង០០២ ដំណាក់កាលទីពីនេះ នឹងអាចចំណាយពេលវេលារហូតដល់ប៉ុន្មានទៀត? យើងឃើញថាគ្រាន់តែសំណុំរឿង០០២ដំណាក់កាលទីមួយនេះគឺបានចាប់ផ្តើមតាំងពីខែវិច្ឆិកា ឆ្នាំ២០១១ មកម្ល៉េះ ។

***ចម្លើយ*** ៖ រឿងក្តីនៃរបបខ្មែរក្រហមជារឿងលំបាក និងស្មុគស្មាញណាស់ហើយ អ.វ.ត.ក ត្រូវការប្រើប្រាស់ការជំនុំជម្រះយូរ គឺថាអាចប្រើ៦ឆ្នាំកន្លះ ចាប់ផ្តើមពីចំណុចចាប់ផ្តើមរហូតដល់បណ្តឹងសាទុក្ខចុងក្រោយ ។ ខ្ញុំជឿជាក់ថា រឿងក្តី០០២ ដំណាក់កាលទីពីនេះ ប្រសិនបើចៅក្រមទទួលយកតាមសំណើរបស់យើងក្នុងការជំនុំជម្រះ នោះគឺថាយើងអាចបញ្ចប់ក្នុងពេលវេលាសមស្រប គឺថាអាចខ្លីជាងរឿងករណី០០២ ដំណាក់កាលទីមួយ ពីព្រោះនោះគឺជាការបន្តនៃការជំនុំជម្រះដដែល ។ ភស្តុតាងភាគច្រើនដែលយើងត្រូវបង្ហាញអំពីការទទួលខុសត្រូវរបស់ ខៀវ សំផន និង នួន ជា នោះគឺថាពួកគាត់ជានរណា? តើពួកគាត់មានដំណែងអ្វីខ្លះ? តើសេចក្តីសម្រេចធ្វើឡើងដូចម្តេចនៅក្នុងថ្នាក់ដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ? តើការប្រាស្រ័យទាក់ទងពីភូមិភាគទៅតំបន់ផ្សេងៗធ្វើឡើងដូចម្តេច? ចៅក្រមបានដឹងហើយថា សាក្សីជាច្រើនត្រូវបានកោះហៅមកសួរដេញដោល និងធ្វើសក្ខីកម្ម ។ ចៅក្រមអាចនឹងយល់ថា ភស្តុតាងមួយចំនួនដែលបានប្រើប្រាស់ស្ថិតនៅរឿងក្តី ០០២ ដំណាក់កាលទីមួយ ក៏ជាផ្នែកនៃភស្តុតាងសម្រាប់វគ្គទីពីដែរ ។ យើងអាចបន្តចាប់ផ្តើមបានឆាប់រហ័ស ។ យើងបានស្នើជាគំនិតថា ចៅក្រមមួយចំនួននៅក្នុងករណី០០២ ដំណាក់កាលទីមួយពិនិត្យមើលនូវការចោទប្រកាន់មួយចំនួនទៀត ។ យើងចង់ដាក់ការជំនុំជម្រះអំពីការដ្ឋានការងារ នៅទូទាំងប្រទេសក្នុងសម័យប្រជាធិបតេយ្យ ។ យើងចង់បង្ហាញថា ខ្មែរក្រហមដាក់មនុស្សឲ្យធ្វើការដោយបង្ខំជាទាសកររហូតដល់អត់អាហារស្លាប់នោះដោយរបៀបណា? យើងក៏នឹងពិនិត្យមើលនូវបទចោទប្រកាន់អំពីមន្ទីរសន្តិសុខទាំងឡាយ គឺមន្ទីរឃុំខ្លួនដែលត្រូវបានបង្កើតឡើងទូទាំងប្រទេស រួមបញ្ចូលទាំងស-២១ ផង ដែលមានមនុស្សរាប់ពាន់នាក់បានរងទារុណកម្ម និងសម្លាប់ និងទីសម្លាប់ ។ បើនិយាយអំពីការរៀប

អាពាហ៍ពិពាហ៍ដោយបង្ខំវិញ ខ្មែរក្រហមបានបង្ខំឲ្យបុរស និងស្ត្រីរៀបការ ហើយបង្ខំឲ្យមានការរំលោភសេពសន្ថវៈផង ហើយនេះជាបទឧក្រិដ្ឋធ្ងន់ធ្ងរណាស់ ។ ការចោទប្រកាន់មួយទៀតគឺការធ្វើទុក្ខបុកម្នេញលើក្រុមសាសនា ដូចព្រះពុទ្ធសាសនា អំពីប្រជាជនចាម និងប្រជាជនវៀតណាមផង ហើយបទចោទមួយចំនួនទៀតដែលយើងត្រូវដាក់មកដេញដោលដើម្បីមកជំនុំជម្រះ ។ យើងនឹងផ្តល់នូវសាក្សីចំនួន៩៤នាក់ និងត្រូវប្រើពេល៩៦ថ្ងៃដើម្បីបញ្ចប់ ។ តាមផែនការរបស់យើង យើងនឹងអាចប្រើពេលមួយឆ្នាំ ឬក៏កន្លះឆ្នាំ ។

***សំណួរ*** ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការកូនកាត់ដែលមានចៅក្រម ព្រះរាជអាជ្ញា មេធាវី និងបុគ្គលិកបម្រើការងារជាជនបរទេស ដែលធ្វើការងារជាមួយចៅក្រម ព្រះរាជអាជ្ញា មេធាវី និងបុគ្គលិកកម្ពុជា ។ តើអ្នកគិតថាប្រព័ន្ធការងារបែបនេះមានលក្ខណៈត្រឹមត្រូវដែរឬទេ? អ្នកធ្វើការជាមួយនឹងសហព្រះរាជអាជ្ញាជាតិ លោកជំទាវ ជា លាង និងព្រះរាជអាជ្ញាជាតិដទៃ ។ តើការងារនេះដំណើរការទៅយ៉ាងដូចម្តេច?

***ចម្លើយ*** ៖ យើងធ្វើការជាក្រុម ហើយយើងរៀនពីគ្នាទៅវិញទៅមក ។ ទោះជាក្នុងចំណោមភាគីអន្តរជាតិក្តី ក៏មកពីប្រទេសផ្សេងពីគ្នា ។ អ្នកទាំងនោះបាននាំយកនូវប្រព័ន្ធច្បាប់ខុសៗគ្នា និតិវិធីច្បាប់ខុសៗគ្នា ។ ដូច្នេះគឺថា នៅក្នុងតុលាការអន្តរជាតិផ្សេងទៀតក៏ដូចគ្នា គឺយើងមានអត្ថប្រយោជន៍ច្រើនណាស់ ហើយយើងតម្រូវឲ្យមានការគាំទ្រអំពីសហសេវិកកម្ពុជា ។ យើងធ្វើសេចក្តីសម្រេចជាមួយគ្នា ដាក់ស្តែងសហសេវិកកម្ពុជាដឹងពីវប្បធម៌ ភូមិសាស្ត្រ ភាសា ដែលយើងជឿជាក់ ហើយពឹងផ្អែកលើគាត់ច្រើន ។ សហសេវិកកម្ពុជាក៏ដឹងអំពីក្រុមនិតិវិធីព្រហ្មទណ្ឌរបស់ខ្លួនគាត់ដែរ ដែលនឹងត្រូវដាក់បញ្ចូលជាមួយក្រុមព្រហ្មទណ្ឌអន្តរជាតិដែលអាចនឹងធ្វើការជំនុំជម្រះរឿងក្តី ដែលមានទំហំធំធេងបែបនេះដែលកើតមានឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ ។ ខ្ញុំក៏បានធ្វើការងារស្រដៀងគ្នានេះដែរនៅក្នុងតុលាការ បូស្នៀ ដែលមានខាងអន្តរជាតិធ្វើការជាមួយភាគីជាតិនៅទីនោះ ទាក់ទងនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម ។ វាមិនមានប្រព័ន្ធច្បាប់ណាមួយល្អឥតខ្ចោះនោះទេ ប៉ុន្តែយើងអាចនាំបទពិសោធរបស់មនុស្សធ្វើការជាមួយគ្នា យើងអាចធ្វើការនេះបានល្អ ។ ដើម្បីធ្វើឲ្យប្រព័ន្ធដំណើរការទៅ យើងត្រូវការភាគីជាតិ និងអន្តរជាតិធ្វើការងារជាមួយគ្នានៅក្នុងបរិស្ថានការងារ ទោះជាយ៉ាងណាក្តី យើងត្រូវមើលការផ្ទុះបញ្ចាំងពីប្រព័ន្ធច្បាប់ដែលយើងមកពីប្រព័ន្ធខុសគ្នាៗដែរ ។

***សំណួរ*** ៖ ឆ្នាំ២០១៤ជិតមកដល់ហើយលោក ហើយលោកប្រហែលជានឹងត្រូវឆ្លងឆ្នាំ និងនៅសប្បាយរីករាយ នៅក្នុងឆ្នាំថ្មីនេះ ។ ប៉ុន្តែបើយើងនិយាយអំពីការងារតុលាការវិញ តើលោករំពឹងថា នៅក្នុងឆ្នាំ២០១៤ ខាងមុខនេះ នឹងមានអ្វីកើតឡើងទៀត?

***ចម្លើយ*** ៖ តុលាការបានលើកឡើងថា នឹងអាចមានសាលក្រមក្នុងពាក់កណ្តាលឆ្នាំក្រោយនេះ ប្រហែលនៅក្នុងខែមិថុនា ក្នុងរឿងក្តី០០២ ដំណាក់កាលទីមួយ ។ ក្រោយប្រកាសសាលក្រមភាគីមួយចំនួននឹងដាក់ពាក្យបណ្តឹងសាទុក្ខ ហើយនឹងអាចមានភាគីមួយប្តឹងឧទ្ធរណ៍ ឬភាគីមួយមិនប្តឹងជាដើម ។ ដំណើរការដែលយើងត្រូវធ្វើការមានភាពសកម្មច្រើននៅក្នុងរឿងហ្នឹង ហើយការស៊ើបអង្កេតក៏ចេះតែនៅបន្តនៅក្នុងរឿងក្តី០០៣ និង០០៤ ។ ខ្ញុំមិនដឹងច្បាស់ទេថា យើងនឹងអាចមានលទ្ធភាព ហើយអាចនឹងបញ្ចប់នៅក្នុងឆ្នាំ២០១៤ ឬយ៉ាងណានោះ ។ ចំណុចមួយទៀតនៅក្នុងរឿងក្តី០០២ ដំណាក់កាលទីពី គឺកំពុងត្រៀមរៀបចំដំណើរទៅមុខ ។ បទចោទប្រកាន់ជាច្រើននៅក្នុងរឿង០០២ដំណាក់កាលទីពី មានដូចជា អំពើទារុណកម្ម មន្ទីរសន្តិសុខ អំពីបទរំលោភសេពសន្ថវៈ ដែលយើងត្រូវពិនិត្យមើល ។ យើងនឹងរង់ចាំឱកាសដើម្បីចាប់ផ្តើមសវនាការឲ្យបានឆាប់ ។ យើងរង់ចាំការសម្រេចរបស់តុលាការដើម្បីកំណត់កាលបរិច្ឆេទសវនាការនេះដែរ ។ យើងនឹងមានការរីកចម្រើនច្រើននៅក្នុងឆ្នាំ២០១៤ ខាងមុខនេះ ។

***សំណួរ*** ៖ លោក នីកូឡាស យើងសូមបញ្ចប់កិច្ចសម្ភាសនៅត្រឹមប៉ុណ្ណេះ ។ សូមថ្លែងអំណរគុណដល់លោកដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយសូមជូនពរលោកឲ្យមានសុខភាពល្អ ហើយរីករាយ នៅក្នុងឆ្នាំថ្មី ។

***ចម្លើយ*** ៖ បាទ! សូមអរគុណ និងសូមជូនពរឆ្នាំថ្មី ។ ខ្ញុំរីករាយណាស់ដែលបានផ្តល់បទសម្ភាស ហើយប្រសិនបើមានឱកាសយើងនឹងជម្រាបជូនពីអ្វីដែលយើងបានធ្វើនៅ អ.វ.ត.ក នេះបន្តទៅទៀត ។




(តបប់)

**៤៦) បន្សុទ្ធកម្មបដិវត្តន៍ បឹងកន្ទួត**

ទីនេះមានឈ្មោះថា បឹងកងមាស ។ អង្គការបានដឹកយើងឆ្លងបឹងដ៏ធំនេះទៅដាក់ត្រើយម្ខាង ហើយបានឆ្លងបឹងតូចមួយទៀតដែលមានឈ្មោះថា បឹងកន្ទួត ហើយបានដាក់យើងឲ្យនៅលើកោះតូចមួយដែលមានសុទ្ធតែទឹកព័ទ្ធជុំវិញ ។

នារដូវទឹកឡើង ទីនោះនៅសល់តែទួលតូចមួយប៉ុណ្ណោះ ក៏ប៉ុន្តែមិនជាអ្វីទេ ព្រោះយើងមានគ្នាតែជាងដប់នាក់ ។ ក្នុងចំណោមយើងក៏មានអ្នកមូលដ្ឋានចាស់ជាច្រើននាក់ទៀតដូចជា ខន ដែលជាអតីតនីរសាររបស់ តាស៊ី លេខាបក្សភូមិភាគបស្ចិម ទែល ជាអតីតជំនួយការរបស់ តាវេង បញ្ជាការដ្ឋានតំបន់ពាមល្វា ។ ពេលនេះអង្គការដាក់យើងឲ្យរស់នៅជាមួយគ្នា គឺអ្នកមូលដ្ឋាននឹងអ្នក១៧មេសា ។ ទោះយ៉ាងណាក្តី យើងសុទ្ធតែជាក្បាលយួនខ្លួនខ្មែរ ឬអាយ៉ងយួនដូចគ្នា ។

ពេលព្រឹកម៉ោងបួន សាន ផ្ទុកញែងដាស់ ប៉ុន្តែគ្មានរណាក្រោកទេ គឺដេកគ្រលុំភួយ សាន ប្រឹងផ្លុំកញ្ចែផងដេរផង យកជើង

ទាត់ធាក់ផង ក៏នៅតែពុំក្រោកទើប សាន និង គាន់ ចាប់ទាញជើងទម្លាក់ដីយកដែកកេះដុតជើង ទើបមានអ្នកខ្លះក្រោកទាំងបិទភ្នែកដើរសំដៅការដ្ឋានទោះជាត្រូវដេរប្រទេចទាត់ធាក់ ឬត្រូវភ្លើងដុតជើងយ៉ាងណា ក៏មានអ្នកខ្លះទ្រាំដេកតទៅទៀត ។ សាន ទាល់តម្រិះឈប់ទាញជើងឈប់ដេរ ។ តើពួកឯងមិនខ្លាចងាប់ទេឬ? គ្មាននរណាឆ្លើយទេ អ្នកខ្លះចេញទៅរកទឹក លុបមុខដើរសំដៅទៅរកកាំបិត ឬចបដើរទ្រេតទ្រោត ដូចមនុស្សជរាឬកោងៗដូចស្វាឈើមភេនស៊ី ជើងរបស់យើងធ្ងន់ដូចដែក ភ្នែកបើកពុំរួច ។ ខ្ញុំចាំថា កាលណោះខ្ញុំចង់ស្លាប់ខ្លាំងណាស់ ព្រោះស្រួលជាងរស់នៅដូចនរកបែបនេះ ។

នៅទីនេះសូម្បីតែ សាន និង គាន់ ក៏គ្មានអ្វីបរិភោគដែរ ព្រោះជាជំរំលត់ដំយ៉ាងខ្លាំងបំផុត ។ ខ្ញុំសង្កេតឃើញថា មិត្តសាន និង មិត្ត គាន់ មិនបានដឹកនាំការងារអ្វីទេ ក្រោយពីយើងបានចេញទៅធ្វើការហើយ គាត់ទៅដេកបាត់ដែរ ។ ចំណែកយើងម្នាក់ៗគិតតែដើររកវាយកណ្ដូប ថ្លែន ខ្យង និងឃ្មុំដើម្បីយកមកដុតស៊ី ឬពេលខ្លះស៊ីឆៅតែម្ដង ។

ទោះបីនៅទីនេះសម្បូរត្រីក៏ពិតមែន តែយើងគ្មានឧបករណ៍សម្រាប់ចាប់ត្រីនោះទេ ហើយអង្គការមិនអនុញ្ញាតឲ្យយើងរកត្រីដែរ ម៉្លោះហើយយើងជួបប្រទះអ្វីក៏ស៊ីហ្នឹងទៅ ។

ចំពោះខ្ញុំ របស់ដែលងាយរកជាងគេគឺ ខ្ទង និងគីង្គក់ ខ្ញុំវាយបំបែកខ្ទងធំៗរួចដោតជាត្រណោតអាំង ហើយដកដើមកំប្លោកធំៗយកមកចិតសំបកហើយដុត វាមានរសជាតិឆ្ងាញ់ម្យ៉ាងដែរ តែត្រូវធ្វើយ៉ាងណាកុំឲ្យមិត្ត សាន និង មិត្តគាន់ ឃើញព្រោះខ្លាចគាត់ដេរខំហូបឲ្យតែពេញពោះគ្មានអង្ករ សម្រាប់ដាំបបរនោះទេ ។

ដោយ នៅក្នុងក្រុមយើងមានអតីតកម្មាភិបាល និងអ្នកមូលដ្ឋានចាស់ជាច្រើននាក់នោះពុំមែនជាការងាយស្រួលនិងបង្ខំឲ្យអ្នកទាំងនោះធ្វើការនោះឡើយ ។ ក្នុងអំឡុងសង្គ្រាម អ្នកទាំងអស់សុទ្ធតែមានប្រវត្តិតស៊ូធ្វើពលិកម្មដើម្បីសម្ដេច សីហនុ ដើម្បីបដិវត្តន៍ ពេលនេះអ្នកទាំងអស់ត្រូវបដិវត្តន៍ចោទថា ជាខ្មាំង និងត្រូវបានបន្ទាបបន្ថោក ត្រូវបានទម្លាក់បុណ្យសក្តិ ហើយត្រូវបង្ខំឲ្យធ្វើការ ត្រូវបង្អត់អាហារ ។ អតីតកម្មាភិបាលទាំងនោះ ចចេសពុំព្រមធ្វើការ ហើយរអ៊ូរទាំ ។ ចំពោះខ្ញុំដែលមិនមែនជាបក្សជន មិនមែនជាកម្មាភិបាល ខ្ញុំគ្មានអ្វីត្រូវចចេសរឹងរូសនោះទេ ។

ក្នុងចំណោមអតីតកម្មាភិបាលទាំងនោះ ខ្ញុំចំណាំបានជាងគេគឺមិត្ត ទែល ព្រោះគាត់ជាជំនួយការរបស់ តាវេង ។ គាត់មិនព្រមធ្វើការឬដើររកចាប់កណ្ដូប បង្គួយ ថ្លែន អ្វីទេ គាត់តែងតែឈរ ឬអង្គុយសញ្ជឹងសម្លឹងមើលជើងមេឃ មើលទៅគាត់ហាក់ដូចជាបាត់បង់ភាពថ្លៃថ្នូរក្នុងនាមជាជនបដិវត្តន៍ ។

ដោយមានការហត់នឿយ និងអស់កម្លាំងព្រោះមិនមានអ្វីស៊ី ដូច្នោះ ពេលថ្ងៃត្រង់ ទែល អង្គុយក្រោមដើមរាំងនិយាយរឿងប្រវត្តិនៅសមរភូមិនៅខាងជើងក្រុងភ្នំពេញ ។ ទែល បានចូលរួមចលនាតស៊ូប្រយុទ្ធដើម្បីដណ្ដើមអំណាចថ្វាយសម្ដេចឪ ។ គាត់សង្ឃឹមថា ពេលចប់សង្គ្រាមគាត់អាចរស់ជាមួយគ្រួសារយ៉ាងសុខដុមរមនា ពេលនេះគាត់បានក្លាយជាអនុប្រជាជនជាអាយ៉ងយួនក្បាលយួនខ្លួនខ្មែរ ហើយត្រូវបង្ខំឲ្យធ្វើការដូចសត្វ ។

ទែល ក៏បាននិយាយប្រាប់ខ្ញុំថា មុនពេលត្រូវចាប់ខ្លួនតា ស៊ី បានរៀបចំកម្លាំងសហការជាមួយគណៈភូមិភាគដទៃទៀតធ្វើរដ្ឋប្រហារទម្លាក់ ប៉ុល ពត ។ តាស៊ី បានឲ្យគាត់ដឹកអាវុធតាមរថយន្តដឹកត្រីយកមកលាក់ទុកនៅរូងភ្នំមួយក្បែរឃុំត្រពាំងដេវរ ដោយរង់ចាំពេលវេលា និងផ្ទុះអាវុធតែប៉ុណ្ណោះ ក៏ប៉ុន្តែសំណាងអាក្រក់ ប៉ុល ពត បានដឹងខ្លួនមុន ហើយក៏ចាត់ការ តាស៊ី ព្រមទាំងបក្សពួកបានមុន ។ ទែល បានបន្ថែមថា បើសិនជាចលនានោះទទួលបានជោគជ័យនោះ យើងនឹងប្រកាសរបបថ្មីមួយដែលធូរស្រាល និងមានសេរីភាពជាពុំខាន ។

ខ្ញុំដឹងច្បាស់អំពីជោគជ័យវាសនារបស់ខ្ញុំព្រោះថា ខ្ញុំធ្វើបដិវត្តន៍យូរហើយ នេះហើយជាលទ្ធផលនៃបដិវត្តន៍ដែលបញ្ជាក់អំពីវាសនាអនាគតរបស់គាត់ ។ គាត់ពន្យល់ថា ជីវិតរបស់ជនបដិវត្តន៍ ឬបក្ខជនប្រៀបដូចជាសំណល់នៃរបស់អ្វីមួយ ។ គាត់ប្រៀបប្រដូចខ្លួនគាត់ទៅនឹងស្លឹកចេកដែលគេយកទៅខ្ចប់នំចេក លុះពេលដែលស៊ីនំរួចហើយ នឹងត្រូវក្រវាត់ស្លឹកចេកចោលនៅតាមផ្លូវដូច្នោះដែរ ។ ខ្ញុំស្ដាប់ ទែល និយាយដល់នេះ គឺមានចិត្តសង្វេគចំពោះរូបគាត់ ។ ទែល ប្រហែលជាពុំដឹងទេថា នៅពេលដែលគាត់នៅជាកម្មាភិបាល តើខ្ញុំទាំងអស់គ្នាវេទនាក់យ៉ាងណា... 

បដិវត្តន៍ច្បាស់លាស់ បដិវត្តន៍ប្រែថា ផ្លាស់ប្តូរនិងផ្លាស់ប្តូរមិនចេះចប់ ។ ទែល និយាយលាខ្ញុំដោយទឹកមុខស្លូតថា លាហើយបដិវត្តន៍! លាហើយបក្សកុម្មុយនីស្តកម្ពុជា! ។

រសៀលម៉ោងបី ខ្ញុំឃើញទូកម៉ាស៊ីនមួយដែលមានយុទ្ធជនស្លៀកពាក់ពណ៌គ្រែអ៊ី បានមកចតនៅមាត់ច្រាំង ក្រោយមក ក៏ឃើញ ទែល, ខន និងអតីតកម្មាភិបាលបីបួននាក់ទៀតត្រូវចងមុខនិងចងស្លាបសេកបណ្តើរចុះទូកចេញពីកោះទៅបាត់ស្រមោល អតីតកម្មាភិបាលទាំងនោះត្រូវបានបញ្ជូនទៅជំរំដុសខាត់ខួរក្បាលនៅឯបន្ទាយអំពិល ដែលមិនឆ្ងាយពីទីនោះប៉ុន្មានទេ គឺជាគុកធំនៃតំបន់៣១ ស្ថិតនៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ទែល និងអតីតកម្មាភិបាលបានចាកចេញពីយើងទៅហើយ អ្នកទាំងនោះជាអ្នកបដិវត្តន៍ដែលត្រូវវែងអំចេញពីជួរបដិវត្តន៍ពីបក្ស ដូចជា សំរាម ឬចុងអង្ករដើម្បីឲ្យអង្ករបានសុទ្ធល្អនោះហើយ ជាសំណល់បដិវត្តន៍នៃបក្សកុម្មុយនីស្តកម្ពុជា ។

## ជំពូក៧ ករម្ទេច

### ៤៧) កោះអវីចី

នៅទីនោះយើងអាចរកអ្វីស៊ីបាន ទោះបីជាវាមិនឆ្ងាញ់ក៏ប៉ុន្តែអាចឆ្អែតដែរ ។ ក្រុមក្បាលយួនខ្លួនខ្មែរត្រូវចាប់ខ្លួនបញ្ជូនអស់មួយចំនួនហើយ ខ្ញុំក៏ចាប់ផ្តើមស្គាល់មិត្តភក្តិជាច្រើននាក់ក្នុងនោះជាមិត្តដ៏ល្អជាងគេរបស់ខ្ញុំ ។

នួន ជាអតីតកម្ម៉ង់ដូពិសេសរបស់អាមេរិកកាំង ក៏ប៉ុន្តែគាត់ប៉ិនធ្វើពុតណាស់ គ្មាននរណាដឹងពីអតីតភាពរបស់គាត់ទេ ។ នួនចេះចែវទូកយ៉ាងស្ទាត់ជំនាញហើយការងារអ្វីក៏ធ្វើបានដែរ ។ មិត្តដ៏ល្អរបស់ខ្ញុំម្នាក់ទៀតឈ្មោះ ចំរើន ដែលរៀននៅមហាវិទ្យាល័យជាមួយគ្នា ។ ឪពុកម្តាយរបស់ ចំរើន ជាអ្នកស្រែដូច្នេះទោះយ៉ាងណាក៏ ចំរើន នៅតែយល់កិច្ចការអ្នកស្រែគ្រាន់បើជាងខ្ញុំ គាត់ចេះរកត្រី អណ្តើក និងចាប់ពស់ព្រៃ ចំណែកម្នាក់ទៀតឈ្មោះ ភន ដែលមានមាឌធំកម្ពស់ប្រហែលមួយម៉ែត្រប៉ែតសិប ជាអ្នកនេសាទទោះគ្មានឧបករណ៍ក៏អាចចាប់ត្រីនឹងដៃបានហើយ បាញ់ត្រង់ គាត់រកបានកណ្តុរបួនប្រាំក្នុងមួយថ្ងៃ ទាស់ម្យ៉ាងគឺល្មោភស៊ីហើយស៊ីមិនចេះឆ្អែត ។ ដោយខ្ញុំមិនប្រសប់រកម្ហូបនឹងគេ ខ្ញុំរកបានតែខ្យងធំៗដែលរត់មិនលឿន និងគីង្គក់តែប៉ុណ្ណោះ ។ យើងទាំងអស់គ្នាហៅមិត្តទាំងពីរថា បង សាន និង បងតាន់ ។ អ្នកទាំងពីរនាក់ក៏គ្មានអ្វីនឹងស៊ីដែរ ។ គាត់ទាំងពីរសុទ្ធតែជាអតីតមេបញ្ជាការវរសេនាដែលអង្គការចាត់ទុកថា វង្វេងស្មារតីបដិវត្តន៍ឬក្បាលយួនខ្លួនខ្មែរ ដូចជា ទែល និង ខន ដែលបានចាប់ខ្លួននោះដែរ ។

ខ្ញុំហៅទីនោះថា កោះអវីចី ព្រោះថាការរស់នៅទីនោះមិនដូចឋានមនុស្សទេ យើងស៊ីអ្វីយ៉ាប់ជាងប្រេតដែលគេសែននាបុណ្យភ្ជុំបិណ្ឌទៅទៀត ។ ដោយកោះនេះនៅដាច់ឆ្ងាយពីមាត់បឹងកងមាស យើងត្រូវបានអង្គការនិរទេសចោល ។ ក្នុងខណៈដែលខ្ញុំរកខ្យង ២០-៣០ យកមកបំបែកសំបក ហើយដោតត្រណោតសម្រាប់ស៊ីជាមួយដើមកំភ្លោកអាំងនោះ នួន និង ភន ចាប់បានត្រីធំៗយកមកដុតដែរ ។ យើងបរិភោគទាំងអស់គ្នា គ្មានបាយ គ្មានអំបិល ចំណែកមុខរបស់យើងឡើងពណ៌ខ្មៅដូចពួកអាហ្វ្រិកដោយសារកម្តៅថ្ងៃ និងមុជទឹកពុំដែលមានសាប៊ូដុស ។ មានពេលខ្លះ ពេលដែលយើងកំពុងតែអាំង ឬដុតអណ្តើក ឬពស់នោះ បង សាន បានមកដល់គាត់បន្ទោសយើងថា រកស៊ីឯកជន ឬនិន្នាការសេរី ឬវាយប្រហារបក្សដោយមិនចេះអត់ធន់តស៊ូវណ្ណៈ ធ្វើដូច្នេះនាំឲ្យចលនាប្រវត្តិសាស្ត្រវិលថយក្រោយ ។ បងសាន បានដកហូតរបស់ឆ្ងាញ់របស់យើងយកទៅស៊ីខ្លួនឯង ។ រីបង តាន់ ក៏ដូចគ្នាដែរ យើងត្រូវប្រយ័ត្នប្រយែងពេលដុតត្រីឬអណ្តើកត្រូវរកកន្លែងពួន បើពុំនោះទេ យើងនឹងពុំបានស៊ី ។ ដោយសារកោះអវីចីនេះនៅឆ្ងាយពីមាត់ច្រាំងពេកបើសិនជាយើងចែវទូកកាត់បឹងដើម្បីដឹកអង្ករ ឬដំឡូងឈើគឺត្រូវប្រើពេលជាងមួយម៉ោងឯណោះ ព្រោះហេតុនោះហើយ បានជាយើងដាច់ស្បៀងខ្វាំងណាស់ ។ ថ្ងៃមួយយើងបានឮថា នៅចុងម្ខាងកោះ អង្គការបានកាប់គោដើម្បីជប់លៀងបុណ្យខួបកំណើតបក្សកុម្មុយនីស្តកម្ពុជា ។ យើងបានបោះបង់ចោល ចប កាំបិត រនាស់ ហើយរត់សំដៅទៅ ក៏ប៉ុន្តែយើងបានប្រទះឃើញតែស្បែកគោដែលជុំក្លិននិងរុយរោមដែលបានបោះចោលតែប៉ុណ្ណោះ ។ យើងមិនខ្វល់ពីអ្វីទាំងអស់នាំគ្នាអារត្រចៀកស្បែកគោដែលស្អុយរុយរោមនោះ ដុតហើយស៊ីរហូតដល់ឆ្អែតហាល់ ។ យប់នោះគ្រប់គ្នាចុកពោះរាកមួលដោយសារស្បែកគោនោះវារឹងពេក ព្រមទាំងពងរុយបណ្តាលឲ្យយើងឈឺគ្រប់គ្នា ។ ស្អែកឡើងគ្មាននរណាម្នាក់ចេញទៅធ្វើការទេ ។ ក្រោយពីបានដឹងថា យើងបានស៊ីស្បែកគោ បងសាន និង បងតាន

ខឹងហើយដេរយើងទាំងអស់គ្នាយ៉ាងខ្លាំងថា ពួកអាភ្លីភ្លើ ហេតុអ្វីក៏ពួកឯងវាយប្រហារបក្ស និងបដិវត្តន៍យ៉ាងនេះ កាលធ្វើសង្គ្រាមជាមួយពួកចក្រពត្តិ ពួកអញអត់បាយបីបួនថ្ងៃ ក៏មិនបន្ទោកបន្ទាបបក្សយើងនេះដែរ ។

បងសាន បានពន្យល់យើងថា ការអត់ឃ្លានជារឿងបណ្តោះអាសន្នព្រោះថាបក្សចង់សាកល្បងគោលជំហររបស់យើង បន្តិចទៀតយើងនឹងបានសម្បូរសប្បាយមិនខាន ។ ខ្ញុំដឹងថានេះគ្រាន់តែជាការលួងលោមពួកយើងតែប៉ុណ្ណោះ ។

ពេលនេះរបបអាហារដែលអង្គការឲ្យលែងសំខាន់ទៀតហើយ ព្រោះថានៅផ្ទះបាយមានតែខ្ទះធំមួយ ដែលដាក់លើភ្លើងចោលអ្នកណាចង់ស៊ីក៏ស៊ីទៅ មានតែព្រលិតស្ងោរបង់អំបិល និងអង្ករប៉ុន្មានគ្រាប់តែប៉ុណ្ណោះ ។ របបព្រលិតមួយខ្ទះនេះវាច្រើនពេកណាស់សម្រាប់យើងដប់នាក់ តែបបរនោះយ៉ាប់ជាងបបរជ្រូកទៅទៀត ។

គួរឲ្យសង្វេគពេកណាស់ ដៃទន្លេសាបដែលសម្បូរទៅដោយត្រី ប៉ុន្តែយើងស៊ីចំណីអន់ជាងសត្វ ជាងពួកនរកទៅទៀត

ចំពោះ នួន ដែលជាមិត្តល្អរបស់ខ្ញុំតែងតែលួចផ្តល់នូវត្រីឬកង្កែបដល់ខ្ញុំជានិច្ច ប៉ុន្តែខ្ញុំក៏មានផលវិបាកផ្ទាល់ខ្លួនផងដែរ គឺចោរលួច ។ អ្នកដែលល្មោភស៊ី និងជំនាញខាងលួចបំផុតគឺ ភន់ ដែលស៊ីមិនចេះឆ្អែត ។ បើខ្ញុំយកត្រីអាំងឬអណ្តើកទៅដំរំគឺច្បាស់ជាត្រូវ បងសាន ឬបងតាន់គាត់រឹបអូសឬក៏ត្រូវ ភន់ លួចដែរ ដូច្នេះខ្ញុំត្រូវលាក់ចំណីទាំងនោះក្នុងរន្ធឈើ ប៉ុន្តែមានពេលខ្លះក៏ត្រូវស្រមោចស៊ីអស់ដែរ ។

ក្នុងចំណោមយើងទាំងអស់ដប់មួយនាក់នោះខ្ញុំសម្គាល់ថា នួន ជាមនុស្សសុចរិតរឹងមាំជាងគេ ចំណែក ភន ថ្វីត្បិតតែមាឌធំតែជាមនុស្សខ្ជិល និងរបិលរប៉ូច ម៉ាត់ និងសុស សុទ្ធតែជនជាតិចាមដែលស្ងប់ស្ងៀមពិបាកយល់ចិត្ត ឡាយ, ហុង និង មាន សុទ្ធតែជាអ្នក១៧មេសា ដូចខ្ញុំដែរជាកូនពាណិជ្ជករ ឬកូនមន្ត្រី ពុំពូកែរកម្ហូបស៊ីទេ រីឯ ផាន, សៀង និង ចំរើន សុទ្ធតែជាមនុស្សរឹងមាំ និងអង់អាចក្លាហាន ។ ជីវិតនៅកោះអរីចីគឺជាជីវិតដ៏ផុយស្រួយ ដូចទឹកដក់លើស្លឹកឈូក ហើយអានាធិបតេយ្យបំផុត ។ យើងប្រៀបដូចជាឆ្កែទាល់ច្រក សូម្បីតែ បងសាន និងបងតាន់ ក៏ប្រហែលជាញញើតយើងដែរ ។

ថ្ងៃមួយ នួន ដែលពូកែហែលទឹក និងចែវទូក បានចែវទៅដល់ព្រែកសាលា និងបឹងរណបសែន រើសបានផ្លែត្នោតទុំជាច្រើន ។ នួន បានលាក់ត្នោតទុំនៅលើកំពោកហើយយកពីរបីមកដុតនៅភ្លើងក្របី ធម្មតាផ្លែត្នោតទុំគឺជាចំណីអាហារក្របីតែប៉ុណ្ណោះ ប៉ុន្តែពេលនេះវាមានតម្លៃលើសមាសប្រាក់ទៅទៀត សម្រាប់យើង នួន បានរកកន្លែងសមរម្យក្នុងព្រៃដើម្បីចែករំលែកចំណីដ៏ឆ្ងាញ់នេះដល់ខ្ញុំ ហើយយើងកកេរត្នោតទុំទល់មុខគ្នា វាមានរសជាតិផ្អែមនិងសម្បូរទៅដោយ វីតាមីន ស្រាប់តែ ពេលនោះ បង សាន បានមកដល់ ។ គាត់សួររកមុខអ្នកដែលបានត្នោតទុំ ។ នួន បានឆ្លើយសារភាពថា ខ្លួនបានចែវទូកទៅរើសនៅព្រែកសាលា ពេលនោះបង សាន ខឹងខ្លាំងណាស់ ។ បង សាន ពន្យល់ថា ផ្លែត្នោតទុំវាគ្មានអនាម័យ ពេលដែលហូបទៅអាចឈឺពោះ និងរាករូសនាំឲ្យស្ទះការងាររបស់បក្ស ។ បង សាន ក៏បញ្ជាក់ថា អ្នកណាដែលធ្វើឲ្យស្ទះដល់ការងាររបស់បក្ស អ្នកនោះត្រូវចាត់ទុកថា ជាខ្មាំងឬក្បាលយួនខ្លួនខ្មែរ និងជាពួកប្រតិកិរិយាប្រឆាំងបដិវត្តន៍ ។ បង សាន បានចង នួនភ្ជាប់នឹងដើមរាំង ហើយឲ្យហៅអ្នកដទៃទៀតមកមើល ។

បងសាន បញ្ជាឲ្យខ្ញុំដែលជាអ្នកទទួលផលប្រយោជន៍ពីខ្មាំងនោមដាក់ នួន ដែលអ្នកប្រព្រឹត្តបទល្មើស ។ នួន ត្រូវចងធូរៗហាក់ដូចជាការកំប្លែងលេងតែប៉ុណ្ណោះ ។ អ្នកទាំងអស់គ្នាសើចរហូតដល់ហៀរទឹកភ្នែក ។ ទោះបីជាត្រូវដេរឬវាយក៏ដោយនៅលើកោះអរីចីនេះវាជារឿងធម្មតាទៅហើយ ។ គ្មាននរណាឈឺចាប់នឹងសម្តីរបស់បង សាន និងបង តាន់ទេ យូរៗទៅយើងចាត់ទុកថា គាត់ទាំងពីរហាក់ដូចជាបងប្រុសដែលមកទទួលរងទុក្ខវេទនាជាមួយយើងដែរ ។

ពេលយប់ឡើង បង សាន និង បងតាន់ តែងតែដើរចេញពីជំរំប្រហែលជាគាត់ខ្លាច យើងលបសម្លាប់គាត់ក៏មិនដឹង ។ រឿងនេះគ្រាន់តែជាការស្មានតែប៉ុណ្ណោះ ព្រោះថាបក្សកុម្មុយនីស្តកម្ពុជានិងបដិវត្តន៍នៅតែស្ថិតជាអាថ៌កំបាំងចំពោះរូបខ្ញុំជានិច្ច សូម្បីតែមកដល់បច្ចុប្បន្ននេះក្តី ។

រសៀលថ្ងៃមួយ បងតាន់ កំពុងឈរមើល សៀង ភ្ជួរដីដាំឪឡឹក រីឯ ភន ដែលកាន់ចបកាប់ក្លីស្រែប្រាំងបានឈរមើល សៀងរហូតដល់របូតចបពីដៃ ។ បងតាន់ក៏សួរទៅ ភន ថា អា ភន តើកំពុង

តែមើលស្អីហ្នឹង? ខ្ញុំកំពុងមើល អាសៀង តើវាបានអីស៊ីបានទំពារញាប់មាត់ដូច្នោះ ។ បងតាន់ ក៏ស្រែកហៅ សៀង ឲ្យបញ្ឈរក្របី ហើយ សួរថា អាសៀង តើឯងបានស្អីស៊ីហ្នឹង? នៅទីនោះ គឺកោះអរីចី គឺមិនប្រើពាក្យមិត្តឬហូបទេ? សៀង ឆ្លើយវិញ ខ្ញុំកំពុងស៊ីក្តាមសក ។ បងតាន់ ហៅ សៀង ឲ្យមកជិតហើយបន្តាប់ថា ខ្ទាក់ក្តាមសកពាក់កណ្តាលឲ្យ អាភន វាស៊ីផង? បដិវត្តន៍មានស្អីត្រូវចែកគ្នាណា! តើពួកឯងភ្លេចហើយឬ?

ពេលនោះ សៀង ក៏ខ្ទាក់ក្តាមសកដែលទំពារហើយដាក់ក្នុងដៃហុចទៅឲ្យ ភន ។ ភន នៅទីទើរ បងតាន់យករំពាត់ជន្លួរកវាយក្បាលទើបទទួលរួចដាក់ក្នុងមាត់ទំពារ ហើយទាំងពីរនាក់ក៏ដើរចេញទៅរកកន្លែងធ្វើការរៀងៗខ្លួន ។ បងតាន់ក៏អស់សំណើចរួចដើរចេញបាត់ទៅ ។

## ៤៨) ភៀសខ្លួន

វាសនារបស់ខ្ញុំបានឈានដល់ការផ្លាស់ប្តូរចាប់ពីពេលដែលបង សាន ត្រូវបាត់ខ្លួនចុងឆ្នាំ១៩៧៦ ។ ថ្ងៃមួយបង សាន ត្រូវបក្សបង្គាប់ឲ្យទៅប្រជុំនៅឯត្រើយម្ខាង ។ នួន បានចែវទូកចម្លងបង សាន ទៅហើយត្រឡប់មកវិញតែម្នាក់ឯង ។ ថ្វីត្បិតតែគាត់បានជេរ ទាត់ធាក់ និងបង្ខំយើងឲ្យធ្វើ តែចិត្តរបស់គាត់ពុំអាក្រក់ទេ តាមពិតគាត់ធ្វើតាមតែបញ្ជាតែប៉ុណ្ណោះ ។ ចំពោះរូបគាត់ ក៏ពុំច្បាស់អំពីវាសនារបស់គាត់ផង ប្រហែលជាគាត់ស្មានត្រូវថាអ៊ីនឹងទៅជាអ្វី ព្រោះថាគាត់ជាអតីតកម្មាភិបាលម្នាក់ដែរ ។ បងសាន បានចាកចេញពីយើងហើយ គាត់មិនត្រឡប់មកវិញទេ ពេលនេះនៅសល់តែបង តាន់ ម្នាក់ឯងគត់ដែលនៅជាមួយយើង ។

បន្ទាប់ពីការចាកចេញរបស់បង សាន បងតាន់ ក៏ប្រែប្រួលដែរ គាត់ស្រពាប់ស្រពោនមែនទែន គាត់លែងច្រៀងហើយមិននិយាយស្តីទាល់តែសោះ ។ បងតាន់ សម្លឹងតែទៅត្រើយខាងលិច ប្រហែលជាគាត់ដឹងថាបង សាន ទៅកាន់ទីណា? នេះជាគុកបន្ទាយអំពិលដ៏ធំមួយដែលមានអតីតបញ្ញវន្ត និងអតីតកម្មាភិបាលរាប់ម៉ឺននាក់បានជាប់នៅទីនោះ ។

ខែធ្នូ១៩៧៦ ទឹកជំនន់ទន្លេមេគង្គក៏ចាប់ស្រកមែនទែន ផ្ទៃបឹងកងមាស ក៏រួមតូចជាងមុនច្រើន ។ ល្ងាចនេះបង តាន់ បានហៅយើងមកប្រជុំនៅជុំវិញភ្នក់ភ្លើងក្របី ។ បងតាន់ និយាយមួយៗ ដោយស្រងូតស្រងាត់អំពីការប្រយុទ្ធតស៊ូដើម្បីបក្ស និងបដិវត្តន៍ ។

ពេលនេះសម្រាប់អញគឺចប់ហើយ ពួកឯងដឹងទេ កាលពីឆ្នាំ ១៩៧០ នយោបាយរបស់បក្ស គឺការតស៊ូប្រជាជាតិប្រមូលផ្តុំដើម្បីយកកម្លាំង តែក្រោយជ័យជម្នះ ១៧ មេសា ១៩៧៥ បក្សបានធ្វើការបោសសម្អាតផ្ទៃក្នុង ហើយឥឡូវនេះគឺជាការចម្រាញ់យកតែបក្ខជនបរិសុទ្ធប៉ុណ្ណោះ ចំពោះរូបអញគឺជាសំរាម ឬជាកាកសំណល់របស់បដិវត្តន៍តែប៉ុណ្ណោះ ។

មកដល់ត្រឹមនេះ យើងហាក់ដូចជាធ្លាក់ក្នុងអន្លង់យ៉ាងជ្រៅនៃភាពស្រយុតស្រយង់ ។ ខ្ញុំចាប់អារម្មណ៍ថា បងតាន់ មិនមែនជាមនុស្សដែលគួរឲ្យស្អប់ខ្ពើមនោះឡើយ ។ ទោះបីជាគាត់ធ្លាប់ជេរធ្លាប់វាយយើងក៏ដោយ ។ «ឯងទាំងអស់គ្នាមិនត្រូវនៅទីនេះទៀតទេ ត្រូវប្រញាប់គេចខ្លួនឲ្យបានរហ័សជាទីបំផុត ត្រូវចាកចេញ រត់ឥឡូវនេះ បើនៅត្រូវតែស្លាប់ បើចេញអាចមានផ្លូវរស់ អញរត់ចេញឥឡូវនេះហើយ សូមជូនពរឯងទាំងអស់គ្នាឲ្យមានសំណាងល្អ» ។

និយាយចប់ បងតាន់ ក៏ដើរសំដៅមាត់កំពង់ ។ យប់ក៏ចាប់ផ្តើមងងឹត បងតាន់ចុះទៅកាន់ទូកតូច ហើយចែវចេញទៅស្រមោលគាត់ក៏លិចបាត់ក្នុងភាពអន្ធការនៃបឹងកងមាស ។

បងតាន់ បានបន្សល់ទុកនូវអនុស្សាវរីយ៍យ៉ាងច្រើន ដូចជាការជះទឹក ការដុតភ្លើង ស្នាមរំពាត់ និងពាក្យប្រទេចផ្តាសា ប៉ុន្តែក្នុងនេះក៏មាននូវសេចក្តីស្រលាញ់ និងការយល់ចិត្តដែរ ។

ឥឡូវគឺដល់វេនយើងទាំងអស់គ្នាម្តងហើយ ។ យើងក៏ត្រូវភៀសខ្លួនផងដែរ ។ យើងនៅសល់ទូកមួយទៀតតែវាហាក់បីដូចជាតូចបន្តិចសម្រាប់យុវជនស្គមៗចំនួនដប់មួយនាក់ យើងមិនចាំបាច់រៀបចំអ្វីទេ ។ ខ្ញុំរើសបានកូនកាំបិតមួយក្រវាត់ក្រមាហើយសៀតកាំបិតនឹងចង្កេះ ។

ក្នុងចំណោមយើងទាំងអស់គ្នាមានតែ នួន និង ភន ទេ ដែលចេះចែវទូក និងរឹងមាំជាងគេ យើងធ្វើដំណើរក្រោមពន្លឺដួងខែដែលចាំងឆ្លុះលើផ្ទៃបឹង ។

ភន ចែវខាងក្បាល រីឯ នួន ចែវខាងកន្សៃ ពេលនោះប្រហែលជាម៉ោង៨យប់ ។ ឯគ្នាយើងប្រាំបួននាក់ទៀត អង្គុយស្ងៀម ព្រោះខ្លាចទូកលិច ។ ធម្មតាបើយើងចែវនៅពេលថ្ងៃ ដើម្បីឆ្លងកាត់បឹងដ៏ធំនេះយ៉ាងតិចក៏ប្រើពេលមួយម៉ោងដែរ ប៉ុន្តែនៅពេលយប់ហើយដើម្បីកុំឲ្យផ្អើលដល់កងសន្តិសុខនៅត្រើយខាងលិចនោះ ប្រាកដជា

ត្រូវប្រើពេលយូរ ។

អ្នកបើកទូកទាំងពីរនាក់ស្គាល់កន្លែងនៅទីនេះច្បាស់លាស់ ព្រោះហេតុនេះហើយបានជាយើងអាចបើកទូកវាងជៀសវាងកងសន្តិសុខ ។ យើងធ្វើដំណើរបានប្រហែលកន្លះម៉ោងក៏ឮសំឡេងកាណូតរបស់សន្តិសុខដែលបានបើកសំដៅទៅកោះអរិជិដើម្បីចាប់យើង ។ ពេលនេះ នួន និង ភន ដែលសុទ្ធតែអតីតកម្មាភិបាលហើយមានពិសោធក្នុងសង្គ្រាមបានប្រាប់យើងឲ្យចុះ និងពន្លិចទូក ។ យើងហែលទឹកសំដៅទៅគុម្ពកំភ្លោកហើយលាក់ខ្លួននៅទីនោះ ។ ឱព្រះអើយ! គ្រាន់តែចុះពីទូកហើយ រកកន្លែងពួនបានភ្លាម កាណូតកងសន្តិសុខបានមកដល់ក្បែរយើងល្មម ។ ភ្លើងពិលបាញ់ឆ្វេចឆ្វាចតែពុំឃើញយើងទេ ។ សំឡេងរបស់មេកងសន្តិសុខឮយ៉ាងច្បាស់ថារកមើលសព្វ ពួកវាមិនទៅឆ្ងាយប៉ុន្មានទេ ។ កងសន្តិសុខប្រចាំប៉ុស្តិ៍បាញ់ពិលមើលមួយសន្ទុះក៏បើកកាណូតចេញពីទីនេះ ។ យើងសម្ងំនៅទីនេះប្រហែលមួយម៉ោងទើបសម្រេចហែលទឹកសំដៅទៅដើមរាំងធំៗដើម្បីរកកន្លែងដេក ។ ដោយត្រាំទឹកម្នាក់ៗត្រូវឈ្លើងប៉ុនៗមេដើងទាមពេញខ្លួន ។

យប់នោះយើងគ្មានអ្វីហូបទេ បើរាវបះខ្យងក៏រើសយកមកដំបំបែកនឹងមែករាំងហូបទាំងឆៅ ខ្លះបានព្រលិតពីរបីទងព្រមទាំងដើមកំភ្លោក បះអ្វីដែលស៊ីកើតគឺស៊ីទាំងអស់ ហើយដឹកទឹកបឹងឡើងប៉ោងពោះម្នាក់ៗ ។

យើងដេកលើមែកឈើដូចស្វា មូសខាំ និងក្រពះទទេពេញមួយយប់ ។ យើងសម្រេចចិត្ត ថាដេកលើមែកឈើនៅពេលថ្ងៃហើយហែលទឹកនៅពេលយប់ ។ ពេលថ្ងៃយើងរកខ្យង និងចាប់កូនត្រីក្នុងឫសកំភ្លោកស៊ីជាមួយព្រលិតឆៅ ពេលយប់ហែលទឹកឆ្លងបឹងកងមាស ។ សំណាងល្អខែប្រាំងទឹកមិនសូវជ្រៅពេលខ្លះដើរបានពេលខ្លះត្រូវហែល ។ នួន និង ភន ចេះមើលផ្កាយនាំផ្លូវយើងហែលឆ្លងឆ្ពោះទៅទិសខាងលិច ។

យើងបានមកដល់ព្រៃរនាមដ៏ក្រាស់មួយឆ្ងាយពីគុកបន្ទាយអំពិល ។ នៅទីនេះមានសុទ្ធតែបន្លាអញ្ចាញ និងដើមរាំងធំៗដែលអាចឲ្យយើងគេចផុតពីការឃ្លាំមើលល្បាតនៃក្រុមឈ្លបស្រុក១៨ (សព្វថ្ងៃគឺស្រុកកំពង់ត្រឡាច) ។ ក្នុងចំណោមគ្នាយើងទាំងដប់មួយនាក់ រូបខ្ញុំផ្ទាល់មានកម្លាំងខ្សោយជាងគេ ចំណែក នួន, ភន, សៀង និង ផាន សុទ្ធតែរឹងមាំព្រោះជាអ្នកស្រែដែលធ្លាប់ធ្វើការងារធ្ងន់ៗ ចំណែក ម៉ាត់ និង សុះ ដែលជាជនជាតិចាមក៏រឹងមាំណាស់ដែរ ។ តាមទំនៀមទម្លាប់សាសនាឥស្លាមមិនឲ្យហូបសាច់សត្វណាដែលមិនស្អាតនោះទេ ដូចជា សាច់ជ្រូក កង្កែប និងត្រីរំអិល ក៏ប៉ុន្តែពេលនោះអ្វីក៏ហូបដែរ ដើម្បីយកកម្លាំងដើរកាត់ព្រៃ និងហែលទឹកក្នុងកាលៈទេសៈដ៏គ្រោះថ្នាក់នេះ ។

យើងដេកក្នុងព្រៃក្រាស់ដែលមានសុទ្ធតែខ្លា និងចចក រីឯពស់វែករនាមក៏សម្បូរណាស់ដែរ រហូតដល់ម៉ោង៩ព្រឹកទើបយើងភ្ញាក់ ។ ព្រៃក្រាស់ណាស់មិនងាយនរណារកយើងឃើញទេ ចំណែកខ្ញុំ ត្រូវបន្លាមុតជើងដើរពុំរួចដេកនឹងកន្លែង ខ្ញុំចង់បង្កាត់ភ្លើង ក៏ប៉ុន្តែភន ប្រាប់ថា កុំបង្កាត់ភ្លើងឲ្យសោះ ព្រោះឈ្លបអាចឃើញផ្សែង ហើយរកកន្លែងលាក់ខ្លួនរបស់យើងឃើញ ។ ពេលនោះ នួន, ភន, សៀង, ផាន, និង ចំរើន បានប្រាប់ខ្ញុំឲ្យរង់ចាំអ្នកទាំងអស់គ្នាចេញទៅរកម្ហូប ចំណែក ម៉ាត់ និង សុស ក៏ចេញទៅជាមួយគ្នាដែរ ដោយទុកអ្នកដែលខ្សោយៗ និងឈឺជើងឲ្យនៅចាំកន្លែង ដូច្នេះអ្នកដែលត្រូវនៅ គឺកូនចៅចិន និងកូនមន្ត្រីចាស់ ដូចជា ម៉ាន់, ឡាយ, ហុង និងរូបខ្ញុំ ។

អ្នកទាំងអស់គ្នាទៅបាត់តាំងពីព្រឹកម៉ោងប្រាំបួន ដោយទុកយើងចោលឲ្យដេកអត់បាយ ចំណែក ម៉ាន់ និង ឡាយ បានដើររកវល្លិ៍ជុយ កាច់យកដើរមកព្យាបាលជើងខ្ញុំដែលឈឺយ៉ាងខ្លាំង អ្នកទាំងពីរយកបន្លាមកដោះជើងនឹងដាក់ថ្នាំឲ្យខ្ញុំរហូតដល់បាត់ឈឺហើយដេកលក់ទាំងអត់បាយក្នុងព្រៃដ៏ស្ងាត់កម្បាំងនេះ ។ រហូតដល់រសៀលម៉ោងបួន ទើបឃើញអ្នកទាំងអស់គ្នាត្រឡប់វិញ ។ ម៉ាត់ និង សុះបានកាំភ្លើងអាកា៤៧ ម្នាក់មួយដើមព្រមទាំងខោអាវ ក្រម៉ា និងកាំបិត រីឯ នួន, ភន, សៀង, ផាន និងចំរើន ម្នាក់ៗមានត្រី ដំឡូងចបជីក និង ខោអាវ មកជាមួយដែរ ។

អ្នករាល់គ្នាបានវាយឆ្មក់លើក្រុមសន្តិសុខនៅបន្ទាយអំពិលដែលដើរកាត់នៅជាយព្រៃ ដណ្តើមកាំភ្លើង ព្រមទាំងចូលទៅលួចខោអាវ ចប និងដកដំឡូងនៅសហករណ៍ ។ ដោយបានចប និងកាំបិត យើងអាចជីកដំឡូងព្រៃ និងចម្អិនបរិភោគយ៉ាងប្រយ័ត្នប្រយែង ។ មិត្តល្អរបស់ខ្ញុំបានជួយព្យាបាលជើង និងឲ្យម្ហូបខ្ញុំហូបហើយដេកនៅទីនោះពីរយប់ទៀត ។ ក្រោយមកទើបមិត្តទាំង

ប្រាំពីរនាក់សម្រេចចិត្តថា នឹងបន្តរស់នៅក្នុងព្រៃតទៅទៀត ព្រោះយល់ថា ខ្លួនពុំចូលទៅនៅតាមសហករណ៍បានទេ ។ ចំណែក ខ្ញុំទាំងបួននាក់ផ្សេងទៀត សម្រេចចិត្តត្រឡប់ទៅសហករណ៍វិញ ។ ក្នុងនោះមាន ម៉ាន់, ឡាយ, និង ហុង ជ្រើសរើសការវិលត្រឡប់ទៅសហករណ៍ឃុំចោងម៉ោង នៅស្រុក១២ ចំណែករូបខ្ញុំពុំដឹងទិសដៅពិតប្រាកដនៅឡើយ ។

មិត្តរបស់ខ្ញុំទាំងប្រាំពីរនាក់បានជូនពរយើង ។ ទីនោះហើយដែលយើងបែកគ្នា មិត្តទាំងប្រាំពីរនាក់បានឲ្យត្រី និងដំឡូងដល់យើង ហើយជូនដំណើរយើងរហូតដល់ជាយព្រៃ ។

## ៤៩) ជីវិតថ្មី

ពេលយប់យើងធ្វើដំណើរកាត់ព្រៃ កាត់វាល ពេលខ្លះកាត់ភូមិស្រុក សហករណ៍ ហើយយើងសម្រាកពេលថ្ងៃ ។ យើងចំណាំទិសខាងលិចដោយមើលព្រះអាទិត្យ ពេលយប់មើលផ្កាយក្រពើ ដោយមិនស្គាល់អ្វីទាំងអស់ ។ យប់ទីបួន យើងបានចូលក្នុងសហករណ៍លួចបាយដែលសេសសល់ហូបយ៉ាងឆ្អែត ហើយបានលួចដកដំឡូងសម្រាប់ហូបតាមផ្លូវរហូតដល់យប់ទីប្រាំមួយ ទើបយើងបានមកដល់ផ្លូវ រទេះភ្លើង ទើបយើងដឹងថា មកដល់ផ្សារស្តុកអាចម៍រមាសហើយ ។ទីនោះមានផ្លូវបែកជាបួនគឺភ្នំពេញ បាត់ដំបង និងកំពង់ឆ្នាំង ទៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

ពេលនោះហើយដែលមិត្តរួមដំណើរទាំងបីនាក់បានបែកពីខ្ញុំ ហើយធ្វើដំណើរតាមបណ្តោយផ្លូវរទេះភ្លើងឆ្លងស្ពានប៉ុមប៉ាទៅចោងម៉ោង ។ ខ្ញុំស្គាល់ទីនេះច្បាស់ណាស់ ព្រោះកាលនៅការដ្ឋានស្រែសម័យ ខ្ញុំតែងតែដើរមកដល់ទីនេះដើម្បីកាប់ឬស្សី និងបោចវល្លិយកមកធ្វើបង្គី និងវេញខ្សែគោ ពេលខ្លះខ្ញុំដកផ្សិតក្មោក ពពេល និងរកត្រីនៅគល់ស្ពានប៉ុមប៉ានេះ ។

ខ្ញុំចាំបានតែត្រឹមនេះ ហើយក៏លែងដឹងអ្វីទាំងអស់ ខ្ញុំពុំដឹងថាសន្លប់ប៉ុន្មានថ្ងៃ ឬប៉ុន្មានម៉ោងទេ ព្រោះថាពេលដឹងខ្លួនគឺសំឡេងដ៏ទន់ភ្លន់មួយ ។ ម៉េចអាចៅ តើឯងដឹងខ្លួនហើយឬ? គឺជាសំឡេងរបស់បុរសចំណាស់ម្នាក់ដែលមានវ័យជាងចិតសិបឆ្នាំ ។ ពេលនោះខ្ញុំកំពុងស្ថិតលើរទេះគោដែលបរដោយបុរសចំណាស់នោះ ។ រទេះគោបរកាត់ព្រៃតាមផ្លូវដ៏រដិបរដុប តាចាស់ បានប្រាប់ខ្ញុំថា គាត់បានប្រទះឃើញខ្ញុំដេកសន្លប់នៅក្នុងព្រៃ ។

គាត់ជាគ្រូពេទ្យបាលនៅសហករណ៍ស្រែរបង ។ គាត់តែងតែបររទេះគោមករកឬសឈើ និងសំបកឈើប្រទាលគ្រប់មុខដើម្បីផ្សំថ្នាំព្យាបាលជំងឺប្រជាជននៅសហករណ៍ ។ គាត់បានដឹកខ្ញុំរហូតដល់ផ្ទះរបស់គាត់ ។ គាត់ជាប្រជាជនមូលដ្ឋានចាស់ ហើយក៏ជាឪពុករបស់គណៈសហករណ៍ឈ្មោះ មិត្ត នឿន ដែលជាអតីតយុទ្ធនារីក្នុងសង្គ្រាមប្រាំឆ្នាំ ។ តាមគោលការណ៍របស់បក្ស មិត្ត នឿន គ្មានសិទ្ធិនឹងផ្តល់ការជ្រកកោនដល់ខ្ញុំដែលជាប្រជាជន១៧មេសានោះទេ ប៉ុន្តែដោយគោរពកោតខ្លាច តាយ៉ន ជាឪពុកក៏សុខចិត្តនៅស្ងៀម ។ តាយ៉ន មានប្រពន្ធដែលខ្ញុំហៅគាត់ថា ម៉ែសួន បានកុហកកូនស្រីគាត់ថាខ្ញុំជាអ្នកមូលដ្ឋានចាស់ដែលឪពុកម្តាយបានស្លាប់កាលពីរឆ្នាំមុន ។ ទោះបីជាមិនសូវជឿឪពុករបស់ខ្លួនក្តីក៏មិត្ត នឿន នៅស្ងៀមមិនសួរដេញដោលអ្វីដែរ ។

ខ្ញុំចាំថា ប្រហែលជាអំឡុងខែមេសា ឆ្នាំ១៩៧៨ ដែលខ្ញុំបានមកនៅផ្ទះតាយ៉ន នៅសហករណ៍ស្រែរបង ។ ឆ្នាំ១៩៧៧នេះ សង្គ្រាមនៅព្រំដែនកម្ពុជាវៀតណាមបានផ្ទុះយ៉ាងសន្ធោសន្ធៅ នៅតាមសហករណ៍ពុំមានការតឹងតែងពេកទេ រីឯពួកយុវជនមូលដ្ឋានក៏ត្រូវបញ្ជូនទៅសមរភូមិអស់ ហើយនៅតាមសហករណ៍កម្មាភិបាលសុទ្ធតែស្រីៗ និងមនុស្សចាស់អាស្រ័យហេតុនេះបានខ្ញុំរស់នៅបានយ៉ាងសុខសាន្តនៅសហករណ៍ស្រែរបង ។ ម្យ៉ាងទៀត តាយ៉ន មានកូនស្រីជាគណៈសហករណ៍ រីកូនប្រុសបីនាក់ទៀត សុទ្ធតែជាយោធាតំបន់ គ្រួសារនេះមិនមែនជាប់និន្នាការសង្គមចាស់ទេ ។

កាលពីមុនសង្គ្រាម តាយ៉ន ជាកសិករក្ររកស៊ីកាប់ខសដុតធ្យូង ក្រោយមកក៏ក្លាយជាអាចារ្យវត្ត ក៏ប៉ុន្តែក្នុងពេលសង្គ្រាម កូនទាំងបួននាក់របស់គាត់ត្រូវអង្គការបដិវត្តន៍កេណ្ឌយកទៅច្បាំងទាំងអស់ហេតុនេះត្រូវបានចាត់ទុកជាគ្រួសារដ៏ស្មោះត្រង់ និងបម្រើបក្សដោយឥតមានលក្ខខណ្ឌ ។

នៅសហករណ៍ស្រែរបងនេះ អ្នកស្រុកគោរពស្រឡាញ់គាត់ណាស់ ព្រោះគាត់ស្លូត និងជួយជីវិតមនុស្សគ្រប់គ្នា ។ ខ្ញុំនៅទីនោះបានសេចក្តីសុខណាស់ ខ្ញុំហៅតាយ៉នថា«ឪ» ហើយហៅម៉ែសួនថា «ម៉ែ» ។ ទីនោះនៅឆ្ងាយពីកោះអរីចីប្រហែល១៥០គីឡូម៉ែត្រ ទោះបីជាកងសន្តិសុខស្វែងរកខ្ញុំ ក៏រកមិនឃើញដែរ ព្រោះគ្មានបញ្ជីឈ្មោះអ្វីទេ ។

## ៥០) សោកនាដកម្ម

ស្រែរបងនៅជិតបង្កើយនឹងកោះកណ្ដាលដាកន្ទែងដែលខ្ញុំបានបាត់បង់ឪពុកម្ដាយនិងបងប្អូន ប្រហែលបីគីឡូម៉ែត្រប៉ុណ្ណោះ ។ ការគ្រប់គ្រងនៅស្រែរបងប្រសើរជាងកោះកណ្ដាលឆ្ងាយណាស់ ។ នៅទីនោះ ប្រជាជនអាចបរិភោគដំឡូងខ្លួនដាំ មាន់ដែលខ្លួនចិញ្ចឹមបាន ។ អត្រានៃមនុស្សស្លាប់ក៏តិចជាងនៅកោះកណ្ដាល ក៏ប៉ុន្តែយើងមិនមានឃើញក្រុមយុវជនយុវនារីទេ ព្រោះអ្នកទាំងនោះត្រូវបានបញ្ចូលឲ្យទៅធ្វើការតាមកងចល័តស្រែសម័យដែលស្ថិតនៅឆ្ងាយៗ រីមនុស្សប្រុសក៏ត្រូវបញ្ជូនឲ្យទៅរៀនសូត្រ ឬបាត់ខ្លួនដោយហេតុផលផ្សេងៗដែរ ។ មនុស្សភាគច្រើននៅទីនេះសម្បូរតែស្រីមេម៉ាយចាស់ជរា និងបុរសដែលមានអាយុលើសពីហាសិបឆ្នាំដែលត្រូវធ្វើស្រែតាមសហករណ៍ ។

គិតទៅជាងពីរឆ្នាំហើយដែលខ្ញុំបានចាកចេញពីកោះកណ្ដាល ខ្ញុំបានឆ្លងកាត់ដំណើរជីវិតដ៏លំបាកវេទនានៅកងយុវជនឈានមុខ កងចល័តស្រែសម័យ កងយុវជនដាច់ខាត ទំនប់ពាមល្វា និងកោះអរីចី ។ ក្នុងដំណើរជីវិតដ៏វែងនិងជូរចត់នេះ ខ្ញុំពុំដែលបានដឹងអំពីដំណើរជីវិតអ្នកនៅសមរភូមិក្រោយថាមានដំណើរយ៉ាងណានោះទេ ។ នៅក្បែរផ្ទះ គាយ័ន អង្គការបានសង់ផ្ទះមួយមានតែដំបូលឥតមានជញ្ជាំងសម្រាប់ដាកន្ទែងព្យាបាលជំងឺដែលគ្រប់គ្រងដោយ គាយ័នផ្ទាល់ដែលហៅថា មន្ទីរពេទ្យសមរភូមិ ។

គាយ័ន ជាគ្រូពេទ្យបុរាណដែលព្យាបាលអ្នកជំងឺតាមរបៀបតាមថ្នាំសំបកឫសឈើ អ្នកជំងឺរបស់គាត់គឺស្ថិតក្នុងភាពកម្រិតទីមួយ ។ រៀងរាល់ថ្ងៃ គាយ័ន តែងតែបររទេះចូលក្នុងព្រៃដើម្បីគាស់មើមឈើ ឫសឈើ ឬប្រទាលយកមកផ្សំឲ្យអ្នកជំងឺផឹកជាប្រភេទថ្នាំដុស ។ ក្នុងករណីដែលអ្នកជំងឺមានភាពធ្ងន់ធ្ងរ គាយ័ន ត្រូវបញ្ជូនអ្នកជំងឺនោះទៅពេទ្យឃុំវត្តជីរស ។ ចំពោះអ្នកជំងឺដូចជារូបខ្ញុំ គាយ័នអាចទុកនៅនឹងពេទ្យភូមិឲ្យផឹកថ្នាំដូចជរាឬទុព្វលភាព ។ គាត់បានផ្សំថ្នាំជាពិសេសដល់ខ្ញុំដែលត្រូវផឹកបីដងក្នុងមួយថ្ងៃ ។

នៅមន្ទីរពេទ្យភូមិខ្ញុំបានស្ដាប់រឿងរ៉ាវរបស់មនុស្សបួននាក់ ។ ទីមួយ យាយស៊ីវ គឺជាម្ដាយរបស់អតីតសាស្ត្រាចារ្យវិចិត្រសិល្បៈ ប៉េង អួន នៅវិទ្យាល័យព្រះសុរាម្រិត ។ លោកគ្រូ ប៉េង អួន ល្បីឈ្មោះខាងមុខវិជ្ជាអក្សរសិល្ប៍ និងវិចិត្រសិល្បៈ ។ គាត់ក៏ជាគ្រូរបស់ខ្ញុំដែរ ។ កាលពីឆ្នាំ ១៩៦៨ ខ្ញុំបានសិក្សាពីគំនូរកំប្លែង ។ គាត់ត្រូវបានទទួលស្គាល់ពីរបៀបបង្រៀនរបស់គាត់ ។ គ្រួសារ ប៉េង អួន មានគ្នាប្រាំបួននាក់គឺ ខ្លួនគាត់ និងប្រពន្ធម៉ារ៉ាណុត ប្អូនប្រុសគាត់ ប៉េង អាង កូនបួននាក់ យាយស៊ីវ ជាម្ដាយ និងក្មួយស្រីម្នាក់ ។

ប៉េង អួន មិនត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រដូចបងប្រុសខ្ញុំប៉ុនថាន់ នោះទេ ។ ក៏ប៉ុន្តែ អង្គការបានបញ្ជូនគាត់ឲ្យទៅកាប់ឈើនៅភ្នំដាំដើម្បីសាងសង់អគារសហករណ៍ ។

នៅទីនោះចាញ់ខ្លាំងណាស់ ប៉េង អួន ត្រូវដឹកតាមរទេះត្រឡប់មកសហករណ៍វិញដោយគាត់គ្រុនជាខ្លាំង ។ បន្ទាប់មកខ្លួនគាត់ចាប់ផ្ដើមហើមពោះ ពោះប៉ោង ដៃជើងហើមដូចសប់ ។ ប្រពន្ធគាត់បានខិតខំស្វែងរកថ្នាំមកព្យាបាលដែរ តែពុំជល់សោះ ឯគាយ័ន ក៏អស់តម្រិះ គាត់ដេកនឹងកន្ទេលខ្លួនហើមចេញទឹករហូតដល់ស្លាប់ ។ ប៉េង អួន ស្លាប់បានប៉ុន្មានថ្ងៃ ប្រពន្ធគាត់ក៏ធ្លាក់ខ្លួនឈឺ គាត់ស្លាប់ប្រហែលពាក់កណ្ដាលអាធ្រាត្រ តែកូនតូចរបស់គាត់ដែលបៅដោះម្ដាយរហូតដល់ភ្លឺដោយមិនដឹងថាម្ដាយបានស្លាប់ទៅហើយនោះទេ ។

ប្អូនប្រុសរបស់ ប៉េង អួន ឈ្មោះ ប៉េង អាង ក៏បានស្លាប់នៅកងចល័ត រីឯក្មួយស្រីរបស់គាត់ ក៏ស្លាប់នៅឯស្រែសម័យភ្នំអង្គដែរ ចំណែកកូនប្រុសស្រីពីរនាក់របស់ ប៉េង អួន ក៏ស្លាប់នៅជំរុំកុមារឈានមុខតាំងព្រេច ដោយជំងឺរាក និងដំបៅរលួយ ។

សព្វថ្ងៃ យាយស៊ីវ ដែលមានអាយុជាងចិតសិបឆ្នាំ ងងឹតភ្នែកហើយរស់នៅជាមួយចៅពីរនាក់ បូផា អាយុប្រាំឆ្នាំ និងបុត្រ អាយុពីរឆ្នាំដោយការសន្ដោសប្រណីរបស់ឪយ័ន និង ម៉ែស្លួន តែប៉ុណ្ណោះ ។ ទីពីរគឺ សុខា អាយុ១៩ឆ្នាំ ជាកូនរបស់វិស្វករផ្នែករុក្ខាប្រមាញ់ រីឯម្ដាយរបស់នាងជាគ្រូបង្រៀនបឋមសិក្សា ។ គ្រួសាររបស់នាងត្រូវបានជម្លៀសពីកំពង់ឆ្នាំង នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។ កាលសម័យសង្គមរាស្ត្រនិយម ភ្នាក់ងារមេព្រៃតែងតែចាប់ដាក់គុក អ្នកស្រុកលើដែលកាប់ឈើខុសច្បាប់ដែលជាហេតុធ្វើឲ្យអង្គការបដិវត្តន៍ចាត់ទុកថាពួកមេព្រៃជាក្រុមជិះជាន់សក្តិភូមិ ដែលគួរឲ្យស្អប់ខ្ពើមខ្លាំងណាស់ ហេតុដូច្នោះហើយបានជា ម៉េង គួង ដែលជាឪពុករបស់សុខា ត្រូវអង្គការបញ្ជូនឲ្យទៅរៀនសូត្រ ចំណែកម្ដាយរបស់នាងគឺអ្នកគ្រូ សោម សារី ដែលទើបនឹងសម្រាលកូននោះធ្លាក់ខ្លួនឈឺ ។ ថ្ងៃមួយពេលត្រឡប់មកពីស្ទូងវិញ អ្នកគ្រូបានដួលនៅលើភ្លឺស្រែ

ហើយពីរថ្ងៃក្រោយមក គាត់ក៏ស្លាប់ចោលទារកដែលទើបនឹងមានអាយុមួយខែនោះទៅ ។ សុខា ដែលនៅក្មេងត្រូវបំបៅប្អូនដោយទឹកបបរនិងត្រូវទៅធ្វើការនៅកងចល័តផង រីឯប្អូនប្រុសស្រីរបស់ សុខា ពីរនាក់ទៀត ក៏បានស្លាប់នៅកងកុមារបដិវត្តន៍ឈានមុខនៅតាំងព្រេច ។ សុខា ធ្លាក់ខ្លួនឈឺជាទម្ងន់រហូតដល់វង្វេង ដូចមនុស្សឡប់សតិ ក្រោយមក ប្អូនតូចរបស់នាងក៏ស្លាប់ទៀត ។ សព្វថ្ងៃនាងរស់នៅមន្ទីរពេទ្យជាតិ ហើយក្លាយទៅជាមនុស្សមិនគ្រប់លក្ខណៈ ។ ទីបីគឺ តាវើត អាយុ៦០ឆ្នាំ ។ ប្រពន្ធគាត់ស្លាប់ដោយជំងឺហើម ។ កូនប្រុសស្រីរបស់គាត់ពីរនាក់ត្រូវបញ្ជូនទៅកងចល័តហើយបាត់ដំណឹងរហូតសព្វថ្ងៃ ។ កូនស្រីម្នាក់ទៀតត្រូវពស់ចឹកស្លាប់ពេលលូករន្ទាក្តាមនៅឯស្រែ រីឯកូនស្រីម្នាក់ទៀតព្រមជាមួយប្ដី និងកូនពីរនាក់ត្រូវបានអង្គការបញ្ជូនឲ្យទៅរៀនសូត្រ ហើយបាត់ដំណឹងរហូតសព្វថ្ងៃ ។ តាវើត ក្លាយជាមនុស្សលីលាមិនគ្រប់ដប់ហើយត្រូវបញ្ជូនមកផឹកថ្នាំនៅផ្ទះ តាយ៉ន នេះដែរ ។ ទីបួនគឺ តាហ៊ុយ អាយុ ៦១ឆ្នាំ ប្រពន្ធគាត់ស្លាប់ដោយរោគហើម ហើយកូនបីនាក់ស្លាប់នៅស្រែសម័យព្រមទាំងចៅប្រាំពីរនាក់ស្លាប់នៅកងកុមារឈានមុខ ។ សព្វថ្ងៃតាហ៊ុយ មានជំងឺដុំពោះ ដើរកាន់ឈើច្រត់ និងមានរោគហឺត ។ សរុបសេចក្ដីទៅ ក្នុងចំណោមទាំង៧នាក់ ខ្ញុំដូចគ្រាន់បើជាងគេ ។ ទោះបីជាខ្ញុំស្គមមិនសូវមានកម្លាំង ក៏ប៉ុន្តែខ្ញុំនៅមានស្មារតីល្អ ។ ចំពោះការហូបចុកប្រសើរជាងកោះអរីជីឆ្ងាយណាស់ ។ មិនមានអ្នកណាបង្ខំឲ្យខ្ញុំទៅធ្វើការទេ ព្រោះតាយ៉ន និង ម៉ែសួន បានចេញមុខការពារខ្ញុំជានិច្ច ។ សំណាងណាស់ ដោយកូនស្រីគាត់ជាគណៈសហករណ៍ ។ អំឡុងឆ្នាំ១៩៧៧ មិនសូវមានមនុស្សស្លាប់ច្រើនដូចកាលពីពីរឆ្នាំមុននោះទេ អ្នកទាំងនោះត្រូវបានបញ្ជូនទៅរៀនសូត្រ ធ្វើការបាក់កម្លាំង គ្រុនចាញ់ អត់អាហារ គឺទាំងស្លាប់ទាំងបាត់ខ្លួនអស់ជាងពាក់កណ្ដាល ។ នៅផ្ទះ តាយ៉ន ខ្ញុំអាចហូបចេកល្ហុង ត្រប់បែក ពោតស្ងោរ ។ ពេលខ្លះខ្ញុំអាចទៅស្រែដល់កន្លែងរំងាស់ស្តុកត្នោតអាចសុំទឹកត្នោតគេផឹកឬឡើងត្នោតដោយខ្លួនឯង ។ ពេលនោះហើយ ដែលខ្ញុំចាប់រំឭកឡើងវិញពីបងប្រុសស្រីរបស់ខ្ញុំព្រមទាំងក្មួយប្រុសស្រី ។ ខ្ញុំគិតថា គ្រាន់តែរឿងជីវិតរបស់មនុស្សបួនប្រាំនាក់នេះបានធ្វើឲ្យខ្ញុំស្លុតចិត្តយ៉ាងនេះទៅហើយចុះទម្រាំរឿងរ៉ាវដ៏សោកសង្រេងរបស់មនុស្សជាង៦០០០សហករណ៍ទៀត តើគួរនឹងខ្លោចផ្សាប៉ុណ្ណា?

**ជំពូក៨ ស្នាមធុរយស**

## ៥១) ខ្មែរស

បុងឆ្នាំ១៩៧៧ ដែលខ្ញុំបានស្នាក់នៅជាមួយ តាយ៉ន គឺជាសំណាងមួយក្នុងមួយពាន់គ្រោះថ្នាក់ដែលនៅទីនោះមានអាហារគ្រប់គ្រាន់ប្រកបដោយជីវជាតិ ។ ខ្ញុំអាចដើរចេញទៅតាមវាលស្រែ ឬទៅមាត់ស្ទឹងដើម្បីដាក់អន្ទាក់សត្វបាន ។ ជារៀងរាល់ព្រឹកខ្ញុំតែងតែទៅលើកទ្រូជាមួយ តាយ៉ន ។ ខ្ញុំក៏បានរៀនដាក់អន្ទាក់ និងអន្ទប់ ទន្សាយ សំពោច កញ្ជ្រោង ឬស្វាដើម្បីធ្វើម្ហូប ។ មានពេលខ្លះ តាយ៉ន បណ្ដោយឲ្យខ្ញុំដើរក្នុងព្រៃតែម្នាក់ឯងដើម្បីដោះអន្ទាក់ ។ ថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងស្រាយអន្ទាក់បានទន្សាយនៅគល់ឈើមួយ ស្រាប់តែខ្ញុំភ្ញាក់ដូចគេចោល ដោយនៅពីក្រោយខ្នងខ្ញុំមានបុរសពីរនាក់ មានសក់វែង និងទុកពុកមាត់ស្រមូមដូចៗគ្នា ។ ស្ពាយសាក់កាដូ និងកាន់កាំភ្លើងម្នាក់មួយដើម ។ ខ្ញុំតក់ស្លុតខ្លាំងណាស់ ប៉ុន្តែអ្នកទាំងពីរហាក់ដូចជាមិនបញ្ចេញកាយវិការអមិត្តអ្វីឡើយ ។ ម្នាក់ដែលមាឌធំខ្ពស់សក់រួញក្រញាញ់សម្លឹងមុខខ្ញុំយ៉ាងយូរដែលជាហេតុធ្វើខ្ញុំឡើងឆ្ងល់យ៉ាងខ្លាំងមួយសន្ទុះទើបគាត់លាន់មាត់ហៅឈ្មោះខ្ញុំយ៉ាងភ្លាត់សំឡេង ។ គាត់ស្ទុះឱបឲ្យខ្ញុំហាក់ដូចជាមិត្តភក្តិឬបងប្អូនដែលបែកគ្នាយូរហើយ ក៏បានស្គាល់គឺបង ប៊ុន ឈឿន ជាអនិតដែលខ្ញុំធ្លាប់ធ្វើការជាមួយកងយុវជនឈានមុខនៅទំនប់ទឹកត្រពាំងខ្ទុងសន្តិសុខ ។

គឺបង ប៊ុន ឈឿន នេះហើយដែលបានសែងខ្ញុំក្នុងអង្រឹងពីទំនប់ត្រពាំងខ្ទុងទៅមន្ទីរពេទ្យឃុំនៅវត្តដំរីស ។ ពេលនេះផែនដីហាក់ដូចជាតូចណាស់ដែលបណ្ដាលឲ្យយើងជួបគ្នា ។ យើងបានបែកគ្នាជាងពីរឆ្នាំកន្លងមកហើយ ។

ប៊ុន ឈឿន ប្រាប់ខ្ញុំទៀតថា គាត់ជាខ្មែរស ពាក្យថាខ្មែរសនេះត្រូវបានដាក់ឈ្មោះដោយបក្សកុម្មុយនីស្តកម្ពុជាសំដៅជនណាដែលមិនព្រមចូលរួមចលនាបដិវត្តន៍ ហើយគេចខ្លួនចូលព្រៃ ។ មេដឹកនាំកម្លាំងខ្មែរសបានប្រយុទ្ធដោយអាវុធប្រឆាំងកងទ័ពបដិវត្តន៍ ហើយរស់នៅជាក្រុមតូចៗ ឬជាឯកជន ហើយតែងតែចូលមកលួចម្ហូបអាហារនិងសម្ភារប្រើប្រាស់តាមសហករណ៍ គឺប្រទះអ្វីលួចហ្នឹងមានតាំងពីអង្ករ ស្រូវ ពោត មាន់ ទា ឆ្នាំង កាំបិត ។ មកដល់

ត្រឹមនេះ ខ្ញុំនឹកដល់មិត្តល្អរបស់ ខ្ញុំទាំង៧នាក់ គឺ នួន, ភន, សៀង, ផាន់, ចំរើន, ម៉ាត់, និងសុះ ដែលជ្រើសរើសជីវិតជាខ្មែរសប្រសើរជាងវិលមកកាន់សហករណ៍ ។

ជីវិតក្នុងព្រៃស្រួលណាស់ ព្រៃនេះក្រាស់អាចឲ្យយើងពួនយ៉ាងងាយ ពេលថ្ងៃយើងដេក យប់ឡើងចូលភូមិលួចរបស់យកមកទុកហូបមើលទៅហាក់ដូចសត្វទីទុយរកចំណីពេលយប់អ៊ីចឹង ។ អ្នកទាំងពីរប្រាប់ខ្ញុំថាបានជួបខ្មែរសជាច្រើននាក់គឺដល់រាប់រយនាក់ មានទាំងស្រី ទាំងប្រុស ភាគច្រើនគ្មានកាំភ្លើងទេ ។ ប៊ុន ឈឿន និយាយសុំចបជីកហើយខ្ញុំក៏បានឲ្យរបស់នោះទៅគាត់ហើយយើងក៏បែកគ្នាត្រឹមនោះ ។

រឿងរ៉ាវដែលបណ្ដាលឲ្យ ប៊ុន ឈឿន ក្លាយជាខ្មែរសនោះគឺបន្ទាប់ពីសែងរូបខ្ញុំយកមកដាក់នៅពេទ្យវត្តជីរស រួចហើយ ប៊ុន ឈឿន ក៏ត្រូវអង្គការចាប់ខ្លួនយកទៅដាក់គុកនៅឯត្រពាំងខ្ទុងដែលជាជំរុំសុសខាតខ្វរក្បាល ។ គាត់ត្រូវបានវាយ និងបង្អត់អាហារយ៉ាងវេទនាជាមួយនឹងអ្នកទោសប្រហែលជាងបីរយនាក់ទៀត ។ ការងាររបស់គាត់គឺធ្វើជីលេខមួយ ។ បន្ទាប់ពីនៅទីនោះបានបីខែ ប៊ុន ឈឿន បានរៀបគម្រោងការជាមួយនឹងមិត្តភក្តិម្នាក់ទៀតដើម្បីរត់ចេញពីគុកនេះ ។ ថ្ងៃមួយពេលកំពុងសែងធុងជីលេខមួយ ខណៈដែលក្រុមសន្តិសុខភ្លេចខ្លួន ប៊ុន ឈឿន បានដាក់ធុងចុះហើយយកឈើស្នែងវាយសំពងក្បាលយ៉ាងខ្លាំង សន្តិសុខរូបនេះក៏ដួលចុះ ប៊ុន ឈឿន ដណ្ដើមកាំភ្លើង បារី រីឯដៃគូរបស់គាត់ក៏ដណ្ដើមកាំភ្លើងហើយបាញ់ ។

## ៥២) លាហើយស្រែរបង

ពេលមកដល់ផ្ទះវិញ ខ្ញុំឃើញមិត្ត នឿន តាយ៉ន និង ម៉ែសួន កំពុងអង្គុយចាំជាស្រេច ។ មិត្ត នឿន ដែលជាគណៈសហករណ៍បានប្រាប់ខ្ញុំឲ្យរៀបចំចេញដំណើរសភាពការណ៍នៅទីនេះពុំស្រួលទេ ព្រោះមានការរាយការណ៍ថាបានជួបពួកខ្មែរស ។ មិត្ត នឿន ប្រាប់ខ្ញុំថា គាត់មិនមានសមត្ថភាព និងការពារខ្ញុំបានទេ ដូច្នេះអ្នកទាំងបីសម្រេចបញ្ជូនខ្ញុំទៅកាន់សហករណ៍មួយទៀតដែលក្ដាប់ដោយក្មួយរបស់ តាយ៉ន ។ តាយ៉នពន្យល់ខ្ញុំថា «នឿនគឺជាមនុស្សស្រីមិនសូវឆ្លាតក្នុងការដោះស្រាយទេ ក៏ប៉ុន្តែអញមានក្មួយម្នាក់គឺ សុគុណ ដែលមានប្រាជ្ញាអាចជួយការពារឯងបាន» ។

ខ្ញុំត្រូវតែចាកចេញពីទីនេះដើម្បីសុវត្ថិភាពផ្ទាល់ខ្លួនឯង និងដើម្បីកុំឲ្យមានបញ្ហាដល់ តាយ៉ន និងកូនស្រីគាត់ផង ។ ខ្ញុំបានទៅដល់គោកពេញហើយជួបនឹងបង សុគុណ តាមការណែនាំរបស់មិត្ត នឿន និង តាយ៉ន ។ សុគុណ ជាបុរសដែលមានវ័យប្រហែល ៣៥ឆ្នាំ ។ គាត់ជាអតីតនិស្សិតនៃពុទ្ធិកមហាវិទ្យាល័យនៃទីក្រុងភ្នំពេញ ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ សុគុណ បានត្រឡប់មកស្រុកកំណើត ហើយត្រូវយៀកកុងកេណ្ឌឲ្យធ្វើជាយោធានៅសមរភូមិមុខ ។ តាមធម្មតា សុគុណ ត្រូវអង្គការចាត់ទុកជាវណ្ណៈអនុធនព្រះពុទ្ធសាសនា ក៏ប៉ុន្តែដោយភាពវៃឆ្លាតគាត់ក៏ត្រូវបានបក្សទុកចិត្ត ហើយមិនបានត្រូវបញ្ជូនឲ្យទៅរៀនសូត្រលត់ដំខ្លួនដូចអតីតកម្មាភិបាលដទៃទៀតទេ ។ គ្រាន់តែស្គាល់ខ្ញុំភ្លាម បងសុគុណ បានបញ្ជូនខ្ញុំភ្លាមៗទៅកាន់ក្រោលគោរបស់សហករណ៍ដែលស្ថិតនៅខាងត្បូង ។ ការងាររបស់ខ្ញុំនៅទីនោះគឺឃ្វាលគោ និងក្របី ។

នៅទីនោះមានទាំងគោនិងក្របីប្រហែល៤០០ក្បាល ។ ធម្មតាអ្នកស្រុកនេះពុំមែនជាអ្នកក្រទេ ព្រោះថាជាទីដែលសម្បូរទៅដោយសម្បត្តិធម្មជាតិ ដីមានជីជាតិខ្លាំងណាស់ ជាផ្លូវថ្នល់ឆ្ពោះទៅកាន់ស្រុកឳរ៉ាល់ដែលជាភ្នំខ្ពស់ជាងគេនៅកម្ពុជា ។ កាលមុនសង្គ្រាម អ្នកស្រុកមានជីវភាពធូរធារណាស់ ផ្ទះធ្វើអំពីឈើប្រក់ក្បឿងធំៗ ស្រូវពេញជង្រុកក្នុងមួយគ្រួសារមានគោក្របីបួនដប់ វិវត្តដែលជាទីសក្ការៈបូជារបស់អ្នកស្រុកវិញធំៗស្អាតណាស់ ។ អកុសលស្រុកកើតសង្គ្រាម អ្នកស្រុកអស់នេះ ត្រូវយៀកកុង និងបដិវត្តន៍បានបង្ខំឲ្យប្រមូលគោក្របីយកមកដាក់សមូហភាពព្រមទាំងបង្ខំកូនចៅឲ្យចូលធ្វើកងទ័ពព្រមទាំងលាបពណ៌ឲ្យទៅជាក្រហមខៀវ ស អស់រលីង ។

យើងមានគ្នាដប់នាក់ភាគច្រើនសុទ្ធតែចាស់ៗជាអតីតទាហានបារាំង មេឃុំ ជំទប់ អាចារ្យ និងចៅអធិការវត្ត ។ អ្នកទាំងនេះមិនចូលចិត្តបដិវត្តន៍ទេ តែមិនដឹងធ្វើម៉េចក៏ចេះតែនៅស្ងៀមសម្ងំយកសុខទៅ ។ នៅទីនេះខ្ញុំបានរៀនសូត្រអំពីជីវិតច្រើនណាស់ ។ តាៗអស់នោះបានប្រាប់ខ្ញុំឲ្យដាំដើមគ បានន័យថា កុំធ្វើចេះ កុំធ្វើដឹង អង្គការប្រើឲ្យធ្វើអ្វីកុំឲ្យតវ៉ា ធ្វើជាគ និងធ្វើជាល្ងង់ កុំធ្វើជាចេះពេកក្រែងអង្គការប្រើច្រើននាំឲ្យនឿយ និងស្លាប់ខ្លួន ។

គាត់មានវិទ្យុកញ្ចាស់មួយ តែមិនមានថ្មពិលសម្រាប់ដាក់

ចាក់ស្លាប់ទេ យើងយកឌីណាម៉ូកង់ បង្វិលដោយកង់ធំមួយសម្រាប់ឲ្យមានថាមពល ។ ពេលយប់ស្ងាត់ តា ៗ អង្គុយជុំគ្នាស្តាប់វិទ្យុដែលផ្សាយពីប្រទេសវៀតណាមជាភាសាខ្មែរ ។

ពេលនោះប្រហែលជាអំឡុងខែមេសា ឆ្នាំ១៩៧៨ ។ វិទ្យុវៀតណាមជាខេមរភាសាថ្លែងថ្កោលទោសកម្ពុជាប្រជាធិបតេយ្យដែលមាន ប៉ុល ពត និងអៀង សារី ។ យើងក៏បានស្តាប់វិទ្យុ វីអូអេជាខេមរភាសាដែរ ។

នៅទីនេះយើងមានម្ហូបអាហារពុំមានខ្វះ បើគោក្របីណាដែលចាស់ពេក យើងក៏សម្លាប់ ហើយផ្ញើសាច់ទៅសហករណ៍ហើយរំលែកខ្លះសម្រាប់យើងខ្លួនឯង រីឯសត្វព្រៃដូចជាទន្សាយ សំពោចកំពឹងដូង ប្រមា ឈ្លូស មានពាសពេញដែលអាចដាក់អន្ទាក់ ឬអង្គប់យកមកធ្វើម្ហូបបានផងដែរ ។

ដោយស្ថានការណ៍នៅព្រំដែនកាន់តែធ្ងន់ធ្ងរ នៅតាមសហករណ៍ក៏មិនសូវជារឹតបន្តឹងដូចមុនទេ ជាអកុសលមានមនុស្សរាប់លាននាក់លាចាកលោកនេះទៅហើយ ។ នៅទីនេះ ខ្ញុំមានសេរីភាពណាស់គ្មាននរណាត្រួតត្រាពេលចេញទៅឃ្វាលក្របីតា ៗ តែងឲ្យខ្ញុំជិះសេះបណ្តើរខ្លែក ព្រោះគាត់ភាគច្រើនអាយុលើសពីហុបសិបឆ្នាំទៅហើយ ។ គឺនៅទីនោះហើយដែលខ្ញុំប្រទះដាននៃក្រុមគ្រួសាររបស់ខ្ញុំ ។

## ៥៣) ស្នាមរបួស

នៅក្រោលគោនេះមានតា ៗ ពីរនាក់ជាព្រានដេញសត្វគឺ តាអឿ និង តាសោម ។ ទាំងពីរនាក់បងប្អូនចិញ្ចឹមផ្កែប្រដេញប្រាំមួយក្បាល ។ យើងសម្បូរម្ហូបឥតមានខ្វះទេ ។ រៀងរាល់យប់យើងទាំងអស់គ្នាអង្គុយជុំវិញវិទ្យុដោយមានខ្ញុំជាអ្នករវៃឌីណាម៉ូ ។ គាត់មានសំណួរជាច្រើនចំពោះពាក្យដែលមិនយល់ដោយមានខ្ញុំជាអ្នកចាំឆ្លើយនិងវិភាគនយោបាយ ។ គាត់ទាំងអស់ចូលចិត្តនយោបាយស្រុកទេសខ្លាំងណាស់ ហើយក៏ស្អប់អង្គការបដិវត្តន៍ និងបក្សកុម្មុយនីស្តណាស់ដែរ ។ គាត់និយាយថា គឺដោយសារតែបដិវត្តន៍នេះហើយបានជាគាត់អស់គោក្របី ស្រែភ្លឺ ផ្ទះសម្បែង និងស្លាប់អស់កូនចៅហើយបន់ស្រន់ឲ្យរបបនេះឆាប់រលាយបាត់ទៅ ។

ថ្ងៃមួយខ្ញុំបានចេញបរបាញ់ជាមួយ តាអឿ និង តាសោម នៅក្នុងព្រៃឆ្ងាយពីក្រោលក្របី ។ យើងបានតាមដានជ្រូកព្រៃកាន់តែឆ្ងាយរហូតដល់តាំងឆ្លោចហើយក៏វង្វេងផ្លូវរហូតដល់អូរស្ពាន និងអរិយវង្សក៏បានប្រទះឃើញជំរំដ៏ស្ងាត់ជ្រងំមួយដែលត្រូវបោះចោល ។ ទីនេះហ៊ុមព័ទ្ធទៅដោយរបងលួសបន្លា ។ រីឯផ្ទះដែលធ្វើពីឈើនោះក៏បាក់បែកដំបូលពុកបាក់ធ្លាក់ដល់ដី ទ្វារបាក់រលំ និងគ្មានមនុស្ស ។ តាសោម និង តាអឿ ដែលជាអ្នកមូលដ្ឋានចាស់បានហាមឃាត់មិនឲ្យខ្ញុំចូលទៅក្នុងរបង ។ គាត់ប្រាប់ខ្ញុំថា នៅទីនោះជាជំរំដុសខាត់ខួរក្បាល ។ តាសោម និង អឿ មិនខ្លាចទេ ព្រោះគាត់ស្គាល់ឈ្លបដែលយាមទីនេះ ក៏ប៉ុន្តែគាត់ឆ្ងល់ថា ហេតុអ្វីក៏ពុំឃើញមានមនុស្សម្នាក់សោះ ស្រាប់តែតែមានបុរសម្នាក់ កំបុតជើងម្ខាងបានចេញមកបុរសកំបុតជើងស្គាល់ តាសោម និង តាអឿ ក៏ហៅយើងឲ្យចូលអង្គុយលេង ។ យើងស្គាល់ថាឈ្មោះមិត្ត សុទ្ធ ជាអតីតយុទ្ធជនបដិវត្តន៍ ។ សុទ្ធ កំបុតជើងដោយសារការប្រយុទ្ធទៅសមរភូមិខាងត្បូងក្រុងភ្នំពេញ ។ គាត់ត្រូវបានអង្គការបញ្ជូនឲ្យមកធ្វើការនៅទីនោះក្នុងនាមជាអ្នកយាមនិងដាំបន្លែផ្គត់ផ្គង់អង្គភាពសន្តិសុខ ។

មិត្តសុទ្ធ បានប្រាប់យើងថា អ្នកយាមក្មេងៗត្រូវបានបញ្ជូនទៅទល់ដែនយួនអស់ហើយ ជំរំនេះបានបិទទៅហើយប្រហែលបីខែ ។ តាំងពីឆ្នាំ១៩៧៥ មកដល់ឆ្នាំ១៩៧៨ នេះមានអ្នកទោសប្រហែលជា៦០០គ្រួសារភាគច្រើនជាប្រពន្ធកូនទាហាន លន់ នល់ ។ ភាគច្រើនស្លាប់អស់ហើយ ដោយសារជំងឺ និងធ្វើការបាក់កម្លាំងនៅសល់ខ្លះ អ្នកណាដែលសង្ស័យថា ខ្មាំងត្រូវបានកម្ទេចមុនបិទជំរំ រីឯនៅសេសសល់ត្រូវបានបញ្ជូនឲ្យទៅនៅសហករណ៍ ។ ក្នុងចំណោមអ្នកទាំងនោះក៏មានអ្នកមូលដ្ឋានចាស់ អតីតកម្មាភិបាលដែលបក្សចាត់ទុកជាអាយ៉ងដែរ សព្វថ្ងៃមាននៅសល់ប្រហែលសាមសិបនាក់ ដែលមិនចង់ទៅទីណា ព្រោះទីនេះដីមានជីជាតិល្អសត្វព្រៃក៏សម្បូរទាំងស្មៅសម្រាប់គោក្របីមិនខ្វះ រីឯទឹកស្ទឹងក៏សម្បូរត្រី ។

យើងអង្គុយជជែកក្រោមឈើចំបក់ធំមួយ ។ មិត្ត សុទ្ធ ស្រែកហៅប្រពន្ធឲ្យយកទឹក និងផ្លែចេកមកទទួលយើង ។ ពេលនោះហើយដែលខ្ញុំភ្ញាក់ស្មើរបះដើងទៅក្រោយដោយសំឡេងហៅឈ្មោះ ។ នោះគឺភរិយារបស់មិត្ត សុទ្ធ ។ ខ្ញុំឈ្លីភ្នែកសម្លឹងមើលស្ត្រីម្នាក់នោះ ។ គឺជា ដានី បងថ្លៃស្រីរបស់ខ្ញុំ ។

## ៥៤) ជំរំបិសាច

ដានី ជាប្រពន្ធរបស់បងប្រុសខ្ញុំ ប៉ុនណាត់ ។ គាត់បានមក

ដល់ទីនេះតាមផែនការបោសសម្អាតខ្លាំងជាទ្រង់ទ្រាយធំរបស់បក្ស ក្រោយថ្ងៃរំដោះ ១៧មេសា ឆ្នាំ១៩៧៥ ។ កាលនោះ អ្នកទាំងអស់គ្នារួមមាន ផានី ស៊ីថា និងបងស្រីបង្កើតរបស់ខ្ញុំ ប៊ុនណយ ត្រូវអង្គការចាត់ទុកថា អនុប្រជាជន ។ គាត់ទាំងបីព្រមទាំងកូនៗត្រូវបានអង្គការបញ្ជូនមកដល់ទីនេះ ។ អ្នកទាំងអស់គ្នាត្រូវបានបញ្ជូនពីសហករណ៍កោះកណ្ដាលមក ។ បងផានីមានកូនពីរនាក់ ។ កូនបងអាយុប្រាំមួយឆ្នាំ ត្រូវអង្គការបញ្ជូនឲ្យទៅនៅកងកុមារឈានមុខនៅតាំងព្រេចរហូតមកដល់សព្វថ្ងៃពុំដឹងថា ស្លាប់ ឬរស់រឹង រីណា ដែលមានអាយុបួនឆ្នាំបានមកដល់ទីនេះត្រូវស្លាប់ដោយជំងឺគ្មានថ្នាំព្យាបាល ។ ជីវិតរបស់ ផានី ត្រូវរស់នៅដូចបងាចារស្ទើរឆ្កួតស្ទើរជា ។ គាត់ត្រូវមិត្ត សុទ្ធ យកចិត្តទុកដាក់ថែរក្សាជំងឺ និងផ្ដល់ម្ហូបចំណី ។ សព្វថ្ងៃ អ្នកទាំងពីរយកគ្នាជាប្ដីប្រពន្ធជាងមួយឆ្នាំហើយ និងមានកូនស្រីអាយុបានប្រាំមួយខែ ។

ផានី បានរៀបរាប់ពីជីវិតរបស់បង ស៊ីថា ដែលជាបងថ្លៃម្នាក់ទៀត ។ គាត់បានមកដល់ទីនេះជាមួយកូនពីរនាក់គឺ ស៊ីនឿន ជាកូនស្រីអាយុ១២ឆ្នាំ និង ស៊ីធួន អាយុ៨ឆ្នាំ ។ ស៊ីធួន ជាកូនប្រុសបានកើតរោគហើម ខ្លួន និងដៃជើងដើរមិនរួចហើយក៏ស្លាប់បាត់ទៅ ។

ចំណែក ស៊ីនឿន ជាកូនស្រីបានទៅធ្វើការជាមួយក្មេងៗឯទៀត ដោយនិស្ស័យជាក្មេង និងសេចក្ដីស្រេកឃ្លានក្រោយពីម៉ោងធ្វើការ ស៊ីនឿន បានបោចដៃដំឡូងជ្វាយកមកផ្ទះដើម្បីឲ្យម្ដាយនាងស្ងោរហូប ។ ពេលនោះ ឈ្លបក្មេងៗបានឃើញហើយក៏ចាប់នាងហើយយកដើមទ័ល ដែលមានបន្លាមកវាយ ហើយចងបណ្ដើរ ។ ស៊ីនឿន ស្រែកយំ ហើយស្រែកឲ្យម្ដាយជួយ ម៉ាក់អើយ! ម៉ាក់ជួយកូនផង! ។ ពេលឮសំឡេងកូនស្រែកឲ្យជួយ ដូច្នោះ បងស៊ីថា ក៏បានស្ទុះចេញមកឃើញកូនត្រូវបានវាយសំពងយ៉ាងខ្លាំង គាត់រន្ធត់ចិត្តណាស់ ហើយឈ្លបក្មេងៗទាំងនោះស្រែកគំហក និងលើករំពាត់ចង្អុលមុខ ហើយនិយាយថា គ្មានម៉ាក់! គ្មានប៉ាអីទេ! តើម៉ាក់នេះហ៊ានជួយឬយើងវៃខ្លាំង ខ្លាំងដែលក្បត់បដិវត្តន៍ ។ បងស៊ីថា ឈរស្ងៀម ហើយឈ្លបទាំងនោះហាមមិនឲ្យគាត់យំជាដាច់ខាត គឺត្រូវឈរមើលខ្លួនវាយខ្លាំងដែលលួចដៃដំឡូងជ្វា ។ ធម្មតាដៃដំឡូងជាចំណីរបស់ជ្រូក តែវាមានទោសជាងចោរលួចយន្តហោះទៅទៀត ។ បង ស៊ីថា ត្រូវហាមមិនឲ្យដើរចេញពីទីនោះទេ ដើម្បីបញ្ជាក់ជំហរថា គាត់ជាជនបដិវត្តន៍ ។

ស្អែកឡើងនៅកណ្ដាលវាលក៏ប្រទះឃើញ ស៊ីនឿន បានស្លាប់ដោយជើងជាប់ច្រវាក់ ឈាមជោគសំពត់ដែលបង្ហាញថានាងត្រូវបានចាប់រំលោភដោយឈ្លបទាំងនោះជាច្រើននាក់ ។ បងស៊ីថា បានដួលសន្លប់ និងស្លាប់ប៉ុន្មានម៉ោង បន្ទាប់ពីបានឃើញព្រឹត្តការណ៍នេះ ។ ឈ្លបក្មេងៗបាននាំគ្នាសើចហើយជំណាលពីក្ដីសប្បាយក្នុងការដែលបានចាប់រំលោភក្មេងស្រីកាលពីយប់មិញ ។

## ៥៥) ស្រមោចស៊ីភ្នែក

បង ផានី បាននិយាយរឿងបន្តទៀតអំពីបងស្រីបង្កើតរបស់ខ្ញុំ ប៊ុនណយ ដែលបានមកដល់ទីនេះជាមួយគាត់ដែរ ។ ប៊ុនណយ អាយុ២៧ឆ្នាំ នាឆ្នាំ១៩៧៥ ប្ដីរបស់គាត់គឺជាអនុសេនីយឯក ឈ្មោះ ប្រាក់ កុសល នៃកងទ័ពលោកសេនាប្រមុខ លន់ នល់ នាថ្ងៃទី១៧ មេសា ១៩៧៥ អនុសេនីយឯកដែលជាបងថ្លៃរបស់ខ្ញុំបានចេញទៅបញ្ជាទាហានឲ្យរៀបចំចេញដំណើរទៅទទួលសម្ដេចឪ ។ ក្បួនដំណើរនៃរថយន្តយោធាបានឆ្ពោះទៅទិសខាងលិចតាមផ្លូវជាតិលេខ៥ ហើយបត់ឆ្វេងទៅកាន់ក្រាំងលាវគឺនៅទីនោះហើយដែលកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាបានដាក់ទាហានរង់ចាំវាយឆ្មក់ ។ មកទល់ពេលនេះខ្ញុំពុំដែលបានទទួលដំណឹងពីគាត់ទាល់តែសោះ តាមស្មានគាត់ប្រហែលជាអស់ជីវិតនៅជ្រលងភ្នំក្រាំងលាវនោះហើយ ។

ប៊ុនណយ បងស្រីខ្ញុំត្រូវបានអង្គការបញ្ជូនមកទីនេះ ពេលដែលគាត់មានផ្ទៃពោះប្រាំពីរខែ ។ ចរិតរបស់ ប៊ុនណយ ជាស្រីឆ្នាស់ ជាកូនស្រីទំយើនៅក្នុងគ្រួសាររហូតដល់ពេលរៀបការ ហើយក្លាយជាភរិយារបស់នាយទាហាន ណយ កាន់តែមានភាពក្រអឺតក្រទម ចូលចិត្តឲ្យអ្នកផងសរសើរពីសម្លៀកបំពាក់គ្រឿងអលង្ការដែលខ្លួនមាន ។ សូម្បីតែមកដល់ទឹកដីបដិវត្តន៍ ក៏គាត់ពុំកែប្រែចរិតបែបនេះដែរ ។ ប៊ុនណយ និយាយខ្លាំងៗរិះគន់កម្មាភិបាលដែលប្រើឲ្យធ្វើការ ហើយខ្លួនឯងពួនសម្ងំនៅផ្ទះ បាយស៊ីឆ្ងាញ់ឆ្អែតពោះជារៀងរាល់ថ្ងៃ ។

អ្នករាល់គ្នាត្រូវកែប្រែចរិតរបស់ខ្លួនឯងដែរ មុននឹងថាឲ្យអ្នកដទៃ កុំធ្វើដូចជាត្រឹមត្រូវល្អណាស់ កុំឲ្យដូចជាចចកពាក់ស្បែកពពែ ។ ពាក្យសម្ដីរបស់ ណយ ពុំបានធ្វើឲ្យកម្មាភិបាលសប្បាយចិត្តទេ

ដោយថា ណយ មាននិន្នាការសេរី គ្មានវិន័យ ហើយពុំសុភាពរាបសា ។ នៅជំរំផុសខាត់ខួរក្បាលនេះ កម្មាភិបាលស្អប់ ណយ គ្រប់ៗគ្នា ដោយចាត់ទុក ណយ ជាស្រីសេរី ឬជាស្រីមាត់ស្អុយ ។ ណយ ត្រូវទៅដកស្មៅរហូតដល់ថ្ងៃកើតកូន ។ កម្មាភិបាលពុំអនុញ្ញាតឲ្យឆ្មបទៅបង្កើតកូនឲ្យ ណយ ទេ ដោយទុកឲ្យកើតចេញដោយខ្លួនឯង និងមិនឲ្យនរណាយកបាយទឹកទៅឲ្យទេ ។ បងស្រីដ៏កំសត់របស់ខ្ញុំត្រូវរំកន្ទុបទាំងឈាមដោតខ្លួនទៅផ្ទះបាយ ហើយត្រូវអ្នកទាំងនោះដេរដៀលត្មះ និងចំអកដាក់មុននឹងផ្តល់បបរមួយចានហើយត្រូវពរកូនដើរត្រឡប់ទៅផ្ទះវិញ ។ គាត់ត្រូវទៅដងទឹករកខសមកដុតកម្តៅខ្លួន និងដើរដឹកឫសឈើយកមកស្ងោរផឹកដោយខ្លួនឯង ។ ដោយរបបអាហារពុំគ្រប់គ្រាន់ក៏គ្មានទឹកដោះឲ្យកូនបៅ ។

ក្រោយសម្រាលកូនបានដប់ថ្ងៃ កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យ ប៊ុនណយ ចេញទៅស្ទូង ។ ប៊ុនណយ ពុំអាចធ្វើការបានល្អទេ ព្រោះគាត់នៅឈឺចាប់ខ្លាំងណាស់ ពេលនោះកម្មាភិបាលស្រីម្នាក់បានសើចចំអកថា កាលអំឡុងសង្គ្រាមគាត់កើតកូនបានតែបីថ្ងៃប៉ុណ្ណោះ ក៏ចុះស្ទូងហើយ ពុំដូចជាទាហានប្រតិកិរិយាដែលចេះតែកាច់រាងជិះជាន់កម្លាំងអ្នកដទៃ ហើយធ្វើពុតនាំឲ្យស្ទះចលនាបដិវត្តន៍ ។ ប៊ុនណយ ព្រុកក៏ផ្ទុះកំហឹងឡើងស្រែកជេរពេញទំហឹង ។ កម្មាភិបាលស្រីនោះ ក៏ស្ទុះទៅយកដងវែកដែលគេវែកសំណាបវាយទៅលើ ប៊ុនណយ ពេញទំហឹង ។

ប៊ុនណយ ដួលផ្កាប់មុខនៅក្នុងទឹកស្រែ ស្ត្រីម្នាក់នោះធាក់ផងទាត់ផង និងវាយលើក្បាល និងដងខ្លួនរហូតដល់ ប៊ុនណយ បែកឈាមដោតក្បាល ។

ប៊ុនណយ សន្លប់បាត់ស្មារតីត្រូវបានសែងយកមកផ្ទះ ។ ទាំងម្តាយទាំងកូនដេកក្បែរគ្នាស្រមោចស៊ីភ្នែក និងមាត់រហូតដល់ស្លាប់ ។

គ្រាន់តែស្តាប់រឿងនេះចប់ ខ្ញុំស្ទុតដល់របូតផ្តិលទឹកពីដៃ ក្រោយពីចាកចេញពីទីនោះមក ខ្ញុំដេកអត់បាយឈឺចុកចាប់ក្នុងចិត្តហេតុអ្វីបាននៅលើលោកនេះមានមនុស្សដែលមានភាពឃោរឃៅព្រៃផ្សៃដូច្នេះ?

ក្នុងចំណោមសាច់ញាតិរបស់ខ្ញុំដែលត្រូវបានអង្គការបញ្ជូនមកទីនេះចំនួនប្រាំមួយនាក់ គឺមានតែបង ផានី ម្នាក់ប៉ុណ្ណោះដែលបានរស់រានមានជីវិត ។

## ៥៨) ទណ្ឌិតផ្លែល្ពៅ

ចុងឆ្នាំ១៩៧៨ ស្ថានការណ៍សង្គ្រាមព្រំដែនកម្ពុជាវៀតណាមកាន់តែធ្ងន់ធ្ងរ ឈ្លបក្មេងៗត្រូវបញ្ជូនចេញអស់ ពាក្យស្លោក មហាភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ពុំសូវជាព្រឺខ្លាំងក្លាដូចមុនទៀតទេ ។ ការធ្វើការងារតាមកងចល័តនិងស្រែសម័យក៏មិនសូវសម្រុក នៅតាមសហករណ៍ក៏មិនមានការបញ្ជូនទៅរៀនសូត្រដែរ ។ អ្នករាល់គ្នាអាចសុំច្បាប់ទៅសួរសុខទុក្ខបងប្អូនពីសហករណ៍មួយទៅសហករណ៍មួយទៀតបាន វិទ្យុភ្នំពេញក៏ឈប់និយាយពីការសម្រុកការងារដឹកប្រឡាយ លើកទំនប់ទៀតហើយ គឺនិយាយតែអំពីមហិច្ឆតារបស់វៀតណាម និងអនុត្តរភាពនិយម ។

ថ្ងៃមួយបង សុគុណ ជាគណៈសហករណ៍បានផ្ញើខោអាវ និងស្បែកជើងមកឲ្យខ្ញុំ ហើយពីរថ្ងៃ បន្ទាប់ក៏គាត់ឈៀងចូលមកលេងដល់ក្រោលក្របី ។ គាត់ជិះសេះនិងមាននីរសាពីរនាក់មកជាមួយ ។ ឆ្លៀតឱកាសនេះ ខ្ញុំក៏បានសុំច្បាប់សម្រាកការងារដើម្បីស្វែងរកបងប្អូនសាច់ញាតិនៅសហករណ៍កោះកណ្តាលដែលស្ថិតនៅប្រហែលជាប្រាំពីរគីឡូម៉ែត្រពីទីនេះ ។

បង សុគុណ ក៏បានសរសេរសំបុត្រអនុញ្ញាត ព្រមទាំងឲ្យខ្ញុំខ្ចីកង់របស់សហករណ៍សម្រាប់ជិះទៀតផង ។ ខ្ញុំជិះកង់កាត់វាលស្រែនិងព្រៃនាមប្រហែលមួយម៉ោងទើបបានទៅដល់កោះកណ្តាលជាងបីឆ្នាំ ហើយដែលខ្ញុំបានចាកចេញពីទីនេះ ។ អ្វីៗប្រែប្រួលអស់ហើយ ។ ខ្ទមរបស់ខ្ញុំត្រូវរុះរើ ហើយដីនៅទីនោះបានក្លាយទៅជាស្រែដែលមានភ្លឺខាត់ខ្វែងត្រង់ភ្លឹង ស្នាក់ការសហករណ៍ក៏មានទំហំធំសង់ពីឈើប្រក់ក្បឿង រីឯផ្ទះប្រជាជនត្រូវរុះរើហើយសង់តាមបណ្តោយថ្នល់ជាជួរសម្រាប់ពួកយុវជនដែលទើបនឹងរៀបការជាសមូហភាព ។

ខ្ញុំបានសាកសួរដំណឹងដែលបងថ្លៃខ្ញុំនិងកូនទាំងបីរបស់គាត់ ។ ខ្ញុំបានជួបស្រីម្នាក់ដែលកាលពីបីឆ្នាំកន្លងទៅជាញាតិជិតខាងគាត់បានប្រាប់ថា បងស៊ីណោ រស់តាមកងចល័តស្ត្រីនៅទ្រាំងព្រេច ។ ខ្ញុំក៏បន្តដំណើរទៅទ្រាំងព្រេចដើម្បីស្វែងរកបងស៊ីណោ ។

ខ្ញុំរន្ធត់ចិត្តជាខ្លាំងរហូតដល់ភាំងស្មារតីនៅពេលដែលជួបគាត់ ។ បងស៊ីណោ ស្រែកទ្រហោយំដូចត្រូវគេវាយនឹងដំបងពេលដែលគាត់បានឃើញខ្ញុំ ។ ពេលនោះ គាត់មានរូបរាងស្គមស្គាំងមុខជាំ

រយើករយោកដូចមនុស្សចាស់ តាមពិត គាត់មានអាយុ២៨ឆ្នាំសោះ ក៏ប៉ុន្តែមើលទៅដូចជាមនុស្សចាស់អាយុហាសិបឆ្នាំអ៊ីចឹង ។ បីឆ្នាំកន្លងទៅ ជីវិតរបស់ ស៊ីណេ បានពើបប្រទះនឹងការឈឺចាប់ជាពន់ពេក ព្រោះគាត់បានបាត់បង់ស្វាមីជាទីស្រឡាញ់ព្រមទាំងកូនទាំងបី ។

ស៊ីណេ ជាប្រពន្ធរបស់បងប្រុសខ្ញុំ ប៊ុនថាន់ ។ គាត់មានកូនបីនាក់ គឺដូលី អាយុ៨ឆ្នាំ ដូឡែត ហៅ អាក្អុល និងលីនដា អាយុ៣ឆ្នាំ ។ បងប៊ុនថាន់ ត្រូវអង្គការបញ្ជូនទៅរៀនសូត្រ ចំណែក ដូលី និង អាក្អុល ត្រូវអង្គការបញ្ជូនទៅមណ្ឌលកុមារបដិវត្តន៍ឈានមុខ តាំងពីប៉ុន្មានថ្ងៃ បន្ទាប់ពីយើងបានមកដល់កោះកណ្តាលម៉េ្វះ ។ ស៊ីណេ ត្រូវទៅធ្វើការនៅកងចល័តជាមួយ លីនដា ជាកូនស្រីពៅ ។ កាលនោះ ដូលី ធំគួរសមហើយ និងដឹងខុសត្រូវច្រើនជាងអាក្អុល ។ ដូលី ជាក្មេងស្រីមានចរិតសុភាពរាបសា ។ នាងស្រឡាញ់ប្អូន ហើយចេះមើលការខុសត្រូវចំពោះប្អូន ។ ទាំងពីរនាក់រស់នៅជុំកុមារបដិវត្តន៍ឈានមុខទាំងអស់គ្នា ។ ដូលី ហូបបាយតែពាក់កណ្តាលចានទេ ព្រោះនាងត្រូវរំលែកចំណែករបស់ខ្លួនឲ្យទៅអាក្អុល ដែលស៊ីច្រើន ។ ដូលី តែងតែលួចដើរកាត់វាលស្រែដើម្បីស្កាត់ទៅរកជួបម្តាយនាងដោយនាំមកជាមួយនូវផ្លែត្របែកទុំ ស្វាយ ក្តាម ខ្យង ដែលនាងរកបាននៅស្រែដើម្បីផ្ញើម្តាយ និងប្អូន ។ ថ្ងៃមួយ ដូលី មានជំងឺគ្រុនក្តៅយ៉ាងខ្លាំង ។ អង្គការបានបញ្ជូននាងទៅពេទ្យវត្តដីរស ។ នាងសម្រាកពេទ្យបានកន្លះខែទើបជាសះស្បើយត្រឡប់មកមណ្ឌលកុមារវិញ ។ ចៃដន្យអភ័ព្វកងកុមារត្រូវទៅធ្វើការឆ្ងាយ ប្រធានមណ្ឌលនាំកុមារដើរជាច្រើនម៉ោង ។ ដោយសារតែដូលី ទើបនឹងចាកចេញពីមន្ទីរពេទ្យហើយត្រូវបង្ខំឲ្យដើរឆ្ងាយ កម្លាំងក្មេងបានធ្វើឲ្យនាងដួលប្រកាច់ទៅនឹងដី ។ ស្របនឹងធាតុអាកាសក្តៅផងនោះ ពេលដែលភ្ញាក់ពីសន្លប់ ដូលី ក្លាយទៅជាឆ្កួត ។

អង្គការបានបញ្ជូន ដូលី ឲ្យទៅម្តាយនាងវិញ ក៏ប៉ុន្តែស្ថានការណ៍ជំងឺរបស់នាងស្ថិតក្នុងភាពមិនអាចជួយបាន ។ នាងលែងស្គាល់ម្តាយនិងប្អូនហើយ ។ នាងរត់ចូលព្រៃស្រែកហៅតែឪពុករបស់នាង ។

ពេលនោះ ស៊ីណេ បានទុក លីនដា កូនតូចជាមួយនឹងស្ត្រីអ្នកមើលក្មេងហើយរកថ្នាំព្យាបាល ដូលី ដែរ ក៏ប៉ុន្តែវាហួសពេលទៅហើយ ប៉ុន្មានថ្ងៃក្រោយមក ដូលី ក៏បានលាចាកលោកនេះទៅ ។ ដូលី ស្លាប់ក្នុងអាយុ៨ឆ្នាំ ក្នុងឆ្នាំ១៩៧៥ នៅសហករណ៍កោះកណ្តាល ។ សពរបស់នាងត្រូវបានរុំដោយទ្រាសហើយបញ្ចុះនៅក្បែរភូមិនោះ ។

បន្ទាប់ពីមរណភាពរបស់ ដូលី អាក្អុល ដែលជាក្មេងខិលខូចក៏រឹតតែខូចឡើងថែមទៀត ។ ពេលនេះ វាគ្មានបងស្រីចាំជួយការពារវាទៀតទេ ។ វាចូលចិត្តឈ្លោះគ្នានិងដាល់តប់ជាមួយក្មេងដទៃទៀត ។ វាមិនចង់ទៅធ្វើការទេ ពេលខ្លះវារត់ទៅពួនក្នុងព្រៃដើររកចាប់បង្កួយ ថ្លែនដុតស៊ី ព្រោះថាពេលនេះគ្មាននរណារំលែកបាយឲ្យវាទៀតទេ ។ អាក្អុលត្រូវរំពាត់របស់គ្រូញឹកញាប់ណាស់

ពេលដែលបាត់បង់បងស្រីវា អាក្អុលតែងតែដើររក និងយំគ្រប់ពេលវេលា ។ អាក្អុលបានលួចរត់ពីមណ្ឌលកុមារច្រើនដងតែវាមិនស្គាល់ផ្លូវទើបបានវាវង្វេងក្នុងព្រៃហើយត្រូវកងឈ្លបចាប់បាន ។ កងឈ្លបតែងតែវាយ អាក្អុល ដោយរំពាត់ឬដំបងដើម្បីឲ្យវារាងចាល ប៉ុន្តែកាន់តែវាយ អាក្អុល កាន់តែខូចលើសដើម ។ ថ្ងៃមួយកងឈ្លបបានចងអាក្អុលជាប់នឹងដើមឈើដាក់ឲ្យអង្រ្កងខាំ ព្រមទាំងបង្អត់បាយផង ។

លើកនេះ អាក្អុល លែងខ្វល់ បន្ទាប់ពីត្រូវដោះលែងវារត់កាត់ព្រៃនិងវាលស្រែសំដៅទៅកោះកណ្តាលដើម្បីរកបងស្រី និងម្តាយរបស់វា ។

ពុំមែនជាការងាយស្រួលឡើយសម្រាប់ក្មេងដែលមានអាយុ៦ឆ្នាំ ហើយដើរកាត់ព្រៃចម្ងាយប្រហែលប្រាំពីរគីឡូម៉ែត្រ ប៉ុន្តែម្តងទៀតនេះ អាក្អុល ស្គាល់ផ្លូវគ្រាន់បើជាងមុន ទីបំផុតវាបានមកដល់ចម្ការល្ពៅមួយដែលបោះបង់ចោល ។ ថ្ងៃក្តៅហែង ផ្លែល្ពៅទាំងឡាយត្រូវបេះអស់ហើយ រីឯដើមល្ពៅព្រមទាំងស្លឹកក៏ស្វិតក្រៀមដោយសារកម្តៅថ្ងៃដែរ ។ ដោយមាននិស្ស័យជាក្មេងរឹងរូស អាក្អុលប្រទះឃើញផ្លែល្ពៅមួយដែលភ្លេចបេះមិនអស់ ។ វាក៏ខិនបេះផ្លែល្ពៅនេះ ។ កុមារអភ័ព្វ វាពុំដឹងថានៅពីក្រោយខ្នងមានកងឈ្លបក្មេងៗពីរនាក់ដែលរត់តាមវានោះទេ ។ អាក្អុល ត្រូវឈ្លបក្មេងទាំងពីរនាក់ចាប់បានភ័ស្តុតាងនៅនឹងដៃ ហើយក៏វាយវាបែកក្បាល និងដួលសន្លប់នៅទីនោះឱបផ្លែល្ពៅជាប់ក្នុងដៃ ។

អនិច្ចាកូនក្មេងអាយុ៦ឆ្នាំដែលមិនដឹងនេះជាទោសឧក្រិដ្ឋត្រូវផ្តន្ទាទោសដោយកងឈ្លបដែលមិនចេះអក្សរគ្មានតុលាការកាត់ទោសក្នុងចម្ការល្ពៅដែលបោះបង់ចោលក្រោមកំដៅថ្ងៃនាខែប្រាំង ឆ្នាំ១៩៧៦ គឺប្រហែលជាពីរខែបន្ទាប់ពីមរណភាពរបស់

បងស្រីវា ។ ពេលបាយថ្ងៃត្រង់ នៅកងចល័តស្ត្រី ឈ្លបក្មេងៗទាំងពីរនាក់បានមកប្រាប់ ស៊ីណេ ថា «នែមីង! ខ្ញុំបានវ៉ៃចោរម្នាក់ដែលលួចល្ពៅមីងឯងទៅយកខ្ទោចដង» ។ បងស៊ីណេ ភ្ញាក់ដូចគេចោលទោះមិននិយាយឈ្មោះក៏គាត់យល់ថា ច្បាស់ជា អាក្នុល ពុំខាន ។ គាត់ស្ទុះយ៉ាងលឿនសំដៅទៅទិសដែលកងឈ្លបទាំងពីរចង្អុលប្រាប់ ។ ឈ្លបក្មេងៗ បានបន្ថែមពាក្យថា យើងវ៉ៃចោរមិនមែនវ៉ៃកូនមីងទេ គឺវាយខ្មាំងដែលប្រឆាំងបដិវត្តន៍នៅទីនោះ ស៊ីណេ បានលើកបីកូនប្រុសដែលបែកក្បាលឈាមប្រឡាក់ពេញខ្លួននៅដង្ហើមដ្ដឹកៗ ដៃឱបផ្លែល្ពៅពុំរបេះ អាក្នុល ដាច់ខ្យល់ស្លាប់ទាំងសោកស្ដាយរស់ជាតិផ្លែល្ពៅដែលវាកំពុងតែឃ្លាន ។

ក្មេងអាយុ៦ឆ្នាំ ត្រូវកាត់ទោសប្រហារជីវិតដោយសារផ្លែល្ពៅស៊ុតមួយ ។ រឿងរ៉ាវជីវិតខ្ទោចផ្សារបស់ ស៊ីណេ ពុំទាន់ចប់ទេ ។ គាត់បានបាត់បង់មនុស្សជាទីស្រឡាញ់បីនាក់ហើយក្នុងរយៈពេលជាងមួយឆ្នាំនេះ ទោះយ៉ាងណាក៏សល់ លីន ដា ជាកូនស្រីពៅមួយជាគ្រឿងលួងចិត្តដែរ ។ ស៊ីណេ បន្តរស់នៅក្នុងកងចល័តជាមួយនឹងស្ត្រីអភ័ពជាច្រើននាក់ទៀត ។ កិច្ចការកងចល័តរបស់គាត់គឺស្ទូងដក ច្រូតកាត់ដោយដើរចល័តពីសហករណ៍មួយទៅសហករណ៍មួយទៀត ។ ទៅដល់ទីណាយក លីនដា ទៅដល់ទីនោះ តាំងពីកោះកណ្ដាលដល់តាំងឃ្មុំ ត្រពាំងឫស្សី ចាប្រង់ឆក់កណ្ដាល តានៃ តានប់ចាស់ជាមួយកូនពៅតែម្នាក់គត់ដែលនៅសល់ជាមួយគាត់រហូតដល់ឆ្នាំ១៩៧៧ នៅតានប់ថ្មី លីនដា ធ្លាក់ខ្លួនឈឺ ។ នាងមានជំងឺអុតស្វាយគាប់ជួនឆ្នាំនោះ សង្គ្រាមកម្ពុជាប្រជាធិបតេយ្យជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាមទើបនឹងចាប់ផ្ដើមការអត់ឃ្លានមានជាខ្លាំង ។ លីនដា ធ្លាក់ខ្លួនស្គម និងមិនស៊ីអ្វីសោះ រីឯថ្នាំបុរាណដែលផ្សំឲ្យពុំជល់ ។ ស៊ីណេ ឱបកូនជាប់នឹងដៃ រីឯអង្គការបេះ តែបង្ខំឲ្យទៅធ្វើការដោយនិយាយថាឲ្យទុក លីន ដា នៅមន្ទីរពេទ្យឃុំ ព្រោះ ស៊ីណេ ឯងពុំមែនជាពេទ្យទេ ត្រូវតែធ្វើការកុំឲ្យស្ទះចលនាបដិវត្តន៍ ។ លីនដា បេះនិយាយច្បាស់ ។ នាងប្រាប់ម្ដាយថា នាងចង់ស៊ីបាយរីង ។ ដោយពុំដឹងជាបានអង្ករពីណាយកមកដាំបាយ ស៊ីណេ ក៏យកចិញ្ចៀនពេជ្រដែលប្ដីគាត់បានបញ្ចាំចិត្ត ពេលភ្លាប់ពាក្យនោះទៅដូរអង្ករអ្នក



រូបគំនូរដោយ ឆាយ ស៊ុំឆាត្រ បង្ហាញអំពីវិធីសម្លាប់របស់កម្មាភិបាលខ្មែរក្រហមលើជនរងគ្រោះ

មូលដ្ឋានចាស់បានពីរកំប៉ុងយកមកដាំបាយ ។ អនិច្ចាកុមារីកំសត់បាយពុំទាន់ឆ្អិននៅឡើយ នាងក៏លាចាកលោកនេះទៅហើយ ។

ស៊ីណេ បានបាត់បង់អ្វីទាំងអស់រួមមានប្តី ទាំងបីគឺ ដូលី អាក្នុល និង លីនដា ដែលជាកូនពន្លក នៃក្តីសង្ឃឹមរបស់គាត់ ។ ក្នុងរយៈកាល ៣ឆ្នាំ ៨ខែ២០ថ្ងៃ នៃរបបកម្ពុជាប្រជាធិបតេយ្យរឿងរ៉ាវរបស់ ស៊ីណេ គ្រាន់តែជាឧទាហរណ៍មួយក្នុងចំណោមរឿងរ៉ាវរាប់ពាន់ដែលខ្ញុំបានដឹងគឺជាប្រវត្តិនៃការឈឺចាប់ព្រាត់ប្រាស និងទុក្ខវេទនាហួសពីសមុទ្រទឹកភ្នែក ហួសពីគុកដែលឥតមានជញ្ជាំង ខ្ញុំមិនមានពេលនិងរាយរ៉ាប់ពីរឿងរ៉ាវដែលស្រដៀងនេះឬខ្លោចផ្សាជាងនេះ មកបកស្រាយក្នុងសៀវភៅតែមួយ បានឡើយ ។ ក្នុងគ្រួសាររបស់ ស៊ីណេ ដែលមានសមាជិកប្រាំនាក់បានស្លាប់អស់បួននាក់ គឺស្មើនឹងប៉ែតសិបភាគរយ ចំណែកគ្រួសារខ្ញុំមានដប់មួយនាក់គឺមានប្រាំពីរនាក់ដែលស្លាប់គឺស្មើនឹងហុកសិបបីភាគរយ មានខ្លះទៀត គឺមួយរយភាគរយនេះហើយជាលទ្ធផលនៃបដិវត្តន៍ ។ ឆ្នាំ១៩៧៥ ស៊ីណេ បានចាកចេញពីភ្នំពេញ មាន គ្នាប្រាំនាក់ ក្រោយឆ្នាំ១៩៧៩ គាត់ត្រឡប់ទៅភ្នំពេញវិញតែម្នាក់ឯងគត់ ។

**៥៩) អវសាន**

ទីក្រុងភ្នំពេញបានរំដោះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ចំណែកស្រុក១៤ បានបែកខ្ចាត់ខ្ចាយ នៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩ ។ កម្មាភិបាលដែលមានចិត្ត ឃោរឃៅដឹងខ្លួនថាមិនអាចនៅស្រុកបានក៏ភៀសខ្លួនទៅព្រំដែនថៃ ខ្លះក៏បានទៅដល់ប្រទេសបារាំង អាមេរិក អូស្ត្រាលីរហូតដល់សព្វថ្ងៃ រីឯប្រជាជនស្លូតត្រង់ក៏បានរស់នៅតាមស្រុកភូមិរបស់ខ្លួនដូចគេឯងធម្មតា ។

បងស៊ីណេ ត្រឡប់មកភ្នំពេញវិញ ដើម្បីស្វែងរកបងប្អូន និងញាតិមិត្តរបស់គាត់ ។ ចំណែកខ្ញុំដែលចាកចេញពីផ្ទះទៅមានគ្នា១៧នាក់ ពេលត្រឡប់មកវិញតែម្នាក់ឯងប៉ុណ្ណោះ ។

ខ្ញុំចាប់ផ្តើមគូររូបនិងសរសេរសៀវភៅនេះនៅក្រោយខែមេសា ឆ្នាំ២០១១ ពេញ៣៦ឆ្នាំ ដែលក្រុមកម្ពុជាប្រជាធិបតេយ្យបានទទួលជ័យជម្នះ ។

ខ្ញុំមិនមានចេតនាណាមួយនឹងនិយាយថា អ្នកណាខុស អ្នកណាត្រូវនោះទេ ខ្ញុំគ្រាន់តែចង់រំឭកពីខ្លួនឯងអំពីដំណើរជីវិត និងចង់និយាយប្រាប់អ្នកណាដែលអានសៀវភៅនេះដើម្បីឲ្យដឹងអំពីអ្វីដែលខ្ញុំឃើញដែលខ្ញុំបានជួបប្រទះ ពីទីកន្លែងដែលខ្ញុំធ្លាប់រស់នៅពីមនុស្សដែលខ្ញុំធ្លាប់ធ្វើការជាមួយ ពីចប ពីបង្គី ពីគ្រឿងឧបករណ៍ដែលខ្ញុំបានប្រើ ។

ខ្ញុំឧទ្ទិសសៀវភៅនេះដល់ជនកម្ពុជាទាំងអស់ដែលធ្លាប់បានទទួលនូវសោកនាដកម្ម ទុកខ្លោចផ្សា ដូចជារូបខ្ញុំដែរ ។

នេះគឺជាសារមួយដែលផ្ញើដល់សមាជិកគ្រួសារញាតិ មិត្តរួមថ្នាក់ មិត្តទាំងឡាយដែលធ្លាប់ធ្វើការជាមួយខ្ញុំនៅការដ្ឋានទំនប់ទឹកនៅកងឈានមុខ នៅស្រែសម័យ នៅកោះអវិចី ទោះអ្នកនោះរស់នៅស្រុកខ្មែរក្តី នៅបរទេសក្តី សូមជ្រាបថា ខ្ញុំកំពុងរស់នៅស្រុកខ្មែរជាស្រុករបស់យើង ជាប្រទេសកម្ពុជាដែលយើងទាំងអស់គ្នាស្រឡាញ់ ។ បើសិនជាមានមិត្តណាម្នាក់ក្នុងចំណោមយើងទាំងដប់មួយនាក់ ដែលហែលទឹកឆ្លងបឹងកងមាស សូមសម្លាញ់ទាំងអស់សរសេរអ៊ីម៉ែល ឬទូរស័ព្ទមកខ្ញុំ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំនឹកអ្នករាល់គ្នាណាស់មកទល់ពេលនេះ ខ្ញុំជួបតែម្នាក់គត់ គឺអ្នកដែលបានចែវទូកចម្លងយើងពេលភៀសខ្លួននោះ ។

**ឆាយ ស៊ុំឆាត្រ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ចាត់ទុកជាសំណាង

ការរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ ដោយជួបការព្រាត់ប្រាសសាច់ញាតិបងប្អូន ជារឿងស្ទើរតែគ្រប់ជនរងគ្រោះទាំងអស់បានជួបប្រទះ ។ ប៉ុន្តែ វីរភាពរបស់ឪពុកម្តាយដែលអាចមើលថែរក្សាកូនឲ្យឆ្លងផុតរបបនេះ ជារឿងមួយដែលគួរតែបង្ហាញឲ្យអ្នកដទៃបានដឹងនិងឮ ។ លោក ចាន់ ស្រ៊ា សព្វថ្ងៃមានអាយុ ៦៨ឆ្នាំ រស់នៅស្រុកតាខ្មៅ ខេត្តកណ្តាល ព្រមជាមួយនឹងប្រពន្ធ មៀច តារា ដែលមានអាយុលើសស្វាមីខ្លួនមួយឆ្នាំ ជាជនរងគ្រោះក្នុងចំណោមជនរងគ្រោះរាប់លាននាក់ដែលបានគស្ស៊ូរួចជីវិតពីសម័យខ្មែរក្រហម ។

ចាន់ ស្រ៊ា មានស្រុកកំណើតនៅស្រុកកោះធំ ខេត្តកណ្តាល និងប្រពន្ធគឺជាប្រជាជនម្នាក់ ដែលមានដើមកំណើតស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ គាត់បានរៀបរាប់ថា នៅក្នុងសម័យ លន់ នល់ គាត់មានតួនាទីជាអ្នកបម្រើការងារជាទាហានអាកាសចរណ៍របស់ លន់ នល់ ដែលមានទីបញ្ជាការនៅព្រលានយន្តហោះពោធិ៍ចិនតុង ។ ចំណែកប្រពន្ធរបស់គាត់ជាកូនកាត់ ចិន ខ្មែរ-វៀតណាម ដែលមានឈ្មោះដើម ថឺ តារា គាត់ជាគ្រូពេទ្យនៅមន្ទីរពេទ្យព្រះកេតុមាលា តែនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏ប្តូរឈ្មោះមកជា មៀច តារា វិញ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចូលមករំដោះទីក្រុងភ្នំពេញ ចាន់ ស្រ៊ា បានដឹងរួចទៅហើយថាគ្រោះថ្នាក់នឹងខិតជិតមកដល់ ។ ពីដំបូង គាត់មិនដែលរំពឹងទុកថាអំពើប្រល័យពូជសាសន៍នឹងឈានមកដល់នោះឡើយ ដោយគាត់គិតថាប្រទេសកម្ពុជាបានទទួលឯករាជ្យរួចទៅហើយ ។ ដោយដឹងថាគ្រោះថ្នាក់បានឈានមកដល់ ចាន់ ស្រ៊ា បានដោះឯកសណ្ឋានយោធា ហើយ



កូនរបស់ ចាន់ ស្រ៊ា ៖ ច័ន្ទ សម្ផស្ស និង ច័ន្ទ ដានិត ថតនៅអំឡុងទសវត្សរ៍ឆ្នាំ៨០



ចាន់ ស្រ៊ា និង ឪពុកមា ថតនៅអំឡុងទសវត្សរ៍ឆ្នាំ៦០

ប្រញាប់ប្រញាល់សំដៅទៅរកប្រពន្ធនិងកូនរបស់គាត់ដែលរស់នៅម្តុំផ្សារដេប៉ូ សង្កាត់លេខមួយ ក្រុងភ្នំពេញ ។ ទាហានដែលរួមការងារជាមួយគាត់មួយចំនួនបានរត់គេចខ្លួនតាមផ្លូវអាកាសទៅកាន់ប្រទេសថៃ ។ ចំណែកឯ ស្រ៊ា មិនដាច់ចិត្តរត់ចោលប្រពន្ធកូននៅពេលដែលប្រទេសកំពុងចលាចល នោះឡើយ ។

ចាន់ ស្រ៊ា ជាមួយប្រពន្ធ ព្រមទាំងកូនស្រីពីរនាក់ ច័ន្ទ ដារី, ច័ន្ទ ដានី និង កូនប្រុស ច័ន្ទ ដានិត និងសមាជិកក្រុមគ្រួសាផ្សេងទៀត ត្រូវខ្មែរក្រហមជម្លៀសដោយថ្មើរជើងពីក្រុងភ្នំពេញទៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ ភូមិចាមជាភូមិមួយស្ថិតនៅក្បែរព្រំប្រទល់ប្រទេសវៀតណាមខាងត្បូង ។ ពេលនោះខ្មែរក្រហមបានប្រកាសថា នៅពេលនេះទីក្រុងត្រូវបានបោសសម្អាត ដូច្នេះសូមបងប្អូនចាកចេញទៅស្រុកកំណើតចំនួនរយៈពេលបីថ្ងៃ ។

ធ្វើដំណើរមកដល់និងរស់នៅភូមិចាម ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធាន តា កុប និង តា យ៉ន ។ ស្រ៊ា បានឲ្យដឹងថា អ្នកទាំងពីរគឺជាមនុស្សល្អទេ ។ អស់រយៈពេលមួយឆ្នាំ ស្រ៊ា ត្រូវបានខ្មែរក្រហមបង្ខំឲ្យលើកទំនប់កម្ពស់ប្រាំម៉ែត្រ ដោយគ្មានពេលសម្រាក ។ ការងារនៅទីនោះ លើកទំនប់មានសភាពធ្ងន់ធ្ងរជាខ្លាំង ដោយគាត់ត្រូវខ្មែរក្រហមប្រើឲ្យរែកដីម្តងបួនបង្គី ។ ទោះបីជាមេភូមិបានដឹងថាគាត់ ជាអតីតទាហាន លន់ នល់ និង មានប្រពន្ធជាអតីតគ្រូពេទ្យ ។ ស្រ៊ា និង គ្រួសារ មិនត្រូវខ្មែរក្រហមយកទៅសម្លាប់ ឬដាក់ទណ្ឌកម្មនោះឡើយ ។ ប្រជាជនជាច្រើននាក់នៅក្នុងភូមិត្រូវបញ្ជូនទៅតំបន់ពាយ័ព្យឬយកទៅសម្លាប់ ។ ផ្ទុយទៅវិញគ្រួសាររបស់ ស្រ៊ា ត្រូវខ្មែរក្រហមទុកជីវិតឲ្យ ។ បើទោះបីជាយ៉ាងណាក៏ដោយ សេចក្តីស្លាប់ក្នុងរបបដ៏ខ្មៅងងឹតនេះ មិនអាចជៀសបាននោះឡើយ ។ ប្អូនថ្លៃប្រុសរបស់គាត់ឈ្មោះ ជី ឈឿង ដែលជាអធិការជាន់ខ្ពស់ ក្នុងសម័យ លន់ នល់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ភ្លាមៗ ក្រោយពេលចូលមកដល់ភូមិ ។ ចំណែកឈ្មោះ ជី ផល្លី ដែលជាប្អូនថ្លៃស្រី ក៏ត្រូវខ្មែរក្រហមសម្លាប់ជាមួយនឹងកូនបួននាក់ដែរ ។

មួយរយៈក្រោយមក អង្គការដឹងថាមានប្រជាជននៅភូមិចាមលួចរត់ទៅប្រទេសវៀតណាម មេភូមិក៏បានបញ្ជូនប្រជាជនទៅកាន់តំបន់ផ្សេង ។ ស្រ៊ា និងគ្រួសារត្រូវអង្គការបញ្ជូនទៅភូមិអង្កាញ់តាមរទេះ ។ នៅតាមផ្លូវទៅភូមិអង្កាញ់ បងប្អូនជីដូនមួយរបស់ប្រពន្ធគាត់ឈ្មោះ ព្រុំ ហៀក ត្រូវខ្មែរក្រហមបង្ខំឲ្យទឹមអូសរទេះហាក់បីដូចជាសត្វគោ និងបានសម្លាប់ចោលនៅកណ្តាលផ្លូវ ។ គ្មាននរណាម្នាក់ដឹងពីមូលហេតុនៃការសម្លាប់នេះឡើយ ។ ការបាត់បង់សាច់ញាតិគឺពិតជាគួរឲ្យសោកស្តាយ ជាខ្លាំង ។

បន្ទាប់ពីការបញ្ជូនជាលើកទីពី គ្រួសាររបស់ ស្រ៊ា ក៏ត្រូវបញ្ជូនបន្តទៅ ភូមិព្រះធាតុ ឃុំព្រះធាតុ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ គ្រួសារគាត់ទាំងមូល ស្ទើរតែត្រូវអស់ជីវិតនៅពេលដែលអត្តសញ្ញាណរបស់អ្នកទាំងអស់គ្នាត្រូវបានលាតត្រដាង ។ ការរួចជីវិតរបស់ពួកគាត់អាចជាវាសនាឬជាសំណាង ។ នៅពេលដែលអត្តសញ្ញាណរបស់ ស្រ៊ា និង គ្រួសារត្រូវបានបកអាក្រាតស្រាប់តែមានបុរសម្នាក់ឈ្មោះ អៀង ដែលមានបងប្អូនធ្វើជាកម្មាភិបាលខ្មែរក្រហមនៅក្នុងភូមិ បានចេញមុខមកអះអាងថា ស្រ៊ា ធ្លាប់ធ្វើការជាអ្នកលីស៊ីម៉ង់ត៍ ជាមួយខ្លួននៅកំពង់ផែមួយ

ក្បែរវត្តឧណ្ណាលោម ក្នុងក្រុងភ្នំពេញ មិនដូចជាអ្វីដែលបានចោទប្រកាន់គាត់ពេលនេះឡើយ ។ មេភូមិព្រះធាតុ ពេញចិត្ត ស្រ៊ា ជាខ្លាំង ដោយសារគាត់បេះដាំថ្នាំជក់ ហើយតែងតែយកថ្នាំជក់ជូនជាអំណោយទៅប្រធានភូមិជារឿយៗ ។ នៅពេលសម្រាកពីការងារលើកទំនប់ ស្រ៊ា តែងតែត្រូវមេភូមិចាត់ឲ្យឡើងលេងកំប្លែង ។ ដោយការទុកចិត្ត ស្រ៊ា ក៏ត្រូវបង្គាប់ឲ្យសម្រាកនៅផ្ទះជាមួយមេភូមិ ។ ថ្ងៃមួយ នៅពេលដែលមេភូមិកំពុងតែដេកលក់ គាត់បានប្រថុយជីវិតលួចអង្ករដាក់ក្នុងក្រមា រួចព្យាយាមហែលទឹកដើម្បីយកអង្ករទៅឲ្យប្រពន្ធ និងកូនៗដែលកំពុងតែស្រេកឃ្លានឯផ្ទះ ។ ប៉ុន្តែទោះបីជាមេភូមិបានដឹងពីទង្វើទាំងនេះក៏ដោយ ក៏មេភូមិនោះមិនបានដាក់ពិន័យឬទារុណកម្មទៅលើ ស្រ៊ា ដែរ ។ ដោយសារតែគាត់គឺជាមនុស្សដែលមេភូមិស្រឡាញ់និងរាប់អាន ។ បើទោះបីជាមេភូមិពេញចិត្ត ស្រ៊ា ក៏ដោយ យប់មួយ ស្រ៊ា និងគ្រួសារត្រូវអង្គការបញ្ជូនឲ្យទៅទប់ទឹកទន្លេ ។ ស្រ៊ា និង ប្រពន្ធ គិតថា ខ្លួននឹងមិនអាចមកវិញ ដោយរួចជីវិតនោះទេ ព្រោះសុខៗស្រាប់តែអង្គការស្នើឲ្យទៅទប់ទឹក បែបនេះ ។ ស្រ៊ា ចាំមិនភ្លេចទេ "នៅក្នុងទឹកសុទ្ធតែសាកសពអណ្តែត" ហើយការងារគាត់នៅពេលនោះគឺកប់សាកសពដែលអណ្តែតពេញទឹកទាំងនោះ ។

នៅឆ្នាំ១៩៧៨ រយៈពេលប្រាំពីរខែ មុនវៀតណាមចូលរំដោះប្រពន្ធរបស់ ស្រ៊ា បានផ្តល់ កំណើតកូនស្រីពៅម្នាក់ឈ្មោះ ច័ន្ទ សម្ផស្ស ក្រោយពេលឆ្លងទន្លេរួច ឆ្មបបានឲ្យហូបទឹកលាយជាមួយនឹងអំបិលនិងដេះ ។ ក្រោយពីហូបរួច ប្រពន្ធរបស់គាត់បានរាកយ៉ាងខ្លាំង ។ នៅពេលដែលកូនស្រីពៅអាយុ៨ខែ វៀតណាមក៏បានវាយចូលខេត្តស្វាយរៀង ។ ការឈ្លានពានរបស់វៀតណាមគឺជាក្តីសង្ឃឹមថានឹងអាចរួចជីវិតពីរបបនេះ ។ ខុសពីការរំពឹងទុកប្រជាជនជាច្រើននាក់ត្រូវបាត់បង់ ជីវិតក្នុងពេលដែលខ្មែរក្រហមប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាម ។ ស្រ៊ា បានបន្តថា "ថ្ងៃមួយគាត់បានឃើញប្រជាជនជាច្រើនត្រូវយោធាខ្មែរក្រហមបានបើកត្រាក់ទ័រកិនសម្លាប់នៅតាមផ្លូវជាតិលេខមួយប្រឡាក់សុទ្ធតែឈាម សាកសពទាំងនោះ ត្រូវខ្មែរក្រហមរុញទម្លាក់ចូលក្នុងទន្លេមេគង្គនៅ ខាងស្រុកអ្នកលឿង" ។

ក្រោយពីថ្ងៃរំដោះ ស្រ៊ា និង គ្រួសារប្រមូលស្រូវបានមួយរទេះ មុននឹងធ្វើដំណើរមករស់នៅភូមិចាម ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែងវិញ ។ គ្រួសាររបស់គាត់រស់នៅភូមិចាមរយៈពេលប្រាំខែមុននឹងត្រឡប់មកក្រុងភ្នំពេញវិញ ។ ជីវិតនៅទីក្រុងភ្នំពេញពិតជាមានការលំបាកជាខ្លាំង ។ ប៉ុន្តែបទពិសោធនៃការធ្វើបាប ជិះជាន់ និងបាត់បង់បងប្អូន គឺជាសោកនាដកម្មដែលមិនអាចបំភ្លេចបាន ។ បទពិសោធឈឺចាប់ទាំងនោះនៅតែដក់ជាប់ក្នុងចិត្តរបស់ ស្រ៊ា ដល់ពេលបច្ចុប្បន្ន ។ អ្វីដែលអាក្រក់ជាងនេះទៅទៀតនោះគឺចាន់ ស្រ៊ា បានទទួលរងជំងឺផ្លូវចិត្តពេញមួយជីវិត ។


រូបរាប់ពីឆ្វេង : ច័ន្ទ សម្ផស្ស, ច័ន្ទ ដាវី, មៀច តារា (ប្រពន្ធ) និង ចាន់ ស្រ៊ា (ប្តី) ច័ន្ទ ដានី និង ច័ន្ទ ដានិត ថតឆ្នាំ១៩៨៣

**អ៊ឹម ច័ន្ទបូរ៉ាជាតិ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានឆ្ពោះទៅរកការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 168, December 2013 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.